# សង្គ្រាការណ៍ ១៤៨

ខែសីហា ឆ្នាំ២០១២



## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

# រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## មាតិកា

ការសួរដេញដោលអ្នកជំនាញប្រវត្តិសាស្ត្រ
សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ
ដោយចៅក្រមអង្គជំនុំជម្រះ ១
ដោយសហព្រះរាជអាជ្ញា ៦
ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ២៦
ដោយមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ៣៦

ក្រុមសង្គ្រាការណ៍ ៖
ឆាយ ឈុនលី, ឌី សុជាតា,
លីមជ័យទ័ត្តនិងចាន់ប្រាថ្នា

*លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ អ្នកជំនាញប្រវត្តិសាស្ត្រ អំឡុងពេលនៃការផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២*

*(ប្រភពរូបថត៖ អ.វ.ត.ក)*



(រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២៖ ការផ្តល់សក្ខីកម្មរបស់អ្នកជំនាញប្រវត្តិសាស្ត្រ ដេវីដ ឆេនដល័រ

## ថ្ងៃទី១៨-២៥ ខែកក្កដា ឆ្នាំ២០១២

*ដោយ ឈុនលី និង លីម ដ័យទ័ត្ត*

## សេចក្តីផ្តើម

ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការសួរដេញដោលលើអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រមួយរូប គឺលោក សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ (David Chandler) ។ លោកសាស្ត្រាចារ្យ ឆេនដល័រ គឺជាអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រដំបូងបង្អស់ ដែលត្រូវបានអញ្ជើញឲ្យមកផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុនៃសវនាការសំណុំរឿង០០២ ។ សក្ខីកម្មលោកសាស្ត្រាចារ្យ ឆេនដល័រ បានផ្តោតជាសំខាន់លើបរិបទប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អង្គជំនុំជម្រះ និងភាគីក្នុងសវនាការបានចោទសួរបន្ថែមទៀតទាក់ទងនឹងសៀវភៅដែលលោកបានចងក្រងដូចជា *«បងធំទីមួយ»*, *«សោកនាដកម្មនៃប្រវត្តិសាស្រ្តកម្ពុជា»*, *«ប៉ុល ពត រៀបចំផែនការសម្រាប់ពេលអនាគត»* និង *«សំឡេងពីមន្ទីរស-២១»* ។ល។ ការសួរដេញដោលបានចាប់ផ្តើមមុនដំបូងដោយចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះ បន្ទាប់មកអង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលជូនភាគី ដោយចាប់ផ្តើមពីសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ គឺក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

ភាគីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានចំណាយពេល៣ថ្ងៃដើម្បីសាកសួរសាក្សី ហើយក្រុមមេធាវីការពារក្តីទាំងបីក្រុមក៏បានចំណាយពេល៣ថ្ងៃដូចគ្នាដែរ ។ ជាការកត់សម្គាល់ឃើញថា ការបកប្រែប្រដេញផ្ទាល់មាត់ពីភាសាអង់គ្លេសមកជាភាសាខ្មែរបានជួបប្រទះបញ្ហាខ្លះៗ ដូចជា ការបាត់បង់នូវការបកប្រែសម្តី និងអត្ថន័យដើមរបស់ភាគី និងអ្នកជំនាញ ដែលបណ្តាលមកពីល្បឿននៃការនិយាយជាភាសាអង់គ្លេសមានលក្ខណៈលឿនពេក ។ ដូច្នេះផ្នែកខ្លះនៃព្រឹត្តិប័ត្រសង្កេតការណ៍នេះត្រូវបានសរសេរឡើងដោយផ្អែកលើសម្តីដើមជាភាសាអង់គ្លេស ដើម្បីរក្សានូវខ្លឹមសារដើមរបស់អ្នកជំនាញ និងភាគី ។ បន្ថែមពីលើនេះ នៅក្នុងកិច្ចដំណើរការសវនាការទាំង៦ថ្ងៃ ជនជាប់ចោទ អៀង សារី បានស្នើសុំអង្គជំនុំជម្រះដើម្បីតាមដាននីតិវិធីសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍នៅក្នុងបន្ទប់រង់ចាំ ដោយសារមូលហេតុសុខភាព ។ រីឯជនជាប់ចោទ នួន ជា មានវត្តមានត្រឹមតែសវនាការពេលព្រឹកតែប៉ុណ្ណោះ ហើយស្នើសុំអង្គជំនុំជម្រះដើម្បីតាមដានដំណើរការនីតិវិធីសវនាការពេលរសៀលនៅឯបន្ទប់រង់ចាំ ដោយសារមូលហេតុសុខភាពដូចជនជាប់ចោទ អៀង សារី ដែរ ។ មានតែជនជាប់ចោទ ខៀវ សំផន ម្នាក់ប៉ុណ្ណោះ ដែលបានចូលរួមពេញលេញនៅក្នុងកិច្ចដំណើរការសវនាការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដល័រ ។

សវនាការរយៈពេល៦ថ្ងៃ ទទួលបានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ សិស្ស និងនិស្សិត ចំនួនប្រមាណជាង ២,០០០នាក់ ដែលមកពីបណ្តាខេត្តមួយចំនួនដូចជា ខេត្តសៀមរាប តាកែវ កណ្តាល កំពង់ស្ពឺ និងកំពង់ចាម តាមរយៈកិច្ចសម្របសម្រួលរបស់អង្គភាពកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ១) ការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដល័រ ដោយចៅក្រមអង្គជំនុំជម្រះ

### ១.ក) ការសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន

ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺលោកចៅក្រម និល ណុន បានសួរសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាវតារ និងប្រវត្តិនៃការសិក្សារបស់

លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ។ ប៉ុន្តែមុននឹងចូលដល់ការសួរសំណួរ លោកប្រធានអង្គជំនុំជម្រះបានស្នើឲ្យលោកសាស្ត្រាចារ្យឡើងធ្វើសម្បថតាមបែបបស្ចឹមប្រទេស ដោយត្រូវនិយាយតាមការអានពាក្យសម្បថរបស់ក្រឡាបញ្ជី នៃអង្គជំនុំជម្រះ ។ លោក ឆេនដល័រ ស្បថថា *"ខ្ញុំសូមប្រកាសថា ខ្ញុំនឹងផ្ដល់ជំនួយដល់អង្គជំនុំជម្រះសាលាដំបូងដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខំប្រឹងប្រែងអស់ពីសមត្ថភាព ។ ខ្ញុំសូមប្រកាសជាឡារិកថា ខ្ញុំនឹងផ្ដល់ជំនួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ"* ។ ឆ្លើយតបនឹងសំណួររបស់លោក ប្រធានអង្គជំនុំជម្រះទាក់ទងនឹងប្រវត្តិសាវតារ និងប្រវត្តិនៃការសិក្សា លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា សព្វថ្ងៃលោកមាន អាយុ៧៩ឆ្នាំ និងមានកាន់លិខិតឆ្លងដែនចំនួនពីរ គឺលិខិតឆ្លងដែន របស់ប្រទេសអូស្ត្រាលី និងរបស់សហរដ្ឋអាមេរិក ។ បច្ចុប្បន្នលោកមានទីលំនៅនៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី និងមានតួនាទីជាសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រនៅប្រទេសអូស្ត្រាលី ។ លោក ឆេនដល័រ បានបន្តថា លោកអាចនិយាយភាសាខ្មែរបាន ប៉ុន្តែការសរសេររបស់លោកមិនសូវល្អឡើយ ។ លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ហាវើដ (Harvard) និងសាកលវិទ្យាល័យ មីឈីហ្គេន (Michigan) នៅ



ចៅក្រម និល ណុន

សហរដ្ឋអាមេរិក ។ ទាក់ទងនឹងការស្រាវជ្រាវវិញ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកផ្ដោតសំខាន់លើសម័យខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧៥រហូតមកដល់ពេលបច្ចុប្បន្ន ដោយលោកបានសរសេរសៀវភៅមួយចំនួនអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា *"សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា"*, *"បងធំទីមួយ"* និង *"សំឡេងពីមន្ទីរស-២១"* ។ លោកក៏ធ្លាប់បានសរសេរអត្ថបទជាច្រើនផ្សេងទៀតនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ទាក់ទងនឹងទិដ្ឋភាពនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ។ ការសរសេរសៀវភៅ និងអត្ថបទជាច្រើននេះ គឺដោយសារលោកមានចាប់អារម្មណ៍លើប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៦០ នៅពេលដែលលោកធ្វើជាអ្នកការទូតប្រចាំស្ថានទូតសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញរយៈពេលពីរឆ្នាំ ។ នៅពេលបញ្ចប់ការងារជាអ្នកការទូត លោកបានចាប់ផ្ដើមសរសេរនិក្ខេបបទទាក់ទងនឹងប្រវត្តិសាស្ត្ររបស់កម្ពុជានៅមុនសម័យអាណានិគម ។ បន្ទាប់មកលោកផ្ដោតសំខាន់លើប្រវត្តិសាស្ត្រសម័យទំនើប ជាពិសេសសម័យកម្ពុជាប្រជាធិបតេយ្យ ។ លោកបញ្ជាក់ថា លោកបានចាប់ផ្ដើមសរសេរសៀវភៅ *"សោកនាដកម្មនៃប្រវត្តិកម្ពុជា"* នៅក្នុងឆ្នាំ១៩៨៥ និងបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩១ ហើយធ្វើការកែប្រែឡើងវិញនៅឆ្នាំ១៩៩២ ។ ចំពោះសៀវភៅដែលមានចំណងជើងថា *"ប៉ុល ពត រៀបចំផែនការសម្រាប់ពេលអនាគត"* គឺការជាការសរសេររួមគ្នារវាងលោក និងលោក បេន ឃៀរនិន និងលោកស្រី ប៊ូចន្ទូ ដោយបានធ្វើការបោះពុម្ពនៅក្នុងឆ្នាំ ១៩៩៨ ។ រីឯសៀវភៅដែលមានចំណងជើងថា *"បងធំទីមួយ"* គឺត្រូវបានរៀបចំចងក្រងឡើងនៅក្នុងឆ្នាំ១៩៨៧ និងបានធ្វើការបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៩៩ ដោយមានការកែសម្រួលផ្នែកខ្លះពីច្បាប់ដើម ។ ទាក់ទងនឹងសៀវភៅ *"សំលេងពីមន្ទីរស-២១"* លោកបានបញ្ជាក់ថា សៀវភៅនេះត្រូវបានសរសេរក្នុងឆ្នាំ១៩៩៣ និងបោះពុម្ពក្នុងឆ្នាំ១៩៩៩ ដើម្បីចងក្រងសៀវភៅនេះ លោកបានធ្វើការសិក្សាលើឯកសារដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរទួលស្លែង និងបានធ្វើសម្ភាសន៍ជាមួយនឹងលោក ហ៊ឹម ហ៊ុយ អតីតបុគ្គលិកនៅមន្ទីរស-២១ លោក វ៉ាន់ណាត និង ប៊ូ ម៉េង អតីតជនរងគ្រោះនៅមន្ទីរស-២១ និងលោក ញ៉ែម អេន អតីតអ្នកថតរូបនៅមន្ទីរស-២១ ។ លោកបានបន្ថែមថា លោកមិនធ្លាប់បានធ្វើសម្ភាសន៍ជាមួយនឹងមេដឹកនាំខ្មែរក្រហម ដូចជា នួន ជា អៀង សារី ខៀវ សំផន ទេ ហើយលោកក៏មិនធ្លាប់ធ្វើសម្ភាសន៍ជាមួយនឹង ឌុច ដែរ ។

## ១.២) ការសួរដេញដោលដោយលោកស្រីចៅក្រុម ស៊ីលវៀ ខាតវ៉្រាយត៍

### ១.២.១) សំណួរទាក់ទងនឹងសៀវភៅ «ប៉ុល ពត រៀបចំផែនការសម្រាប់ពេលអនាគត»

មុននឹងចាប់ផ្តើមសំណួរលោកសាស្ត្រាចារ្យ ឆេនដល័រ


លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

លោកស្រីចៅក្រុមបានជម្រាបជូនអំពីវិសាលភាពនៃសវនាការដំណាក់កាលដំបូង ទាក់ទងនឹងអន្តហេតុទាំងឡាយដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអន្តហេតុទាំងនោះគឺរាប់ចាប់តាំងពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា រហូតដល់ការជម្លៀសនៅដំណាក់កាលទីមួយ និងទីពីរ ។ លោកស្រីចៅក្រុមបានបន្តថា លោកស្រីនឹងមានសំណួរមួយចំនួនអំពីសៀវភៅដែលមានចំណងជើងថា ប៉ុល ពល រៀបចំផែនការសម្រាប់ពេលអនាគត ។ សំណួរដំបូងរបស់លោកស្រីចៅក្រុម គឺទាក់ទងនឹងខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ ដោយបានចោទសួរថា តើនរណាដែលត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យកំណត់ថាជាខ្មាំងនៅដំណាក់កាលដំបូងនៃរបបនេះ? លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ខ្មាំង គឺជាអ្នកដែលធ្លាប់បម្រើការឲ្យរដ្ឋការរបស់របប លន់ នល់ ឬរបបសាធារណរដ្ឋខ្មែរ បន្ទាប់មកគឺប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុង និងត្រូវបានគេហៅថា ប្រជាជនថ្មីឬប្រជាជន ១៧មេសា ដែលក្លាយជាទិសដៅរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកនៅឆ្នាំ១៩៧៦ ការកំចាត់កម្មាភិបាលដែលត្រូវបានចាត់ទុកថាខ្មាំងផ្ទៃក្នុងរបស់បក្សបានចាប់ផ្តើមឡើង ហើយនៅពាក់កណ្តាលឆ្នាំ១៩៧៧ មានការបោសសម្អាតកម្មាភិបាលផ្ទៃក្នុងយ៉ាងទូលំទូលាយនៅទូទាំងប្រទេស ។ លោកស្រីចៅក្រុម ខាតវ៉្រាយត៍ បានបន្តសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងប្រភពឯកសារដែលលោកបានយកមកប្រើប្រាស់ធ្វើការចងក្រងជាសៀវភៅដែលមានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់ពេលអនាគត» ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា មានឯកសារសំខាន់ចំនួន៨ ដែលលោកយកមកប្រើប្រាស់ដើម្បីជាប្រភពក្នុងការសរសេរសៀវភៅនេះ ក្នុងនោះក៏មានចម្លើយសារភាពរបស់ ហ៊ូ នឹម និងកំណត់ហេតុកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីចៅក្រុមទាក់ទងនឹងភាពគួរឲ្យជឿជាក់បាននៃប្រភពឯកសារទាំងនោះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបន្ថែមថា លោកជឿជាក់ថា ឯកសារទាំងនោះជាឯកសារដែលមានយថាភាព ព្រោះនៅសល់ដោយចៃដន្យពីសម័យនោះ មិនមែនជាការបន្សល់ទុកដោយចេតនាទេ ហើយវាត្រូវបានរកឃើញដោយបុគ្គលមួយចំនួន ។ បន្ទាប់មកបុគ្គលនោះ បានប្រគល់ឯកសារនោះជូនលោក បេិន ឃៀរនិន (Ben Kiernan) ហើយលោក ឃៀរនិន បានប្រគល់ឯកសារនោះមកឲ្យលោកនៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ ។

### ១.២.២) តួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ

លោកស្រីចៅក្រុម ខាតវ៉្រាយត៍ បានបន្តសួរទាក់ទងនឹងឯកសារសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ដោយស្នើឲ្យ


លោកស្រីចៅក្រុម ស៊ីលវៀ ខាតវ៉្រាយត៍

លោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ពាក្យថា កម្ទេចក្នុងជួរ

និង ក្រៅជួរបក្ស គឺស្មើនឹងការសម្រេចសម្រាប់អ្នកនៅក្នុងបក្ស និង នៅក្រៅបក្ស ។ ស្រីថៅក្រមបានបន្តស្នើឲ្យសាស្ត្រាចារ្យ ឆេនដល័រ បញ្ជាក់អំពីសេចក្តីសម្រេចរបស់បក្សទាក់ទងនឹងគោលនយោបាយ ផលិតស្រូវឲ្យបាន៣តោនក្នុង១ហិចតា ។ លោកសាស្ត្រាចារ្យ បានអះអាងថា សេចក្តីសម្រេចនោះ គឺជាផែនការសម្រាប់អនាគត មួយរបស់ ប៉ុល ពត ។ ពាក់ព័ន្ធនឹងសំណួរថាតើ ជនជាប់ចោទទាំងបី រូបនៅក្នុងសំណុំរឿង០០២ គឺជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិប តេយ្យមែនដែរឬទេ? លោកបានឆ្លើយតបថា នួន ជា, អៀង សារី និង ខៀវ សំផន គឺជាមេដឹកនាំនៃរបបនោះ ហើយលោកបានបន្តថា បើតាមឯកសារដែលលោកស្រាវជ្រាវ នួន ជា និងអៀង សារី ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ប៉ុន្តែលោកមិនច្បាស់ទេចំពោះ ខៀវ សំផន។ លោកសាស្ត្រាចារ្យមិនប្រាកដទេថា ខៀវ សំផន បានកាន់កាប់តួនាទីជាប្រធានគណៈប្រធានរដ្ឋរហូតដល់ឆ្នាំ១៩៧៩ ប៉ុន្តែ អៀង សារី ពិតជាបានកាន់កាប់តំណែងរបស់ខ្លួនជារដ្ឋមន្ត្រី ក្រសួងការបរទេសរហូតដល់ឆ្នាំ១៩៧៩ ព្រោះតួនាទីរបស់ អៀង សារី ត្រូវបាន ផ្សព្វផ្សាយជាសាធារណៈ និងមានការដឹងពីអន្តរជាតិ ។ ចំពោះ នួន ជា គឺមានតំណែងជាប្រធានសភា ប៉ុន្តែតំណែងនេះ មិនមែនជាតំណែងសំខាន់របស់ នួន ជា នោះទេ ។ ឆ្លើយតបនឹងការ ស្នើសុំឲ្យធ្វើការបញ្ជាក់ពីសំណាក់លោកស្រីថៅក្រមទាក់ទងនឹងការ អះអាងរបស់ជនជាប់ចោទ នួន ជា ដែលនិយាយនៅចំពោះមុខ ថៅក្រមស៊ើបអង្កេតថា ខ្លួនមិនមានតំណែងធំ និងមិនមានអំណាច ដូចក្រុមកាន់កាប់អំណាចខាងយោធា ព្រោះខ្លួនស្ថិតនៅក្នុងក្រុម នយោបាយ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកមិនសូវជឿ សម្តីទាំងអស់នេះរបស់ នួន ជា ទេ ។ លោកបន្ថែមថា យោងតាម ការស្រាវជ្រាវបន្ថែមរបស់លោកតាមរយៈដីកាដំណោះស្រាយ នួន ជា ក៏មានតួនាទីខ្ពស់ និងជាបុគ្គលមួយរូបដែលបានចូលរួមក្នុង ការបង្កើតគោលនយោបាយសម្រាប់អនុវត្តនៅទូទាំងប្រទេស ហើយថែមទាំងកាន់កាប់តួនាទីខាងយោធា និងការបរទេសដែរ ។ លោកបានប្រៀបធៀប ប៉ុល ពត និង នួន ជា ថា ប៉ុល ពត ប្រៀបដូចជា ប្រធាន ហើយ នួន ជា ប្រៀបបាននឹងនាយកប្រតិបត្តិ។ លោកបន្ត ថា សមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិកនៃគណៈមជ្ឈិមទាំងអស់ គឺមានអំណាចក្នុងការគ្រប់គ្រងប្រទេសទាំងមូលនៅពេលនោះ ។

### ១.ខ.៣) ទំនាក់ទំនងរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍

ចំពោះសំណួររបស់លោកស្រីថៅក្រម ខាតព្រ៉ាយត៍ ពាក់ព័ន្ធនឹង ទំនាក់ទំនងរវាងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម លោកសាស្ត្រាចារ្យ




ឆេនដល័រ បានលើកឡើងថា លោកមិនបានធ្វើការសិក្សាលម្អិត លើបញ្ហានេះទេ ។ ដូច្នេះលោកមិនទាន់អាចឆ្លើយតបនឹងសំណួរ នេះបានឡើយ ប៉ុន្តែលោកគ្រាន់តែបញ្ជាក់ដោយខ្លីថា គឺមាន ការផ្សារភ្ជាប់គ្នារវាងស្ថាប័នទាំងពីរនេះ ។

លោកស្រី ថៅក្រម បានបន្តសួរលោកសាស្ត្រាចារ្យ ឆេនដល័រ អំពីកិច្ចប្រជុំរបស់គណៈមជ្ឈិមដែលធ្វើឡើងនៅទីក្រុង ភ្នំពេញ ចន្លោះពីថ្ងៃ២១ ដល់២៣ ខែសីហា ឆ្នាំ១៩៧៦ ដោយមាន ការថ្លែងសុន្ទរកថាយ៉ាងវែងរបស់លេខាបក្ស ប៉ុល ពត ទាក់ទងនឹង ផែនការបួនឆ្នាំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ លោកស្រីបាន សួរថា តើអ្នកចូលរួមអ្នកទាំងអស់គឺជាសមាជិកគណៈអចិន្ត្រៃយ៍ និងសមាជិករបស់គណៈមជ្ឈិមឬយ៉ាងណា? លោកសាស្ត្រាចារ្យ បញ្ជាក់ថា លោកមិនមានភស្តុតាងដើម្បីបញ្ជាក់ថា អ្នកចូលរួម ទាំងនោះជាសមាជិករបស់គណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមទេ ប៉ុន្តែលោកជឿថាអ្នកចូលរួមទាំងអស់នោះ គឺពិតជាសមាជិកនៃ

គណៈទាំងពីរនេះ ។ លោកស្រីបានបន្តសួរទាក់ទងនឹងពាក្យថា អង្គការ ថាតើពាក្យនេះសំដៅតែ លើរូប ប៉ុល ពត ឬមានបញ្ចូលសមាជិកផ្សេងទៀតនៅក្នុងនោះដែរ? លោកបានបញ្ជាក់ថា



...មួយគណៈប្រតិភូបរទេស (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកមិនមានភស្តុតាងច្បាស់លាស់ទេ ប៉ុន្តែលោកគិតថា អង្គការ គឺសំដៅលើសមូហភាព មិនមែនសំដៅលើរូប ប៉ុល ពត តែម្នាក់ទេ ។

### ១.ខ.៤) ការបង្កើត និងការអនុវត្តគោលនយោបាយប្រាំចំណុច

លោកស្រីចៅក្រម ខាតព្រាំយត៌ បានបន្តសួរសំណួរទាក់ទងនឹងការបង្កើត និងការអនុវត្តគោលនយោបាយចំនួនប្រាំចំណុច ដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា និងត្រូវបានជឿជាក់ថា ជនជាប់ចោទទាំងបីរូប និងសមាជិកបក្សកុម្មុយនីស្តកម្ពុជាដទៃទៀតបានយកមកអនុវត្ត ។ គោលនយោបាយទាំងប្រាំចំណុចនោះរួមមាន៖

១) ការផ្លាស់ទីលំនៅដែលធ្វើឡើងច្រើនលើកច្រើនសារ ជម្លៀសប្រជាជនទៅតំបន់ជនបទ និងពីជនបទមួយទៅជនបទមួយផ្សេងទៀត ។

២) ការបង្កើតការទាញយកផលប្រយោជន៍តាមរយៈសហករណ៍ និងតាមការដ្ឋាន ។

៣) ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងដែលត្រូវបានរកឃើញនៅក្នុង និងក្រៅបក្ស ។

៤) ការចេញនូវវិធានការជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជា ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងអតីតមន្ត្រីរាជការ បុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ ។

៥) ការដាក់បទបញ្ញាទាក់ទងនឹងការរៀបការដោយបង្ខំ ។

លោកស្រីបានសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ថា តើការអនុវត្តគោលនយោបាយទាំងប្រាំមានសារៈសំខាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? លោកសាស្ត្រាចារ្យបានឆ្លើយថា គោលនយោបាយទាំងប្រាំនោះ គឺជាសុទ្ធតែជាគោលនយោបាយដែលសំខាន់ ជាពិសេសគឺគោលនយោបាយពីចំណុចទី១ ដល់ចំណុចទី៣ ។ លោកបានបន្តថា លោកមិនបានដឹងថានរណាជាអ្នកបង្កើតគោលនយោបាយទាំងនោះទេ លោកគ្រាន់តែដឹងថា គោលនយោបាយពីរដំបូងត្រូវបានយកមកអនុវត្តនៅមុនឆ្នាំ ១៩៧៥ រីឯគោលនយោបាយបីចុងក្រោយ គឺត្រូវបានយកមកអនុវត្តនៅក្រោយថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ ។ លោកសាស្ត្រាចារ្យបានបញ្ជាក់បន្ថែមថា គោលនយោបាយទាំងអស់នោះត្រូវបានបក្សកុម្មុយនីស្តកម្ពុជាយកមកពន្យល់ និងផ្សព្វផ្សាយដល់ប្រជាជនតាមរយៈការប្រជុំនៅក្នុងតំបន់ សហករណ៍ ភូមិភាគ ជាដើម ។ គោលនយោបាយមួយចំនួនត្រូវបានពន្យល់ដល់កម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈទស្សនាវដ្ដីទង់បដិវត្ត ហើយលំហូរនៃព័ត៌មានត្រូវបានគ្រប់គ្រង និងមិនមានការជជែកគ្នាអំពីគោលនយោបាយរបស់បក្សជាសាធារណៈឡើយ ។ ពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា លោកស្រីចៅក្រមបានសួរទាក់ទងនឹងការផ្សព្វផ្សាយគោលនយោបាយរបស់បក្សតាមរយៈទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន យុវនារី បដិវត្ត ដោយលោកស្រីបានចោទសួរថា តើអ្នកណាខ្លះដែលអាចទទួលបានទស្សនាវដ្ដីទាំងពីរនេះ? សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា អ្នកដែលអាចទទួលបានទស្សនាវដ្ដីទាំងពីរនេះបាន គឺមានតែសមាជិកបក្សមួយចំនួនតែប៉ុណ្ណោះ រីឯអ្នកដទៃទៀត គឺមិនបានទទួលទស្សនាវដ្ដីទាំងនោះឡើយ ។

## ២) ការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដល័រ ដោយសហព្រះរាជអាជ្ញា

### ២.ក) ការសួរដេញដោលដោយសហព្រះរាជអាជ្ញារងជាតិ

សហព្រះរាជអាជ្ញារងជាតិគឺលោក ចាន់ តារាស្មី សួរលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ អំពីសៀវភៅដែលលោកសាស្ត្រាចារ្យបានសរសេរទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក តារាស្មី បានចាប់ផ្តើមសំណួរទាក់ទងនឹងប្រវត្តិសាវតាររបស់អ្នកជំនាញ និងប្រភពឯកសារដែលលោកសាស្ត្រាចារ្យឆេនដល័រ បានប្រើប្រាស់ដើម្បីចងក្រងជាសៀវភៅប្រវត្តិសាស្ត្ររបស់លោក ។ ចម្លើយដែលលោកសាស្ត្រាចារ្យឆ្លើយតបចំពោះសំណួររបស់លោកសហព្រះរាជអាជ្ញារង គឺស្រដៀងគ្នានឹងចម្លើយដែលលោកធ្លាប់បានឆ្លើយជូនអង្គជំនុំជម្រះទាក់ទងនឹងប្រវត្តិនៃការសិក្សា និងឯកសារដែលលោកយកមកប្រើប្រាស់ធ្វើជាប្រភពក្នុងការសរសេរសៀវភៅរបស់លោក ។

#### ២.ក.១) ការដេញដោលលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា

លោកសហព្រះរាជអាជ្ញារងជាតិ បានបង្ហាញឯកសារទាក់ទងនឹងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដោយបានចោទជាសំណួរថា តើលក្ខន្តិកៈកុម្មុយនីស្តកម្ពុជាបង្កើតឡើងក្នុងគោលបំណងអ្វី? ឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យបញ្ជាក់ថា បើតាមការយល់ដឹងរបស់លោក លក្ខន្តិកៈនេះគឺបង្កើតឡើងដើម្បីចែងឲ្យបានច្បាស់លាស់អំពីទម្រង់នៃការងារមួយចំនួន និងមានចែងអំពីអង្គការ គោលបំណង គំនិតទស្សនៈនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាឧបករណ៍មួយដើម្បីធ្វើការពិចារណាអំពីបដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកមិនច្បាស់ទេថា ឯកសារនេះត្រូវបានបង្កើតឡើងនៅពេលណា និងសរសេរឡើងដោយនរណា ប៉ុន្តែបើតាមការចងចាំរបស់លោក លក្ខន្តិកៈបក្សនេះ ប្រហែលជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៦ ។ បន្ទាប់មក លោកសហព្រះរាជអាជ្ញារង តារាស្មី បានបង្ហាញជូននូវឯកសារលក្ខន្តិកៈបក្សត្រង់កថាខណ្ឌទី២ នៅលើកញ្ចក់កុំព្យូទ័រ ដោយស្នើសុំលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់អំពីអត្ថន័យនៃកថាខណ្ឌទី២នោះ ។ នៅក្នុងកថាខណ្ឌទី២នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានចែងថាៈ

*«បក្សកុម្មុយនីស្តកម្ពុជា ជាបក្សរបស់វណ្ណៈកម្មករ ក្រោយពីបក្សដឹកនាំសម្រេចបដិវត្តប្រជាជាតិប្រជាធិបតេយ្យបានទាំងស្រុង និងជាស្ថាពរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក បក្សបន្តដឹកនាំបដិវត្តសង្គមនិយម និងកសាងសង្គមនិយមតទៅទៀត ដោយផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែក ។ បក្សមានធាតុពិតជាអង្គការខ្ពស់បំផុត វណ្ណៈកម្មករកម្ពុជាជាកងទ័ពស្រួច មោះមុតអង់អាចបំផុត ជាអង្គបញ្ជាការគ្រប់គ្រង និងចាត់ចែងការងារបដិវត្តទាំងអស់ ហើយជាប់ជិតស្និត និងមហាជន ។»*



សហព្រះរាជអាជ្ញារង ចាន់ តារា ស្មី

លោកសាស្ត្រាចារ្យបានបញ្ជាក់ថា អត្ថន័យនៃកថាខណ្ឌទី២នៃកលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានេះ គឺមានលក្ខណៈត្រង់ៗដែលបញ្ជាក់ពីអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយប្រទេសកម្ពុជាទាំងមូលគឺគ្រប់គ្រងដោយបក្សទោះបីជាមិនមានលក្ខណៈស្របច្បាប់ ប៉ុន្តែបក្សមានសិទ្ធិអំណាចក្នុងការអនុញ្ញាតឲ្យមានការគ្រប់គ្រងដោយ ផ្តាច់មុខ ដាច់ខាត នៅពេលនោះ ។ លោកបន្តថា ពាក្យផ្តាច់មុខ ដាច់ខាត គឺបញ្ជាក់អំពីការមិនអនុញ្ញាតឲ្យមានការប្រឆាំងឬមតិជំទាស់នឹងលក្ខន្តិកៈរបស់បក្សទេ ដែលពាក្យនេះមានអត្ថន័យទូលំទូលាយ ។ រីឯពាក្យថា«*អង្គការខ្ពស់បំផុត*»គឺសំដៅលើអ្នកទទួលខុសត្រូវដែលមាន លេខា អនុលេខាបក្ស មានគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ដែលមានអំណាចក្នុងការអនុវត្តសកម្មភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកសហព្រះរាជអាជ្ញារងជាតិបានបន្តស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់អំពីពាក្យថា

"ប្រជាធិបតេយ្យប្រមូលផ្តុំ" ដែលមាននៅក្នុងកថាខណ្ឌទី៦ នៃលក្ខន្តិកៈបក្សកុម្មុយនីស្ត ។ ឆ្លើយតបនឹងសំណើនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ពាក្យប្រជាធិបតេយ្យប្រមូលផ្តុំ គឺជាពាក្យមួយដែលមានអត្ថន័យហាក់បីដូចជាផ្ទុយនឹងអ្វីដែលបក្សបានកំណត់ ព្រោះមិនមានប្រជាធិបតេយ្យទូលំទូលាយ នៅក្នុងការប្រមូលផ្តុំឡើយ ។ លោកបន្ថែមថា បក្សបានចាត់ទុកខ្លួនឯងជាអ្នកតំណាងឲ្យឆន្ទៈរបស់ប្រជាជន និងជាអ្នកតំណាងឲ្យប្រជាធិបតេយ្យស្របច្បាប់នៃអំណាចរបស់ប្រជាជននៅក្នុងទម្រង់មួយតាមបែបប្រមូលផ្តុំ ។ ប៉ុន្តែលោកបានទទួលស្គាល់ថា ពាក្យនេះគឺលំបាក និងស្មុគស្មាញ ដែលលោកមិនធ្លាប់បានឃើញពីមុនមក ។

នៅអំឡុងពេលនៃការសួរដេញដោល លោកតំណាងសហព្រះរាជអាជ្ញារងជាតិ តារាស្មី បានព្យាយាមស្នើឲ្យអ្នកជំនាញសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់អំពីអត្ថន័យនៃពាក្យសំខាន់ៗដែលមាននៅក្នុងលក្ខន្តិកៈបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុន្តែការស្នើសុំរបស់លោកសហព្រះរាជអាជ្ញារងជាតិឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់នេះ ត្រូវបានទទួលការជំទាស់ជាញឹកញាប់ពីសំណាក់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ។ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស បានអះអាងថា សំណួររបស់សហព្រះរាជអាជ្ញា គឺជាសំណួរដែលនាំឲ្យអ្នកជំនាញធ្វើការសន្និដ្ឋាន ។ លោកបន្តថា អ្នកជំនាញសាស្ត្រាចារ្យ ឆេនដល័រ មិនមែនជាអ្នកបកស្រាយរដ្ឋធម្មនុញ្ញទេ លោកគ្រាន់តែបកស្រាយព្រឹត្តិការណ៍ទៅតាមការយល់ឃើញរបស់លោកតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក្តី ការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី ត្រូវបានចៅក្រមប្រធានអង្គជំនុំជម្រះបដិសេធ ។

គួរកត់សម្គាល់ថា សំណួរជាច្រើនរបស់លោកសហព្រះរាជអាជ្ញារងជាតិដែលបានចោទសួរលោក សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ទាក់ទងនឹងសមាជិកភាពនៃបក្សកុម្មុយនីស្តកម្ពុជា និងមហាសន្និបាតបក្ស ត្រូវបានលោកសាស្ត្រាចារ្យបញ្ជាក់ថា លោកមិនទាន់អាចឆ្លើយតបនឹងសហព្រះរាជអាជ្ញាភ្លាមៗបានទេ ប៉ុន្តែនឹងឆ្លើយសំណួរទាំងអស់នោះនៅពេលក្រោយ ដោយសារលោកមិនមានឯកសារដែលលោកបានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងដៃ ។

### ២.ក.២) ការិយាល័យនយោបាយ៨៧០ និងមន្ទីរ៨៧០

លោកសហព្រះរាជអាជ្ញារងជាតិ តារាស្មី បានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការបកស្រាយអំពីតួនាទីនៃមន្ទីរ៨៧០ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងឯកសារជាច្រើន ។ ពាក់ព័ន្ធនឹងតួនាទីនៃមន្ទីរទាំងពីរនេះ លោកមិនអាចឆ្លើយឲ្យបានច្បាស់លាស់នោះទេ ព្រោះឯកសារដែលនិយាយពីតួនាទីនៃមន្ទីរនេះ គឺមានលក្ខណៈជាន់គ្នានឹងតួនាទីនៃគណៈមជ្ឈិម តួនាទីនៃគណៈអចិន្ត្រៃយ៍ និងតួនាទីរបស់ ប៉ុល ពត និង នួន ជា ។ល ។ ម្យ៉ាងវិញទៀត តួនាទីនៃមន្ទីរនេះមិនមានចែងឲ្យច្បាស់លាស់នៅក្នុងលក្ខន្តិកៈបក្សទេ ដូច្នេះតួនាទីនៃមន្ទីរនេះមានលក្ខណៈស្រពិចស្រពិលនៅឡើយ ។ ឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញា ដែលសួរថាតើមន្ទីរ៨៧០ត្រូវបានបង្កើតឡើងនៅពេលណា? លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា មន្ទីរ៨៧០ អាចត្រូវបានបង្កើតឡើងនៅមុនឆ្នាំ១៩៧៥ ប៉ុន្តែលេខកូដ៨៧០ អាចត្រូវបានដាក់ឲ្យមន្ទីរនេះ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយមន្ទីរនេះ គឺជាកន្លែងធ្វើការរបស់ ប៉ុល ពត ។ លោកបានបន្ថែមថា ក្រៅពី ប៉ុល ពត ដែលមានតួនាទីសំខាន់នៅក្នុងមន្ទីរ៨៧០ លោកពុំទាន់ឃើញមានឯកសារផ្សេងទៀតដែលនិយាយថា នួន ជា អៀង សារី និង ខៀវ សំផន ជាសមាជិកនៃមន្ទីរទេ ។

លោកសហព្រះរាជអាជ្ញារង តារាស្មី បានបន្តសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងឈ្មោះ ខឿន ថាតើលោកសាស្ត្រាចារ្យធ្លាប់ស្គាល់ឈ្មោះ ខឿន ដែរឬទេ បើតាមការស្រាវជ្រាវរបស់លោក? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកមិនទាន់អាចឆ្លើយនឹងសំណួរនេះបានទេ ។ បន្ទាប់មកលោកព្រះរាជអាជ្ញារងបានសួរថា តើលោកសាស្ត្រាចារ្យបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនកម្មាភិបាលឈ្មោះ សឿ វ៉ាស៊ី ហៅ ខឿន នៅដើមឆ្នាំ១៩៧៧ដែរឬទេ? លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមិនអាចសន្និដ្ឋានបានទេថា ហេតុអ្វីបានជានាំឲ្យមានការចាប់ខ្លួនឈ្មោះ ខឿន ប៉ុន្តែនៅក្នុងសៀវភៅរបស់លោក លោកបានសរសេរថា អ្នកទោសដែលត្រូវបាននាំចូលស-២១ គឺជាកម្មាភិបាលជាន់ខ្ពស់មួយរូប ហើយបន្ទាប់ពីការចាប់ខ្លួន ដំណែងរបស់កម្មាភិបាលរូបនោះត្រូវបានជំនួសដោយ ខៀវ សំផន ។ ការចាប់

ខ្លួននេះ គឺដោយសារតែកម្មាភិបាលរូបនោះមានជាប់ខ្សែក្សែត់ កុយ ធួន ដូច្នេះលោកគិតថា ការចាប់ខ្លួននោះ គឺបណ្ដាលមកពី ខឿន ជាប់ខ្សែក្សែត់ជាមួយ កុយ ធួន ។ ការឆ្លើយរបស់លោកសាស្ត្រាចារ្យ នៅត្រង់ចំណុចនេះត្រូវបានមេធាវីអន្តរជាតិការពារក្តី អៀង សារី គឺលោក កាណាវ៉ាស បានធ្វើការជំទាស់ដោយអះអាងថា អ្នកជំនាញ ប្រើប្រាស់ពាក្យថា *"លោកគិតថា"* ពាក្យនេះគឺជាពាក្យដែល មិនមានភាពប្រាកដប្រជា ហើយសំណួរដែលសហព្រះរាជអាជ្ញា បានសួរគឺជាសំណួរជាក់លាក់ ។ ដូច្នេះអ្នកជំនាញគប្បីឆ្លើយនូវ ចម្លើយភាពជាក់លាក់ ។ ប៉ុន្តែលោកសាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយតបនឹងការលើកឡើងរបស់លោកមេធាវី កាណាវ៉ាស ថា លោកប្រើពាក្យ*"គិតថា"* គឺដោយសារលោកមិនបានដឹងច្បាស់ថា មានអ្វីកើតឡើងពិតប្រាកដនៅទីនោះទេ ប៉ុន្តែអ្វីដែលលោក លើកឡើង គឺផ្អែកលើឯកសារដែលលោកបានធ្វើការសិក្សាស្រាវជ្រាវ ។ ដើម្បីដោះស្រាយបញ្ហានេះ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានសម្រេចថា ការលើកឡើងរបស់លោកមេធាវី កាណាវ៉ាស អាចទទួលយកបាន ប៉ុន្តែអ្វីដែលអ្នកជំនាញបាន លើកឡើង គឺដោយសារលោកយោងលើឯកសារដែលលោក បានសិក្សា ។ លោកស្រីគ្រាន់តែស្នើឲ្យអ្នកជំនាញសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់ឲ្យបានច្បាស់ថា តើអ្វីដែលលោកបានអះអាង គឺដកស្រង់ចេញពីចម្លើយសារភាព ឬឯកសារដែលលោកបាន ធ្វើការសិក្សា ដោយសារចម្លើយសារភាពដែលស្ថិតក្រោម ការធ្វើទារុណកម្ម ដូចជាចម្លើយសារភាពនៅស-២១ មិនត្រូវបាន អនុញ្ញាតឲ្យយកមកប្រើប្រាស់នៅក្នុងតុលាការទេ ។

បន្ទាប់មក លោកសហព្រះរាជអាជ្ញារងបានបន្តសួរសំណួរ លោកសាស្ត្រាចារ្យ ថាតើនរណាឡើងកាន់ដំណែងជំនួស ខឿន បន្ទាប់ពី ខឿន ត្រូវបានចាប់ខ្លួន? លោកសាស្ត្រាចារ្យបានអះអាងថា គឺជនជាប់ចោទ ខៀវ សំផន ។ លោកបានបន្ថែមថា ប្រភពព័ត៌មាន ទាក់ទងនឹងបញ្ហានេះ គឺមាននៅក្នុងកំណត់សម្គាល់ជើងទំព័រ(Footnote) ទី៦៧នៃសៀវភៅរបស់លោកដែលមានចំណងជើងថាសំឡេងពីមន្ទីរស-២១ ។ បន្ទាប់ពីលោកសហព្រះរាជអាជ្ញារងជាតិ ចាន់តារាវស្មី បានបញ្ចប់ការសួរដេញដោល អង្គជំនុំជម្រះបានប្រគល់វេទិកាជូន លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ថារីក អាប់ឌុលហាក់ (Tarik Abdulhak) ដើម្បីបន្តធ្វើការសាកសួរ ។

## ២.១) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

### *២.១.១) ភាពខុសគ្នារវាងពាក្យ "មជ្ឈិមបក្ស" និង "ក្បាលម៉ាស៊ីន"*

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ថារីក អាប់ឌុលហាក់ ចាប់ផ្ដើមសំណួរដំបូងទាក់ទងនឹងសៀវភៅរបស់ លោកសាស្ត្រាចារ្យ សំឡេងចេញពីមន្ទីរស-២១ ដោយស្នើឲ្យ លោកធ្វើការពន្យល់ពាក់ព័ន្ធនឹងអត្ថន័យនៃពាក្យថា "មជ្ឈិមបក្ស" និងថា តើពាក្យថា "មជ្ឈិមបក្ស" មានអត្ថន័យខុសគ្នានឹងពាក្យថា "ក្បាលម៉ាស៊ីន" យ៉ាងដូចម្ដេច? លោកបានបញ្ជាក់ថា មជ្ឈិមបក្ស គឺសំដៅលើគណៈកម្មាធិការមជ្ឈិម រីឯពាក្យថា ក្បាលម៉ាស៊ីន មិនមែនជាឈ្មោះដែលគេប្រើប្រាស់ជាផ្លូវការនោះទេ គឺគ្រាន់ តែជាយន្តការមួយតែប៉ុណ្ណោះ ។ បន្ទាប់មកលោកតំណាងសហ ព្រះរាជអាជ្ញា ថារីក បានបន្តសួរទៀតថា តើលោកសាស្ត្រាចារ្យ ចាត់ទុកជនជាប់ចោទទាំងបីរូប រួមមាន នួន ជា អៀង សារី និងខៀវ



តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ដុលហាក់

សំផន ស្ថិតនៅក្នុងគណៈមជ្ឈិមបក្សដែរឬទេ? លោកសាស្ត្រាចារ្យ បានបញ្ជាក់ថា ជនជាប់ចោទទាំងបីរូបពិតជាស្ថិតនៅក្នុងគណៈ មជ្ឈិមបក្ស ហើយក្នុងនោះក៏នៅមានអ្នកដទៃផ្សេងទៀតដែរ ។ ឆ្លើយតបសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹង ទំនាក់ទំនងរវាងមជ្ឈិមបក្ស និងស-២១ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ស-២១ និងមជ្ឈិមបក្ស គឺមានទំនាក់ទំនង

នឹងគ្នាយ៉ាងជិតស្និទ ដោយយោងលើសម្តីរបស់ ឌុច ដែលនិយាយថា ខ្លួនបានរាយការណ៍ជូន សុន សេន ដែលជាថ្នាក់លើរបស់ខ្លួន និងជាសមាជិកសំខាន់មួយរូបនៃគណៈមជ្ឈិម ។ ហេតុនេះគណៈមជ្ឈិមអាចដឹងពីដំណើរការនៅស-២១ ។ លោកបានបន្ថែមថា មន្ទីរ ស-២១ មិនមែនជាផ្នែកនៃគណៈមជ្ឈិមទេ គឺគ្រាន់តែមានតួនាទីរាយការណ៍ជូនសមាជិកសំខាន់មួយរូបនៃគណៈអចិន្ត្រៃយ៍ប៉ុណ្ណោះ ។

### ២.១.២) អ្នកគ្រប់គ្រងមន្ទីរ៨៧០

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការផ្លាស់ប្តូរអ្នកគ្រប់គ្រងនៅមន្ទីរ៨៧០ លោកសាស្ត្រាចារ្យបានពន្យល់ថា គឺពិតជាមានការផ្លាស់ប្តូរពី ឌឿន ទៅ ខៀវ សំផន ហើយព័ត៌មាននៃការផ្លាស់ប្តូរនេះមិនមែនជាការសម្ងាត់ទេ គឺមាននៅក្នុងឯកសារសាធារណៈ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាដែលបានសួរពាក់ព័ន្ធនឹងតួនាទីរបស់ប្រធានមន្ទីរ៨៧០ លោកសាស្ត្រាចារ្យបញ្ជាក់ថា លោកបានដឹងព័ត៌មាននេះតាមរយៈការអានដីកាដំណោះស្រាយ មិនមែនតាមការស្រាវជ្រាវរបស់លោកទេ ។ មន្ទីរ៨៧០ គឺគ្រាន់តែជាលេខកូដរបស់ ប៉ុល ពត តែប៉ុណ្ណោះ ប៉ុន្តែមន្ទីរនេះមាននាទីចាត់ចែងក្រដាសស្នាមចេញចូលនៅមជ្ឈិមបក្ស ។ លោកបន្ថែមថា ប្រធានមន្ទីរ៨៧០នេះអាចជា ឌឿន ឬ ខៀវ សំផន ប៉ុន្តែអ្នកដឹកនាំ៨៧០គឺសំដៅលើ ប៉ុល ពត ដែលអាចនាំឲ្យមានការភាន់ច្រឡំ ហើយនេះក៏ជាបញ្ហាមួយដើម្បីកំណត់ពីនិយមន័យរបស់មន្ទីរ៨៧០នេះដែរ ។ ភ្លាមៗបន្ទាប់ពីការឆ្លើយសំណួររបស់លោកសាស្ត្រាចារ្យ មេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុម បានធ្វើការជំទាស់នឹងការលើកឡើងរបស់អ្នកជំនាញដែលអះអាងថា លោកបានអានដីកាដំណោះស្រាយទាក់ទងនឹងមន្ទីរ៨៧០ ដោយមេធាវីការពារក្តីទាំងអស់លើកឡើងថា ការណ៍ដែលអ្នកជំនាញអានដីកាដំណោះស្រាយដែលមានការសន្និដ្ឋានរួចហើយពីសំណាក់សហចៅក្រមស៊ើបគឺជារឿងដែលមិនអាចទទួលយកបាន ។ ដោយសារការអះអាងរបស់លោកសាស្ត្រាចារ្យមិនមែនជាការសន្និដ្ឋានផ្ទាល់របស់លោក ប៉ុន្តែគឺជាសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ។ មេធាវីការពារក្តីទាំងបីក្រុមស្នើឲ្យអ្នកជំនាញបង្ហាញពីឯកសារយោង ដែលលោកបានឃើញនៅក្នុងដីកាដំណោះស្រាយ ហើយយកមកធ្វើការសន្និដ្ឋាន ។ លោកប្រធានចៅក្រម និល ណុន បានដោះស្រាយបញ្ហានេះ ដោយស្នើឲ្យអ្នកជំនាញបង្ហាញពីកំណត់សម្គាល់ជើងទំព័រនៃដីកាដំណោះស្រាយ ប្រសិនបើលោកសាស្ត្រាចារ្យអាចធ្វើការបង្ហាញជូនអង្គជំនុំជម្រះបាន ។ ប៉ុន្តែបើលោកសាស្ត្រាចារ្យមិនអាចបង្ហាញឯកសារយោង ដែលលោកបានយកមកធ្វើការសន្និដ្ឋានបានទេ លោកប្រធានចៅក្រមស្នើឲ្យក្រុមមេធាវីការពារក្តីអាចធ្វើការកត់សម្គាល់ ដោយរង់ចាំរហូតដល់វេទិកាសួរសំណួររបស់ខ្លួនដើម្បីសួរទៅលោកសាស្ត្រាចារ្យ ។

### ២.១.៣) មហាសន្និបាតបក្សឆ្នាំ១៩៦០ និង១៩៦២

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ដែលជាថ្ងៃទី២នៃសវនាការ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរសំណួរលោកសាស្ត្រាចារ្យដោយផ្តោតជាសំខាន់លើសៀវភៅចំនួនពីរក្បាល ដែលមានចំណងជើងថា "បងធំទីមួយ" និង "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ទាក់ទងនឹងមហាសន្និបាតឆ្នាំ១៩៦០របស់បក្ស ។ លោកតំណាងសហព្រះរាជអាជ្ញាបានស្នើលោកសាស្ត្រាចារ្យឲ្យបញ្ជាក់អំពីការផ្លាស់ប្តូរឈ្មោះបក្សពី "បក្សប្រជាជនបដិវត្តកម្ពុជា" មកជា "បក្សពលករខ្មែរ" និងការ



(រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តែងតាំងសមាជិកថ្មីនៅក្នុងគណៈកម្មាមជ្ឈិម រួមមាន ប៉ុល ពត អៀង សារី និងកុយ ធួន ដែលធ្វើឡើងនៅអំឡុងពេលនៃមហាសន្និបាតនាពេលនោះ ។ ឆ្លើយតបសំណើរបស់សហព្រះរាជអាជ្ញា

លោកសាស្ត្រាចារ្យបានបញ្ជាក់ថា មហាសន្និបាតបក្សឆ្នាំ១៩៦០ គឺជាកាលបរិច្ឆេទដែលត្រូវបានចាត់ទុកថាជាការចាប់ផ្តើមនៃបក្សកុម្មុយនីស្តកម្ពុជា ដែលតាមការពិតដើមកំណើតពិតប្រាកដរបស់បក្ស គឺចាប់ផ្តើមនៅឆ្នាំ១៩៥១ ។ លោកបន្តថា អំឡុងពេលនៃមហាសន្និបាតនោះ ប៉ុល ពត អៀង សារី និង កុយ ធួន ត្រូវបានតែងតាំងជាសមាជិកនៃគណៈកម្មាធិការ ហើយមហាសន្និបាតនេះបានប្រែក្លាយកម្ពុជាមិនឲ្យស្ថិតនៅក្រោមប្រទេសវៀតណាម និងបក្សកុម្មុយនីស្តវៀតណាម ។ លោក ថារីក បានបន្តអានផ្នែកមួយនៃសៀវភៅ«បងធំទី១» និង«សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា» ជូនលោកសាស្ត្រាចារ្យ និងបានស្នើឲ្យលោកធ្វើការពន្យល់អំពីផ្នែកនោះ ដែលទាក់ទងនឹងសារៈសំខាន់នៃមហាសន្និបាតរបស់បក្សនៅឆ្នាំ១៩៦២ ក្រោយការបាត់ខ្លួន ទូ សាមុត និងទាក់ទងនឹងការដាក់បញ្ចូលសមាជិកថ្មីបន្ថែម រួមមាន សាឡុត ស, នួន ជា, ទូ សាមុត ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ប៉ុល ពត, អៀង សារី, នួន ជា, និង សុន សេន គឺជាក្រុមមេដឹកនាំស្នូល ប៉ុន្តែមិនអាចនិយាយថា ជាក្រុមដែលមកពីប្រទេសបារាំងទេ ដោយសារ នួន ជា មិនដែលធ្លាប់បានទៅប្រទេសបារាំងម្តងណាឡើយ ។ អ្នកទាំងបួននាក់បានក្លាយជាមេដឹកនាំសំខាន់រហូតដល់ពេលចូលកាន់អំណាច ។ ទាក់ទងនឹងសារៈសំខាន់មហាសន្និបាត លោកបានពន្យល់ថា មហាសន្និបាតនៅពេលនោះ គឺមានសារៈសំខាន់សម្រាប់អ្នកដែលចង់ចូលកាន់កាប់អំណាច ដោយលោកភ្ជាប់អ្នកទាំងនោះនឹងក្រុមសុទិដ្ឋិនិយមដែលអង្គុយនៅក្នុងបន្ទប់មួយដែលហ៊ុំព័ទ្ធដោយមនុស្សទាំងឡាយ ដែលមិនមានការរំពឹងទុកថាអ្វីៗនៅពេលនោះនឹងអាចកើតឡើង ។

## ២.១.៤) ការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់បក្សកុម្មុនីស្តកម្ពុជា

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់អំពីការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សដោយបញ្ជូនសមាជិកឲ្យធ្វើការនៅភូមិភាគឦសានការផ្លាស់ប្តូរឈ្មោះបក្ស និងការធ្វើផ្លាស់ប្តូរបុគ្គលសំខាន់ៗ ។ លោកសាស្ត្រាចារ្យបានពន្យល់ដោយយោងលើព្រឹត្តិការណ៍ឆ្នាំ១៩៦៥-១៩៦៦ ក្នុងប្រទេសឥណ្ឌូនេស៊ី ដែលមានការកាប់សម្លាប់ប្រជាជនជិតកន្លះលាននាក់ពីសំណាក់រដ្ឋាភិបាលដោយសារតែអ្នកទាំងនោះត្រូវបានគេចោទថាជាក្រុមគាំទ្រលទ្ធិកុម្មុយនីស្ត ។ ដោយមើលឃើញពីព្រឹត្តិការណ៍នេះ បក្សកុម្មុយនីស្តកម្ពុជាមានការព្រួយបារម្ភ និងបានស្វែងរកកន្លែងដែលមានសុវត្ថិភាព ហើយនៅឆ្ងាយពីតំបន់ដែលមានប្រជាជនរស់នៅ ។ លោកសាស្ត្រាចារ្យបានបន្ថែមថា បក្សកុម្មុយនីស្តបានដាក់មូលដ្ឋាននៅទីនោះរយៈបីឆ្នាំ ដើម្បីរៀបចំផែនការពង្រឹងបក្ស និងធ្វើឲ្យមានសាមគ្គីភាព តាមរយៈការជ្រើសរើសសមាជិកថ្មីៗដែលជាជនជាតិភាគតិច ។

## ២.១.៥) ដើមកំណើតនៃសង្គ្រាមស៊ីវិលនៅកម្ពុជា

លោកតំណាងសហព្រះរាជអាជ្ញា បានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់បន្ថែមទាក់ទងនឹងព្រឹត្តិការណ៍បះបោរនៅសំឡូតក្នុងឆ្នាំ១៩៦៧ និងការប៉ះទង្គិចនៅក្នុងឆ្នាំ១៩៦៨ ដែលត្រូវបានចាត់ទុកថាជាដើមកំណើតនៃការតស៊ូប្រដាប់អាវុធដែលលោកសាស្ត្រាចារ្យបានសរសេរនៅក្នុងសៀវភៅរបស់លោក ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ទោះបីជាមានការបះបោរនៅសំឡូត និងមានការដណ្តើមយកអាវុធនៅពេលនោះពីសំណាក់អ្នកបះបោរក៏ដោយ ព្រឹត្តិការណ៍នោះមិនមានការជាប់ពាក់ព័ន្ធនឹងបក្សកុម្មុយនីស្តទេ ការបះបោរនាពេលនោះគឺផ្តើមចេញពីការមិនពេញចិត្តរបស់បុគ្គលម្នាក់ៗជាមួយនឹងការគ្រប់គ្រងរបស់រដ្ឋាភិបាល ។ ការតស៊ូប្រដាប់អាវុធនៅក្នុងឆ្នាំ១៩៦៨ គឺកើតចេញពីសេចក្តីសម្រេចរបស់ ប៉ុល ពត ដែលយល់ថា ប្រសិនបើមិនមានការតស៊ូប្រដាប់អាវុធ ចលនារបស់ខ្លួននឹងមិនអាចដើរទៅមុខបានឡើយ ។ លោកសាស្ត្រាចារ្យបានបន្ថែមថា ការតស៊ូប្រដាប់អាវុធនៅពេលនោះបានក្លាយជាការចាប់ផ្តើមនៃសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាប្រឆាំងនឹងរដ្ឋាភិបាលសម្តេចសីហនុ និងរដ្ឋាភិបាល លន់ នល់ នៅពេលបន្ទាប់ ។

## ២.១.៦) ការបង្កើតរណសិរ្សសង្គ្រោះជាតិកម្ពុជា

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការពន្យល់ទាក់ទងនឹងសៀវភៅ«បងធំទីមួយ»ត្រង់ជំពូកទី៦ ដែលនិយាយអំពីព្រឹត្តិការណ៍ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ការបង្កើតរណសិរ្ស និងការដឹកនាំរណសិរ្សរបស់សម្តេចសីហនុ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា

ក្រោយរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ នៅឆ្នាំ១៩៧០ សម្តេច សីហនុ ទ្រង់មានការភ្ញាក់ផ្អើល និងបានដេរប្រមាថចំពោះ អំពើរដ្ឋប្រហារនោះ ដោយទ្រង់បានយាងទៅទីក្រុង ប៉េកាំង ដើម្បីពិភាក្សាជាមួយ លោក ជូ អេនឡាយ រកមធ្យោបាយក្នុងការវាយបកចំពោះកងទ័ពរបស់លោកសេនាប្រមុខ លន់ នល់ ។ ភ្លាមៗក្រោយពីរដ្ឋប្រហារ ប៉ុល ពត បានចាកចេញពីទីក្រុង ហាណូយ ឆ្ពោះទៅកាន់ទីក្រុង ប៉េកាំង ដើម្បីជួបសម្តេចសីហនុ ប៉ុន្តែលោកសាស្ត្រាចារ្យមិនបានដឹងថា ប៉ុល ពត ទៅទីនោះពិភាក្សាពីអ្វីឡើយ ។ ក្រោយពីការបង្កើតរណសិរ្ស ប៉ុល ពត មិនបានចេញមុខទេ ដោយទុកការកិច្ចដឹកនាំរណសិរ្សជូនសម្តេច សីហនុ ដើម្បីធ្វើឲ្យរណសិរ្សនោះមានកិត្យានុភាព ព្រោះព្រះអង្គ គឺជានិមិត្តរូបនៃប្រជាជនកម្ពុជា ។ ព្រះអង្គបានចាត់ទុកអ្នកដែលពាក់ព័ន្ធនឹងរដ្ឋប្រហារ គឺជាជនក្បត់ ។ លោកសាស្ត្រាចារ្យបានបន្ថែមថា អំឡុងពេលនៃការបង្កើតរណសិរ្ស គឺជាពេលវេលាមួយដែលគួរឲ្យចាប់អារម្មណ៍បំផុត ព្រោះសម្តេច សីហនុ បានចេញមុខជាសាធារណៈដើម្បីដឹកនាំរណសិរ្ស ហើយព្រះអង្គបានប្រាប់អ្នកកាសែតថា *"នៅពេលវេលាមកដល់ ពួកគេនឹងស្តោះខ្ញុំចេញក្រៅដូចជាគ្រាប់ផ្លែឈើរី"* ។ លោកសាស្ត្រាចារ្យអះអាងទៀតថា សម្តេច សីហនុ មិនបាននៅជាប់ជាមួយនឹង អៀង សារី ទេ ហើយព្រះអង្គក៏មិនបានដឹងអំពីកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ ខ្មោចទាំងបី(ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម) បានចាត់ចែងកិច្ចការទាំងអស់ជំនួសព្រះអង្គ ហើយព្រះអង្គមិនដឹងពីគោលនយោបាយដែលបានរៀបចំចែងចាត់ជាសម្ងាត់ដោយបក្សកុម្មុយនីស្តឡើយ ។

## ២.១.៧) ការតស៊ូវណ្ណៈ

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការតស៊ូអំពីវណ្ណៈ ដែលបក្សមានគោលនយោបាយក្នុងការជ្រើសរើសសមាជិកបក្សចេញពីវណ្ណៈកសិករ វណ្ណៈក្រក្រី ដែលត្រូវបានប្រៀបប្រដូចនឹងការរើសយកគ្រាប់ពេជ្រចេញពីក្នុងដី ដោយជៀសវាងការជ្រើសរើសសមាជិកចេញពីវណ្ណៈអភិជន ។ សាស្ត្រា ចារ្យ ឆេនដល័រ បានពន្យល់ថា បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយជ្រើសរើសសមាជិកចេញពីវណ្ណៈ ដែលគិតថាខ្លួនជាអ្នករងគ្រោះដោយសាររបប លន់ នល់ ដើម្បីធ្វើការប្រឆាំង ។

## ២.១.៨) ទស្សនបដិវត្តកម្ពុជាក្នុងការផ្តួលរំលំពួកសក្តិភូមិនិយម និង ចក្រពត្តិនិយម

លោក ថារីក បានបន្តស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់អំពីអត្ថន័យនៃពាក្យទស្សនបដិវត្តកម្ពុជាក្នុងការផ្តួលរំលំពួកសក្តិភូមិនិយម និងចក្រពត្តិនិយម ថាតើមានសារៈសំខាន់បែបណាសម្រាប់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ? លោកសាស្ត្រាចារ្យបានអះអាងថា នៅក្នុងកិច្ចប្រជុំក្នុងខែកក្កដា ឆ្នាំ១៩៧១ បក្សបានបញ្ជាក់ប្រាប់សមាជិករបស់ខ្លួនថា "យើងកំពុងឈានដល់ដំណាក់កាលថ្មីដែលអាចផ្តួលរំលំពួកសក្តិភូមិនិយម និងចក្រពត្តិនិយមនៅក្នុងពេលឆាប់ៗ" ។ លោកបានបន្តទៀតថា ពួកចក្រពត្តិនិយមគឺសំដៅលើអាមេរិក រីឯសក្តិភូមិនិយម គឺសំដៅលើពួកអ្នកមាន ។ បក្សបានរៀបចំផែនការធ្វើសង្គ្រាមប្រឆាំងនឹងក្រុមសង្គមចាស់ និងសហរដ្ឋអាមេរិក និងថា កិច្ចប្រជុំរបស់បក្សនាពេលនោះ គឺជាកិច្ចប្រជុំប្រកបដោយសេចក្តីសម្រេច និងជាកិច្ចប្រជុំដែលជូនដំណឹងដល់សមាជិករបស់ខ្លួនអំពីកន្លែងដែលបក្សនឹងត្រូវធ្វើដំណើរទៅ ។

## ២.១.៩) គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥

លោកតំណាងសហព្រះរាជអាជ្ញា បានបន្តសួរលោកសាស្ត្រាចារ្យទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការបង្កើតសហករណ៍ ដោយលោកអានឃ្លាមួយដែលមាននៅក្នុងសៀវភៅ "បងធំទីមួយ" និង "សោកនាកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ជូនលោកសាស្ត្រាចារ្យ និងស្នើសុំឲ្យលោកធ្វើការពន្យល់ ។ ឃ្លាមួយនៃសៀវភៅ បងធំទីមួយ បានសរសេរថា៖

> *"នៅដើមឆ្នាំ១៩៧៣ កងទ័ពកុម្មុយនីស្តកម្ពុជាបានវាយប្រហារកងទ័ពរដ្ឋាភិបាលដើម្បីពង្រីកការគ្រប់គ្រងទឹកដី និងដើម្បីដាក់ចេញនូវកម្មវិធីសង្គម ។ ដំណើរការនេះត្រូវបានតាមដានយ៉ាងជាប់លាប់នៅភូមិភាគនិរតី ភាគច្រើននៃការអនុវត្តនៅទីនោះរួមមានការបង្កើតសហករណ៍កសិកម្ម ការជម្លៀសប្រជាជនដោយបង្ខំ ការ*

*បង្ក្រាបអ្នកកាន់ព្រះពុទ្ធសាសនា ការបង្កើតក្រុមយុវជន ការដកកុមារចេញពីក្រុមគ្រួសារ ការដាក់វិន័យទាក់ទងនឹងការស្លៀកពាក់ ដោយត្រូវស្លៀកសំលៀកបំពាក់ជាកសិករ ត្រូវពាក់ខោខ្មៅ អាវខ្មៅ គ្រប់ពេលវេលា ។ ដោយសារការអនុវត្តគោលនយោបាយដ៏ធ្ងន់ធ្ងរនេះ មានប្រជាជនជាងពីរម៉ឺននាក់បានគេចខ្លួនទៅជ្រកនៅវៀតណាមខាងត្បូង ។ គោលនយោបាយនេះចេញមកពីសេចក្តីសម្រេចរបស់សាឡុតស នៅក្នុងវគ្គសិក្សាមួយក្នុងឆ្នាំ១៩៧១ ។ សេចក្តីសម្រេចនេះត្រូវបានអនុម័ត និងបង្គាប់ឲ្យអនុវត្តទូទាំងប្រទេសក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាមួយនឹងបទបញ្ជាយ៉ាងដាច់ខាត ដូចជា ការលុបបំបាត់រូបិយប័ណ្ណ ទីផ្សារ និងសាលារៀន និងការជម្លៀសទូទាំងទីក្រុង និងទីប្រជុំជន ។»*


ប្រជាជនកំពុងធ្វើការនៅការដ្ឋាន
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីអានផ្នែកដកស្រង់នៃសៀវភៅ បងធំទី១ លោកតំណាងសហព្រះរាជអាជ្ញាបានសួរលោកសាស្ត្រាចារ្យអំពីការអនុវត្តជាក់ស្តែងរបស់បក្សកុម្មុយនីស្តទាក់ទងនឹងសេចក្តីសម្រេចនេះ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា តាមការពិតព័ត៌មានអំពីការអនុវត្តគោលនយោបាយនេះនៅក្នុងភូមិភាគនិរតីមិនត្រូវបានរកឃើញនៅក្នុងការស្រាវជ្រាវរបស់លោកនោះទេ ប៉ុន្តែដំណឹងនោះត្រូវបានផ្សព្វផ្សាយដោយបុគ្គលិកស្ថានទូតអាមេរិកមួយរូប គឺលោក កេនណែត គ្វីន (Kenneth Quinn) ដែលក្រោយមកក្លាយជាឯកអគ្គរដ្ឋទូតនៅក្នុងកម្ពុជា ដែលបានស្នាក់នៅ និងធ្វើការនៅជិតព្រំដែនកម្ពុជា និងវៀតណាម ហើយបានឃើញផ្សែងចេញពីតំបន់ដែលខ្មែរក្រហមព្យាយាមចូលកាន់កាប់ ។ លោកបន្ថែមថា ចាប់ពីពេលដែលខ្មែរក្រហមចូលកាន់កាប់ភូមិភាគនិរតី តំបន់នោះបានក្លាយទៅជាតំបន់មួយដ៏រឹងមាំ និងដ៏ស្មោះស្ម័គ្រ ដែលគ្រប់គ្រងដោយ តាម៉ុក នៅក្នុងខេត្តតាកែវ ។ ទាក់ទងនឹងសារៈសំខាន់នៃគោលនយោបាយនេះ លោកសាស្ត្រាចារ្យបានអះអាងថា ក្រុមខ្មែរក្រហមមានការអន្ទះអន្ទែងក្នុងការអនុវត្តដោយមិនចំណាយពេលធ្វើពិសោធន៍សាកល្បងថា តើការអនុវត្តទទួលបានជោគជ័យ ឬយ៉ាងណានោះទេ ដោយសារខ្មែរក្រហមមិនដែលគិតពីភាពបរាជ័យនោះទេ ។

### ២.១.១០) ការអនុវត្តគោលនយោបាយជម្លៀសប្រជាជនរបស់បក្សកុម្មុយនីស្តកម្ពុជា

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តសួរទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនដោយលើកឡើងផ្នែកមួយនៃសៀវភៅ«បងធំទី១» និង«*សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា*»ហើយស្នើសុំឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ឆ្លើយតបនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញា លោកសាស្ត្រាចារ្យបានពន្យល់ថា ការជម្លៀសប្រជាជនគឺជារឿងដែលមិនធ្លាប់កើតមាននៅកម្ពុជា ហើយការជម្លៀសនេះបានក្លាយជារឿងដែលសំខាន់ ដែលអ្នកសង្កេតតាមដានសភាពការណ៍នៅពេលនោះបាននាំគ្នាលើកឡើងពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ លោកបានបន្តថា ដោយផ្អែកលើឯកសារដែលរកឃើញក្រោយៗមកទៀត ការជម្លៀសប្រជាជនគឺជាផែនការត្រូវបានគិតទុកជាមុន នៅពេលចូល មកដល់ខេត្ត តាកែវ នៅក្រចេះ ស្ទឹងត្រែង និងនៅឧត្តុង្គ ហើយការជម្លៀសធំបំផុតគឺធ្វើឡើងនៅទីក្រុងភ្នំពេញ ។ ពាក់ព័ន្ធនឹងគោលនយោបាយដណ្តើមប្រជាជនដែលមានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ត្រូវបានតំណាងសហព្រះរាជអាជ្ញាស្នើសុំលោកសាស្ត្រាចារ្យធ្វើការបកស្រាយអំពីទស្សនៈនៃគោល

នយោបាយនោះ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា គោលនយោបាយជម្លៀសប្រជាជននេះ គឺជាគោលនយោបាយមួយ ដែលធ្លាប់បានប្រើនៅក្រោយសម័យអាណានិគម ដោយទាហានថៃធ្លាប់បានប្រើយុទ្ធសាស្ត្រនេះ នៅពេលដែលថៃបានឈ្លានពានចូលមកក្នុងទឹកដីកម្ពុជានៅក្នុងឆ្នាំ១៨៨៣ ។ លោកបន្តថា ថៃចូលមកបោសសម្អាតទីក្រុងភ្នំពេញ ដើម្បីកុំឲ្យមានអ្នកកងទ័ពធ្វើសកម្មភាពវាយបក ហើយសកម្មភាពនេះត្រូវបានបក្សកុម្មុយនីស្តកម្ពុជាយកមកអនុវត្តនៅក្នុងគោលនយោបាយរបស់ខ្លួន ។

ឆ្លើយតបនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញា ដែលស្នើសុំការពន្យល់ទាក់ទងនឹងសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញរបស់បក្សកុម្មុយនីស្តកម្ពុជា លោកសាស្ត្រាចារ្យបានបកស្រាយថា លោកគិតថាសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺធ្វើឡើងនៅដើមឆ្នាំ១៩៧៥ ។ លោកបានបន្តថា ប្រជាជនដែលរស់នៅទីក្រុងត្រូវបានចាត់ទុកថាជាខ្មាំង ។



ទិដ្ឋភាពនៃការជម្លៀសប្រជាជននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាក់ទងនឹងពាក្យថា «ប្រជាជនថ្មី» និង«ប្រជាជនមូលដ្ឋាន» ត្រូវបានលោកសាស្ត្រាចារ្យពន្យល់ថា អ្នកដែលត្រូវបានជម្លៀសត្រូវបានចាត់ទុកថាជាប្រជាជនថ្មី ឬប្រជាជន១៧មេសា ដោយសារអ្នកទាំងនោះមិនបានចូលរួមជាមួយនឹងបដិវត្ត ហើយប្រជាជនដែលរស់នៅផ្ទាល់នៅតាមទីជនបទត្រូវបានហៅថា ប្រជាជនមូលដ្ឋាន ដែលមិនសូវទទួលរងការធ្វើបាបដូចជាអ្នកដទៃឡើយ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរអំពីឃ្លាមួយទៀតនៃសៀវភៅ *សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា* របស់លោកសាស្ត្រាចារ្យដែលសរសេរថា *«ប្រជាជន ១៧មេសា ត្រូវបានដាក់ទោស ឬសម្លាប់ចោល ដោយសារបានប្រព្រឹត្តអំពើដែលគេគិតថានាំឲ្យមានការអន្តរាយ»* ដូចជាការនិយាយពីការពិតទាក់ទងនឹងប្រវត្តិរូបផ្ទាល់ខ្លួន និងការត្អូញត្អែរអំពីលក្ខខណ្ឌការងារ ។ លោកសាស្ត្រាចារ្យបានពន្យល់នៅត្រង់ចំណុចនេះថា ការកំណត់ថា នរណាជាប្រជាជនថ្មី និងនរណាជាប្រជាជនមូលដ្ឋាន គឺដើម្បីកំណត់ថានរណាជា «ពួកយើង» និង «ពួកគេ» នរណាជា «អ្នកឈ្នះ» និង«នរណាជាអ្នកចាញ់» ហើយមនុស្សគ្រប់គ្នាសុទ្ធតែដឹងថាប្រជាជនថ្មីត្រូវបានតាមដាន ។ លោកបន្តថា ក្រុមខ្មែរក្រហមចង់ធ្វើការអប់រំប្រជាជនថ្មីឡើងវិញ ដោយតម្រូវឲ្យធ្វើការយ៉ាងលំបាកលំបិនដើម្បីឲ្យក្លាយជាមនុស្សបរិសុទ្ធ ប៉ុន្តែប្រសិននរណាម្នាក់ត្រូវបានអប់រំចំនួនបីដងហើយនៅតែមិនអាចកែប្រែបាន វាសនាអ្នកទាំងនោះនឹងត្រូវបញ្ចប់ ។

តំណាងសហព្រះរាជអាជ្ញាបានបន្តស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់ទាក់ទងនឹងការចាត់ចំណាត់ថ្នាក់ប្រជាជន ដោយផ្តោតលើការចាត់ទុកប្រជាជនថ្មីថាជា «បញ្ញើរក្អែក» ។ លោកសាស្ត្រាចារ្យ

ឆេនដល័រ បានបញ្ជាក់ថា លោកមិនច្បាស់ថាការបែងចែកប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន បានរីករាលដាលដោយរបៀប ណានោះទេ ប៉ុន្តែការបែងចែកនេះ គឺធ្វើឡើងដើម្បីបំបែកប្រជាជនមិនស្អាតស្អំ ចេញពីប្រជាជនស្អាតស្អំ តាមរយៈការពង្រីងប្រជាជនទាំងនោះ ចេញពីទីក្រុង បន្ទាប់មកធ្វើការតាមដានប្រជាជនថ្មី ។ ប៉ុន្តែការ ចាត់ចំណាត់ថ្នាក់ប្រជាជន ត្រូវបានដកចេញវិញដោយបក្សនៅ ក្នុងឆ្នាំ១៩៧៨ ។

## ២.៩.១១) ផែនការបួនឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរ ទាក់ទងនឹងផែនការបួនឆ្នាំរបស់ ប៉ុល ពត ដែលមាននៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា" ដោយស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនល័រ ធ្វើការបញ្ជាក់អំពីសេចក្តីសន្និដ្ឋានទាក់ទងនឹងការប្រញាប់ ប្រញាល់ក្នុងការបង្កើតផែនការ និងការតម្រូវឲ្យមានការវាយ សម្រុកដោយប្រជាជនដើម្បីធ្វើឲ្យសម្រេចផែនការ ។ លោសាស្ត្រា ចារ្យ ឆេនដល័រ បានបញ្ជាក់ថា ផែនការបានកំណត់ដូចជា គោល នយោបាយផ្សេងៗទៀតដែរ គឺផ្អែកលើការសន្និដ្ឋាន ដោយមិន មានការពិនិត្យមើលអំពីលទ្ធភាព និងសមត្ថភាពដែលត្រូវយកទៅ អនុវត្តនោះទេ ។ ផែនការបួនឆ្នាំដែលមានការតម្រូវឲ្យធ្វើស្រែ ដើម្បីទទួលបានទន្និផលស្រូវ៣តោនក្នុង១ហិចតា គឺជាផែនការ ដែលអាចយកតាមគំរូរបស់ប្រទេសចិនដែលធ្លាប់ធ្វើនៅក្នុងឆ្នាំ ១៩៧១ ដូចជា ពាក្យ"មហាលោតផ្លោះ មហាអស្ចារ្យ"ជាដើម ។ លោកបន្តថា ប្រទេសកម្ពុជានៅពេលនោះ គឺពិតជាមានភាព អំណោយផលខាងផ្នែកកសិកម្ម ប៉ុន្តែផែនការផលិតស្រូវឲ្យបាន ៣តោនក្នុង១ហិចតា គឺគ្រាន់តែជាការស្រមើរស្រមៃរបស់មេដឹកនាំ បក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ ដោយសារផែនការនោះមិនមាន ការសិក្សាឲ្យបានច្បាស់លាស់អំពីលទ្ធភាពនៅក្នុងការអនុវត្ត ។

ឆ្លើយតបនឹងសំណួរថា តើនរណាជាអ្នកដាក់ចេញនូវផែនការ បួនឆ្នាំនេះ? លោកសាស្ត្រាចារ្យអះអាងថា គឺមិនមែនចេញមកពី ប៉ុល ពត តែម្នាក់តែទេ គឺអាចចេញពីក្រុមមេដឹកនាំបក្ស ដោយ មានផ្នែកខ្លះសរសេរដោយ ខៀវ សំផន ផ្នែកខ្លះសរសេរដោយ មេដឹកនាំផ្សេងទៀត ហើយត្រូវបានសម្រេចជាសមូហភាពដោយ មជ្ឈិមបក្ស ប៉ុន្តែ មិនមានឯកសារណាមួយបញ្ជាក់អំពីបញ្ហានេះទេ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរ ទៀតថា តើមានផលប៉ះពាល់អ្វីដែលកើតចេញពីផែនការផលិត ឲ្យបានស្រូវ៣តោនក្នុង១ហិចតាដែរឬទេ? លោកសាស្ត្រាចារ្យ បញ្ជាក់ថា ផែនការនោះបានធ្វើឲ្យមនុស្សមានការភ័យខ្លាចក្នុងការ អនុវត្តដោយកម្មាភិបាលថ្នាក់ស្រុក ថ្នាក់តំបន់ ត្រូវបានដាក់កំហិត ឲ្យសម្រេចបានតាមផែនការដែលបានកំណត់ ប៉ុន្តែការសម្រេច បាន ឬមិនបានតាមផែនការ មិនមានព័ត៌មានណាមួយបញ្ជាក់អំពី បញ្ហានោះឡើយ ។ លោកបានសង្កត់ធ្ងន់ថា មានភស្តុតាងមួយចំនួន ដែលបញ្ជាក់ថា អ្នកគ្រប់គ្រងស្រុក និងតំបន់ទាំងអស់នោះ បានកាត់ យកចំណែកខ្លះដែលទុកសម្រាប់ចិញ្ចឹមប្រជាជននៅតាមមូលដ្ឋាន ដើម្បីសម្រេចឲ្យបានតាមផែនការកំណត់ ។ មានភស្តុតាងផ្សេង ទៀត ដែលនិយាយអំពីការនាំចេញស្រូវទៅប្រទេសចិនចំនួន រាប់រយតោន ជាថ្នូរនឹងការនាំចូលនូវទំនិញប្រើប្រាស់ផ្សេងៗ ហើយក៏មានភស្តុតាងដែលបញ្ជាក់អំពីការធ្លាក់ចុះនៃការផ្គត់ផ្គង់ ចំណីអាហារ កង្វះអាហារូបត្ថម្ភ ដែលបានធ្វើឲ្យមានមនុស្សស្លាប់ ជាច្រើននៅទូទាំងប្រទេស ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានអានឃ្លាមួយនៃសៀវភៅ "បងធំទីមួយ" ត្រង់ទំព័រ១១៧ ទាក់ទងនឹងលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅរបស់ប្រជាជន ។ នៅក្នុងឃ្លានោះបានសរសេរថា៖

> "ការងារភាគច្រើននៅក្នុងភូមិភាគពាយ័ព្យ គឺធ្វើឡើងដោយមនុស្សរាប់លាន ដែលជា ប្រជាជន១៧មេសា មកពីទីក្រុងភ្នំពេញ និង តំបន់ជនបទនៅបាត់ដំបង នៅក្នុងរយៈពេល ពីរឆ្នាំទៅទៀត ពួកគេត្រូវបានបង្ខំឲ្យកាប់គស់ រានដី ជីកប្រឡាយ និងកសាងទំនប់ទឹកនៅក្នុង ភូមិស្ថាននានា ។ មនុស្សរាប់ពាន់នាក់ត្រូវ បានស្លាប់ដោយសារខ្វះអាហារបរិភោគ ជំងឺ ការបាក់កម្លាំង និងការសម្លាប់ ។ គេបាន បញ្ជូនដំណឹងអ្នកស្លាប់ទាំងនេះទៅភ្នំពេញ ហើយគេចាត់ទុកថា អ្នកស្លាប់ទាំងនេះជាខ្មាំង ហើយជាខ្មាំងដែលនៅក្នុងជួរប្រជាជនថ្មី

*ដោយសារពួកគេមានច្រើនជាពួកខ្មាំងវណ្ណៈ ។ អ្នកនៅរស់ភាគច្រើនក៏អាចបន្លាញពីកម្មាភិបាលចំអកលកលើយ និងធ្វើបាបពួកគេ ដោយគេនិយាយពាក្យថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត " ។»*

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានសួរថា តើអ្វីដែលជាការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យទាក់ទងនឹងការស្លាប់ជីវិតមនុស្សរាប់ពាន់នាក់នៅក្នុងតំបន់នោះ? លោកបានឆ្លើយថា ប្រភពសំខាន់នៃព័ត៌មាននៅភូមិភាគពាយ័ព្យគឺចម្លើយរបស់ប្រជាជនថ្មីដែលនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានរត់ទៅរស់នៅព្រំដែនប្រទេសថៃ ដែលអាចនិយាយពិពណ៌នាពិស្តារពីអ្វីដែលបានកើតឡើងនៅក្នុងសម័យនោះ ។ លោកបន្តថា លោកប្រមូលបានព័ត៌មានមួយចំនួនទៀតពីសៀវភៅដែលបោះពុម្ពនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ពាក់ព័ន្ធនឹងការអះអាងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលថាខ្លួនមានអំណាចផ្តាច់មុខក្នុងការគិត ត្រូវបានលោកសាស្ត្រចារ្យអះអាងថា ការគិតបែបនោះគឺជាការយល់ខុសរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគិតថាគោលនយោបាយរបស់ខ្លួន គឺជាគោលនយោបាយដែលមិនចេះបរាជ័យ បើបរាជ័យគឺដោយសារចំណុចខ្វះខាតរបស់អ្នកអនុវត្ត ។ លោកបានប្រៀបធៀបការគិតរបស់បក្សកុម្មុយនីស្តកម្ពុជាទៅនឹងការគិតរបស់ ស្តាលីន មេដឹកនាំសហភាពសូវៀតបន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ដែលអះអាងថា បើផែនការបរាជ័យ គឺដោយសារមនុស្សធ្វើមិនបាន ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទៀតថា តើសេចក្តីសម្រេចណាមួយដែលនាំឲ្យមានការជម្លៀសប្រជាជនទៅភូមិភាគពាយ័ព្យនៅដើមឆ្នាំ១៩៧៦? លោកសាស្ត្រាចារ្យបញ្ជាក់ថា សេចក្តីសម្រេចនោះគឺចេញមកពីមជ្ឈិមបក្ស ដោយផ្សារភ្ជាប់ជាមួយនឹងនយោបាយទាំងមូលទាក់ទងនឹងផែនការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិកតា ហើយជាទូទៅសេចក្តីសម្រេច គឺចេញមកពីថ្នាក់កំពូលទាំងអស់ ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់អំពីពាក្យថា «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» លោកបានបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក្យនេះ បានក្លាយជាពាក្យស្លោកដែលកម្មាភិបាលរបស់បក្សចង់ប្រាប់ប្រជាជនថ្មីថា អ្នកទាំងនោះគ្មានតម្លៃទេ បើអ្នកទាំងនោះចង់នៅរស់គឺត្រូវខិតខំធ្វើការ ។ ពាក់ព័ន្ធនឹងការប៉ាន់ប្រមាណរបស់លោកសាស្ត្រាចារ្យអំពីចំនួនអ្នកស្លាប់ដោយសាររបបកម្ពុជាប្រជាធិបយេត្យដែលមាននៅក្នុងសៀវភៅ «សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា» ត្រូវបានលោកតំណាងសហព្រះរាជអាជ្ញាចោទសួរថា តើចំនួនតួលេខដែលប៉ាន់ប្រមាណថាមានមនុស្សម្នាក់ក្នុងចំណោមប្រាំនាក់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម



ទិដ្ឋភាពប្រជាជនកំពុងធ្វើការនៅក្នុងសហករណ៍ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានប្រភពមកពីណា? លោកសាស្ត្រាចារ្យបានពន្យល់ថា ការគិតគូរអំពីចំនួនអ្នកស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនមែនធ្វើឡើងដោយលោកតែម្នាក់ឯងទេ គឺលោកបានយោងលើរបាយការណ៍ប្រជាសាស្ត្រដែលបានធ្វើជំរឿននៅឆ្នាំ២០០០ ។ ប៉ុន្តែលោកគិតថា ចំនួនអ្នកស្លាប់អាចមានចំនួនរហូតដល់ជាងពីរលាននាក់ មិនមែន១.៥ ឬ១.៧លាននាក់នោះទេ ហើយលោកសប្បាយចិត្តនឹងធ្វើការកែប្រែចំនួនទូរលេខនេះ ប្រសិនបើមានការសិក្សាថ្មីរកឃើញអំពីចំនួននេះ ។

### ២.១.១២) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងតួនាទីរបស់ក្រុមមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ដោយស្នើសុំឲ្យលោកធ្វើការបញ្ជាក់ឲ្យបានច្បាស់អំពីតួនាទីនៃមេដឹកនាំទាំងអស់នោះ ។ លោកសាស្ត្រាចារ្យបានពន្យល់ថា ជនជាប់ចោទទាំងអស់ក្នុងសវនាការពិតជាធ្លាប់បានកាន់កាប់ដំណែងជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយលើកឡើងអំពី អៀង សារី ធ្លាប់ទទួលបន្ទុកកិច្ចការបរទេស, នួន ជា មានបទពិសោធន៍ច្រើនក្នុងការអប់រំកម្មាភិបាលនៅតាមភូមិភាគផ្សេងៗ, ខៀវ សំផន ទទួលបន្ទុកខាងផ្នែកពាណិជ្ជកម្ម និងបានបំពេញតួនាទីនេះយ៉ាងល្អ និងធ្វើទំនាក់ទំនងជាមួយសម្តេចសីហនុនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ រីឯ អៀង ធីរិទ្ធ មានតួនាទីខាងអប់រំ យោធាការ និង សុន សេន មានការកិច្ចខាងយោធា និងអប់រំយុវជននៅតាមតំបន់ និងភូមិភាគ ។ ដូច្នេះ បុគ្គលដែលត្រូវបានជ្រើសតាំងឲ្យធ្វើជាមេដឹកនាំ មិនមែនធ្វើឡើងដោយចោះៗនោះទេ គឺអ្នកទាំងនោះសុទ្ធតែមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើការងារទាំងអស់នោះ ។

### ២.១.១៣) ដំណើរការនៃស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តចោទសួរលោកសាស្ត្រាចារ្យទាក់ទងនឹងសេចក្តីសម្រេចខែតុលា ឆ្នាំ១៩៧៥ ពាក់ព័ន្ធនឹងការអនុម័តរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសួរថា តើរណសិរ្សរួបរួមជាតិកម្ពុជា និងស្ថាប័ននីតិប្បញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យមានដំណើរការ ឬមានដាក់អនុវត្តដែរឬទេ នៅក្រោយឆ្នាំ១៩៧៥? ឆ្លើយតបនឹងសំណួរនេះលោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា គឺស្ទើរតែមិនមានដំណើរការអ្វីទាំងអស់នៅពេលនោះ ដោយលោកបានសង្កត់ធ្ងន់ថា សម្តេច សីហនុ ទ្រង់បានយាងមកប្រទេសកម្ពុជា ហើយនៅតែបន្តគង់ជាប្រមុខរដ្ឋ ប៉ុន្តែទ្រង់មិនមានតួនាទីជាក់លាក់ក្នុងការធ្វើសកម្មភាពរបស់ទ្រង់ឡើយ ។ លោកបន្តថា នៅចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៦ បក្សបានធ្វើសកម្មភាពដោយសម្ងាត់ និងមិនបានធ្វើការពិភាក្សាអំពីអ្វីដែលបានកើតឡើងនៅពេលនោះឡើយ ។

### ២.១.១៤) ការបោះឆ្នោត

លោក ថារីក លើកឡើងអំពីការបោះឆ្នោតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបន្តសួរលោក សាស្ត្រាចារ្យទាក់ទងនឹងចំនួនដែលបានចេញទៅបោះឆ្នោតនៅអំឡុងពេលនោះ ថាតើជាត្រឹមត្រូវដែរឬទេ ដែលថាមានប្រជាជន៩៨ភាគរយបានចេញទៅបោះឆ្នោតនៅពេលនោះ? លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា នៅពេលនោះគឺពិតជាមានការបោះឆ្នោត ប៉ុន្តែប្រជាជនថ្មីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការបោះឆ្នោតនោះទេ គឺមានតែអ្នកមូលដ្ឋាន និងយោធាដែលអាចបោះឆ្នោតបាន ។ ពាក់ព័ន្ធនឹងតួលេខនៃប្រជាជនដែលចេញទៅបោះឆ្នោតនៅពេលនោះ លោកបញ្ជាក់ថា ចំនួន៩៨ភាគរយ គឺជាចំនួនមិនត្រឹមត្រូវ ហើយចំនួននេះមិនបានឆ្លុះបញ្ចាំងអំពីថា តើនរណាជាអ្នកមានសិទ្ធិអាចបោះឆ្នោតបាននោះទេ ។ លើសពីនេះទៀត ការបោះឆ្នោតនោះគឺធ្វើឡើងដោយក្លែង និងមិនដឹងថាជាការបោះឆ្នោតសម្រាប់ផ្ទេរអំណាចពីរណសិរ្សដល់របបថ្មីឬយ៉ាងណានោះទេ ។

### ២.១.១៥) រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ

ឆ្លើយតបនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំការពន្យល់ទាក់ទងនឹងមាត្រា៩ នៃរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ថាតើមានការអនុវត្តត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញក្នុងការបែងចែកអំណាចសភា ដែរឬយ៉ាងណានោះ? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា សភាប្រជាជនធ្លាប់បានកោះប្រជុំម្តងក្រោមអធិបតីរបស់ នួន ជា ដោយមានការចូលរួមពីសំណាក់គណៈមជ្ឈិម និងកម្មករ ប៉ុន្តែក្រោយមកទៀត មិនមានការកោះប្រជុំជាថ្មី

ឡើយ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបង្ហាញឯកសារមួយទាក់ទងនឹងតួនាទីរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងរដ្ឋាភិបាល នៅក្នុងសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងស្នើឲ្យលោកសាស្ត្រាចារ្យបញ្ជាក់អំពីឈ្មោះរបស់បុគ្គលម្នាក់ៗ ដែលមានឈ្មោះនៅក្នុងឯកសារនោះ ។ បុគ្គលទាំងនោះរួមមាន ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, សុន សេន, សោ ភឹម, វន វ៉េត និង តាម៉ុក ។

### ២.១.១៦) ហេតុការណ៍ជុំវិញការលាលែងពីតំណែងប្រមុខរដ្ឋរបស់សម្តេច សីហនុ

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តចោទសំណួរដោយផ្តោតលើការលាលែងចេញពីតំណែងជាប្រមុខរដ្ឋរបស់សម្តេចនរោត្តម សីហនុ នៅខែមិនា និងខែមេសា ឆ្នាំ១៩៧៦ និងហេតុការណ៍ជុំវិញការលាលែងនោះ ។ បន្ទាប់មកលោកបានបង្ហាញឯកសារកំណត់ហេតុគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៧៦ ពាក់ព័ន្ធនឹងការលាលែងពីដំណែងរបស់សម្តេចសីហនុ នៅលើអេក្រង់កុំព្យូទ័រ និងអានផ្នែកខ្លះៗនៃអត្ថបទនោះជូនលោកសាស្ត្រាចារ្យដើម្បីធ្វើការបញ្ជាក់ ។ លោក ថារីក បានលើកឡើងពីចំណុចមួយដែលបានសរសេរថាៈ

> *"យោបល់របស់អង្គការ ការប្រជុំនៅល្ងាចថ្ងៃទី១៣ ខែមិនា សមមិត្ត ហែម រាយការណ៍ទៅគណៈអចិន្ត្រៃយ៍អំពីសម្តេចសីហនុ ។ ទ្រង់បានសម្រេចលាលែងពីដំណែង លោកបានពន្យល់ថា អង្គការគួរតែអាណិតអាសូរទៅដល់សម្តេច ហើយសម្តេចនៅតែគោរពចំពោះអង្គការដដែល ទុកឲ្យសម្តេចលាលែងពីដំណែងនោះទៅ ។ លិខិតលាលែងនេះ គឺមិនមានអ្វីជុំយទៅនឹងយើងនោះឡើយ ។ លេខាបក្សបានពន្យល់ថា វាជាបញ្ហាធំ ហើយឲ្យខាងមជ្ឈិមជាអ្នកសម្រេច ។ ក៏ប៉ុន្តែលេខាបានលើកឡើងថា គោលការណ៍ចម្បងដែលគណៈអចិន្ត្រៃយ៍បានឯកភាពនោះ គឺមានដូចតទៅៈ ទីមួយ កុំឲ្យសម្តេច សីហនុ ចេញទៅក្រៅប្រទេស នេះជាវិធានការទីមួយ ។ ទីពីរ ត្រូវតែកោះប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីឲ្យសម្រេច ហើយបន្ទាប់មកត្រូវទៅជួបសម្តេច សីហនុ សារជាថ្មី ដោយមាន ប៉ែន នុត ចូលរួម ។"*

បន្ទាប់មកលោកបានអានឃ្លាមួយទៀតដែលការពិភាក្សាអំពីការលាលែងរបស់សម្តេច សីហនុ ជូនលោកសាស្ត្រាចារ្យ ។ ចំណុចនោះបានសរសេរថាៈ

> *"ទ្រង់បានចូលរួមបដិវត្តជាមួយពួកយើង ទោះបីជាទ្រង់មានជម្លោះជាមួយយើងក្តី ហេតុដូច្នេះហើយ ទើបបក្សសម្រេចឲ្យទ្រង់ធ្វើជាប្រធានរដ្ឋ ។ ក៏ប៉ុន្តែសម្តេចទ្រង់មិនឯកភាព ។ ទោះបីជាទ្រង់សម្រេចចិត្តលាលែង ឬក៏នៅដដែល វាគឺជាបញ្ហារបស់ទ្រង់ ។ យើងនៅតែរក្សាទុកទ្រង់ជានិមិត្តរូបដដែល យើងមិនសម្លាប់ទ្រង់ទេ ។ ក៏ប៉ុន្តែដើម្បីជាតិ និងប្រជាជន ទ្រង់បានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ធ្ងរ ដែលនាំឲ្យមានការស្លាប់ប្រជាជន ។ ដូច្នេះការសម្រេចចិត្តរបស់យើង គឺមានភាពសមហេតុផល ។ យើងនឹងនៅតែរក្សាទុកទ្រង់ ប៉ុន្តែប្រសិនបើទ្រង់នៅតែព្យាយាមរំដោះខ្លួនឲ្យមានសេរីភាព យើងនឹងបញ្ឈប់ការព្យាយាមនោះ ។"*

លោកបានអានឃ្លាមួយផ្សេងទៀតដែលនិយាយពីទិសវិវត្តរបស់បដិវត្ត ដែលនៅត្រង់ចំណុចនោះបានសរសេរថាៈ

> *"គឺត្រូវបញ្ឈប់សក្តិភូមិយ៉ាងដូច្នេះឯង ។ ក្រឡាអុកវាចេញមកដល់ត្រង់ហ្នឹងហើយ ។ របបសក្តិភូមិទាំងឡាយត្រូវបដិវត្តកម្ទេច និងគាស់រំលើងជាស្ថាពរ ។ ស្តេចដែលមានមក២,០០០ឆ្នាំមកហើយ ទីចុងបំផុតត្រូវស្អាត ។ យើងគ្មានផ្លូវដើរចេញក្រៅពីនេះទេ ។"*

ផ្អែកតបនឹងការលើកឡើងទាំងអស់នេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ហេតុផលសំខាន់ គឺក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដកសម្តេចចេញពីតំណែង ប៉ុន្តែរក្សាទុកព្រះអង្គឲ្យនៅជាមួយនឹងក្រុមរបស់គេដដែល ។ លោកបានបន្ថែមថា

នៅពេលដែលមេដឹកនាំចិន លោក ជូ អេនឡាយ បានស្លាប់ នៅទីក្រុងប៉េកាំង សម្តេច សីហនុ បានបាត់បង់នូវការគាំទ្រដោយផ្ទាល់ពីប្រទេសចិន ហើយពេលនោះបក្សកុម្មុយនីស្តកម្ពុជាគិតថា ខ្លួនអាចដកសម្តេចសីហនុពីអំណាចដោយសុវត្ថិភាព ។

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តអានឯកសារមួយទៀតដែលនិយាយអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីទាក់ទងនឹងការលាលែងពីដំណែងរបស់សម្តេច សីហនុ ដើម្បីឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ឯកសារនោះបានសរសេរថា៖

> “ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ឃើញថា សម្តេច សីហនុ គឺជាព្រះរាជាមានសេចក្តីស្នេហាជាតិ ហើយបានចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងការតស៊ូ ដើម្បីរំដោះជាតិប្រឆាំងនឹងសង្គ្រាមឈ្លានពានអំពីចក្រពត្តិអាមេរិក និងបរិវាររបស់វា ។ ផ្អែកទីបីនៃសេចក្តីសម្រេចរបស់មហាសន្និបាតជាតិចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ បានបញ្ជាក់យ៉ាងច្បាស់អំពីសេចក្តីល្អរបស់សម្តេច និងការអះអាងរបស់ទ្រង់ក្នុងការរក្សាឋានៈជាប្រមុខរដ្ឋ នៅក្នុងប្រវត្តិសាស្ត្រក្នុងដំណាក់កាលថ្មីរបស់ប្រទេសកម្ពុជា និងនៅក្នុងសង្គមកម្ពុជាថ្មី ។ ក៏ប៉ុន្តែសម្តេចមានបំណងចូលនិវត្ត ដូច្នេះហើយទ្រង់នឹងមានពេលវេលារស់នៅក្នុងជីវិតឯកជនជាមួយគ្រួសាររបស់ខ្លួន បន្ទាប់ពីព្រះអង្គបានធ្វើសកម្មភាពនយោបាយអស់រយៈពេល៣៥ឆ្នាំ ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានបង្ហាញអំពីការសោកស្តាយក្នុងការចូលនិវត្តរបស់សម្តេចព្រះនរោត្តម សីហនុ ប៉ុន្តែដោយគោរពទៅលើគោលបំណងខ្ពង់ខ្ពស់របស់សម្តេច ក្រុមប្រឹក្សារដ្ឋមន្ត្រីបានសម្រេចយល់ព្រមតាមសំណើសុំចូលនិវត្តនោះ ។”

ពាក់ព័ន្ធនឹងអត្ថន័យដែលសហព្រះរាជអាជ្ញាបានរៀបរាប់ខាងលើ សាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ពិតប្រាកដណាស់ បក្សមានគោលនយោបាយឃុំខ្លួនទ្រង់ ប៉ុន្តែមិនសម្លាប់ទ្រង់ទេ ដោយសារទ្រង់មានគុណបំណាច់ក្នុងការធ្វើនយោបាយរយៈពេល៣៥ឆ្នាំ ។ លោកបានបន្ថែមថា ការផ្សព្វផ្សាយចេញមកក្រៅនូវអត្ថបទមួយនេះ គឺដើម្បីធ្វើឲ្យប្រទេសក្រៅជឿលើចំណុចនេះ និងធ្វើឲ្យជឿថារបបរបស់ខ្លួនជារបបដែលមានហេតុផល និងមានការគោរពចំពោះបុគ្គលមួយរូបដែលមានគុណបំណាច់ចំពោះប្រទេសកម្ពុជា ។

### ២.១.១៧) ការកម្ទេច និងការអប់រំកែប្រែ

តំណាងសហព្រះរាជ្ញាអន្តរជាតិ បានងាកចេញពីប្រធានបទទាក់ទងនឹងការលាលែងចេញពីដំណែងរបស់សម្តេចសីហនុមកប្រធានបទទាក់ទងនឹងការកម្ទេចខ្មាំងរបស់បក្ស ដោយលោកសួរផ្តោតជាសំខាន់លើមន្ទីរស-២១ដែលគ្រប់គ្រងដោយ ឌុច ។ ប៉ុន្តែលោកបានបញ្ជាក់បន្ថែមថា លោកនឹងមិនសួរលម្អិតអំពីមន្ទីរស-២១


បរិវេននៃគុកទួលស្លែង ឬមន្ទីរស-២១

ទេ ដោយសារមិនមានជាប់ទាក់ទងនឹងអង្គហេតុនៅក្នុងសវនាការដំណាក់កាលដំបូង ។ លោក ថារីក បានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់អំពីការបង្កើតមន្ទីរស-២១ ។ ឆ្លើយតបនឹងសំណើនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ស-២១គឺជាលេខកូដរបស់មន្ទីរដែលមានទីតាំងនៅសាលាទួលស្លែង ហើយក្រៅពីស-២១ គឺមានមន្ទីរមួយទៀត គឺស-២៤ ដែលមានទីតាំងនៅព្រៃស

សម្រាប់ធ្វើការអប់រំកែប្រែអ្នកទោសដែលមានទោសស្រាលៗ រីឯអ្នកដែលបានប្រព្រឹត្តកំហុស ឬមានទោសធ្ងន់ធ្ងរត្រូវបញ្ជូនទៅ ស-២១ ។ បន្ទាប់មកលោក ផារីក បានសួរថា តើមន្ទីរស-២១ មានបេសកកម្មដូចម្តេច? លោកសាស្ត្រាចារ្យ បានឆ្លើយថា ឌុច មានតួនាទីក្នុងការអនុវត្តបេសកកម្មទាំងនោះ ដោយសារ ឌុច ធ្លាប់អនុវត្តការកិច្ចទាំងអស់នោះនៅអមលាំង ដោយធ្វើការបោសសម្អាត លុបបំបាត់ និងកម្ទេចអ្នកដែលប្រឆាំង ។ លោក ផារីក បានបន្តសួរទៀតថា តើអ្វីដែលជាទំនាក់ទំនងរវាងការអប់រំកែប្រែ និងការកម្ទេច? លោកបានអះអាងថា មិនមានភស្តុតាងណាមួយបញ្ជាក់អំពីបញ្ហានេះទេ ប៉ុន្តែនីតិវិធីនៃការអនុវត្តសកម្មភាពទាំងពីរនេះ គឺមិនមានទំនាក់ទំនងដោយផ្ទាល់នោះទេ ។ លោកបន្ថែមថា ប្រសិនបើមានភស្តុតាងណាមួយបញ្ជាក់ថានរណាម្នាក់ជាខ្មាំង បុគ្គលនោះគ្រាន់តែទទួលការអប់រំកែប្រែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើ


(រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នរណាម្នាក់ត្រូវបានចាត់ទុកថាជាខ្មាំង បុគ្គលនោះនឹងក្លាយជាកម្មវត្ថុក្នុងការនាំយកទៅកម្ទេច ។ ការអប់រំកែប្រែមិនបានកើតមាននៅមន្ទីរស-២១ទេ មិនមាននរណាម្នាក់ត្រូវបានដោះលែងឲ្យរួចខ្លួនឡើយ ប៉ុន្តែនៅមន្ទីរស-២៤ដែលជាកន្លែងអប់រំកែប្រែ អាចមានមនុស្សមួយចំនួនត្រូវបានដោះលែង ។

លោកបានធ្វើការកត់សម្គាល់ថា អ្នកដែលនៅរស់រានមានជីវិតពីស-២១ គឺមានចំនួនប្រហែល១០ទៅ១២ នាក់តែប៉ុណ្ណោះ រួមទាំងកុមារ ។ ក្នុងចំណោមអ្នកទាំងនោះ លោកគិតថាមានមនុស្សពីរនាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

តំណាងសហព្រះរាជអាជ្ញា ផារីក បានបន្តស្នើសុំការពន្យល់ពីសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងឯកសារនៅមន្ទីរស-២១ ។ លោកសាស្ត្រាចារ្យបានរៀបរាប់ថា ឯកសារនៅមន្ទីរស-២១ គឺមានច្រើនប្រភេទ និងមានភាពគួរឲ្យចាប់អារម្មណ៍ ។ ឯកសារទាំងនោះបានបង្ហាញពីសំឡេងដែលចេញពីមន្ទីរនេះ និងប្រើប្រាស់ដើម្បីធ្វើជាភស្តុតាងបង្ហាញ ដូចជា ឯកសារប្រវត្តិរូប ជាដើម ។ ប៉ុន្តែឯកសារដែលមានសារៈសំខាន់ក្នុងការវិភាគ គឺឯកសាររដ្ឋបាល សៀវភៅណែនាំ និងគោលនយោបាយដែលត្រូវធ្វើជាមួយអ្នកទោស ដូចជានៅក្នុងការសួរចម្លើយ វគ្គសិក្សាដែលកម្មាភិបាលធ្វើការនៅស-២១បានរក្សាទុកនៅមន្ទីរនេះ ។ លោកសាស្ត្រាចារ្យបានធ្វើការកត់សម្គាល់ទៀតថា មានឯកសារចម្លើយសារភាពចំនួនតែ៣.៨០០ប៉ុណ្ណោះ ដែលត្រូវបានរកឃើញនៅមន្ទីរស-២១ ហើយចម្លើយសារភាពចំនួន១០០ទៀត ត្រូវបានរកឃើញនៅកន្លែងផ្សេង ។ ប៉ុន្តែចំនួនអ្នកទោសនៅស-២១មានចំនួន១៤.០០០នាក់ ដូច្នេះលោកគិតថាគួរតែមានចម្លើយសារភាពយ៉ាងហោចណាស់១៤.០០០ ។ លោកបានពន្យល់ថា ការណ៍ដែលមិនឃើញមានចម្លើយសារភាពផ្សេងទៀត អាចបណ្តាលមកពីអ្នកទោសខ្លះដែលដឹកមកដល់ស-២១ ត្រូវបានបញ្ជូនចេញភ្លាមៗ ដោយមិនទាន់បានសរសេរចម្លើយសារភាព ហើយចម្លើយសារភាពខ្លះទៀតត្រូវបានកម្ទេចចោលក្រោយឆ្នាំ១៩៧៩ ។ អ្នកដែលធ្វើចម្លើយសារភាពទាំងអស់ខិតខំប្រឹងឆ្លើយដើម្បីអាចរួចខ្លួន ប៉ុន្តែអ្នកទាំងនោះមិនបានដឹងទេថា ខ្លួននឹងត្រូវយកទៅសម្លាប់ក្រោយពេលឆ្លើយសារភាពនោះទេ ។ ចម្លើយសារភាពរបស់ កុយ ធួន និង វន វ៉េត ដែលឆ្លើយមានប្រវែងរាប់សិបទំព័រ គឺមានការឆ្លើយទាក់ទងនឹងចំណុចផ្សេងៗគ្នា ។ ប្រសិនបើរកឃើញថា ការឆ្លើយនោះមិនទាន់អាចទទួលយកបាន អ្នកឆ្លើយសារភាពនោះនឹងត្រូវកែតម្រូវឲ្យ ឆ្លើយសារភាពរហូតដល់ត្រូវនឹងលក្ខខណ្ឌតម្រូវ ហើយអ្នកដែលត្រូវបានឆ្លើយដាក់នឹងត្រូវចាប់ខ្លួនយកមកសួរចម្លើយដូចគ្នា ។

***សូមបញ្ជាក់ថា*** *នៅព្រឹកថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ មុនពេលតំណាងសហព្រះរាជអាជ្ញាបន្តការសួរដេញដោលលើលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ លោកមេធាវីការពារក្តី កាណាវ៉ាស បានធ្វើការកត់សម្គាល់លើបញ្ហាចំនួនបីចំណុច ។ ទីមួយ ទាក់ទងនឹងការជជែកគ្នារវាងលោកសាស្ត្រាចារ្យ ឆេនដល័រ ដែលជាអ្នកជំនាញជាមួយនឹងសហព្រះរាជអាជ្ញាមុនពេលចាប់ផ្តើមសវនាការ ដែលជាកាយវិការមួយមិនសមរម្យ ព្រោះអ្នកជំនាញមិនអាចមកពិភាក្សាជាមួយសហព្រះរាជអាជ្ញាដែលជាអ្នកចោទប្រកាន់បានទេ ។ លោក ឆេនដល័រ ក៏ដឹងអំពីបញ្ហានេះពីព្រោះរូបលោកសាស្ត្រាចារ្យផ្ទាល់ក៏ជាកូនប្រុសរបស់មេធាវីល្បីឈ្មោះមួយរូបដែរ ។ ចំណុចទីពីរ លោកមេធាវី កាណាវ៉ាស បានលើកឡើងទាក់ទងនឹងបញ្ហាសំណើរបស់លោក ដែលស្នើសុំឲ្យកូនក្តីរបស់ខ្លួនទៅសម្រាកនៅក្នុងបន្ទប់រង់ចាំដោយសារតែបញ្ហាសុខភាពដោយមិនអាចចូលរួមដោយផ្ទាល់ក្នុងសវនាការបាន ។ លោកមេធាវីបានជម្រាបអង្គជំនុំជម្រះថា លោកបានសួរលោកវេជ្ជបណ្ឌិតអំពីបញ្ហាសុខភាពកូនក្តីរបស់ខ្លួន ប៉ុន្តែលោកគ្រូពេទ្យបានធ្វើប្រងើយកន្តើយនឹងសំណើរបស់លោក ដោយមិនបានបញ្ជាក់អំពីមូលហេតុសុខភាពរបស់កូនក្តីរបស់ខ្លួនទេ ។ រីឯបញ្ហាទីបីគឺទាក់ទងនឹងបញ្ហាការរៀបចំ និងត្រៀមខ្លួនរបស់អ្នកជំនាញក្នុងការឆ្លើយតបនឹងសំណួររបស់ភាគីនៅក្នុងសវនាការ ។ ភ្លាមៗ សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានឆ្លើយតបនឹងការលើកឡើងរបស់លោកមេធាវីកាណាវ៉ាស ដោយអះអាងថា ការលើកឡើងរបស់លោកមេធាវីកាណាវ៉ាស ទាក់ទងនឹងការមិនឆ្លើយតបរបស់លោកគ្រូពេទ្យជាមួយខ្លួននោះ គឺមិនមែនជារឿងចម្លែកនោះទេ ។ ដោយសារគ្រូពេទ្យក៏ជាអ្នកជំនាញ និងមានវិជ្ជាជីវៈរបស់ខ្លួនក្នុងការរក្សាការសម្ងាត់ ហើយការរាយការណ៍របស់គ្រូពេទ្យមិនមែនសម្រាប់មេធាវីការពារក្តី ឬភាគីផ្សេងទេ គឺធ្វើឡើងនៅក្នុងសវនាការដើម្បីឲ្យភាគីទាំងអស់បានសួរដេញដោលនៅក្នុងសវនាការ ។ម្យ៉ាងវិញទៀត ករណីនេះដូចក៏ជាអ្វីដែលលោកមេធាវី កាណាវ៉ាស បានលើកឡើងទាក់ទងនឹងការទាក់ទងរវាងសាស្ត្រាចារ្យ ឆេនដល័រ និងសហព្រះរាជអាជ្ញាដែរ ។*

ដើម្បីដោះស្រាយបញ្ហាដែលលើកឡើងដោយលោកមេធាវី កាណាវ៉ាស អង្គជំនុំជម្រះបានកោះហៅវេជ្ជបណ្ឌិតប្រចាំការនៅតុលាការដើម្បីបង្ហាញពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ជូនដល់អង្គជំនុំជម្រះ និងសាធារណៈជនបានជ្រាប ។

**២.១.១៨) ការបោសសម្អាតមន្ត្រីជាន់ខ្ពស់ និងកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ**

នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ដែលជាថ្ងៃទី៣នៃសវនាការ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរសំណួរលោកសាស្ត្រាចារ្យ ឆេនដល័រ ដោយផ្តោតលើការបោសសម្អាតនៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ។ មុនពេលចូលដល់ការសួរសំណួរ លោក ថារីក បានអានឃ្លាមួយនៃសៀវភៅ "សំឡេងពីមន្ទីរស-២១" ដោយស្នើឲ្យសុំលោកសាស្ត្រាចារ្យធ្វើការពន្យល់ពីអត្ថន័យដែលសរសេរថាៈ

> *"វិសុទ្ធកម្ម ការបោសសម្អាត ធ្វើឡើងដោយមជ្ឈិមបក្ស និងអនុវត្តនៅមន្ទីរស-២១ អាចចែកចេញជាពីរដំណាក់កាលធំៗ ។ ដំណាក់កាលទីមួយ គឺចាប់ផ្តើមធ្វើឡើងពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែកញ្ញា ឆ្នាំ១៩៧៦ ។ ដំណាក់កាលទីពីរ គឺបន្តរហូតមកដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សដែលជាមុខសញ្ញាក្នុងការធ្វើវិសុទ្ធកម្មលើកទីមួយ គឺប្រជាជនស៊ីវិល និងយុទ្ធជនមានស័ក្តិធំៗរបស់របប លន់ នល់ ។ ជាលទ្ធផល ប្រជាជនរាប់ពាន់នាក់ត្រូវបានប្រមូលយកទៅសម្លាប់ចោល ។ អំពីមនុស្សឃាតក្នុងឆ្នាំ១៩៧៥ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការអប់រំកសាងខ្លួននៅប្រទេសវៀតណាម គឺធ្វើឡើងតាមបញ្ជាពីថ្នាក់លើដាច់ខាត ។ នៅក្នុងប្រទេសកម្ពុជា ការសម្លាប់គឺធ្វើឡើងនៅក្នុងឆ្នាំ១៩៧៥ ដោយបក្ស ។ ក្រោយមក ឃើញមានឯកសារជាច្រើនដែលបានលើកឡើងអំពីបញ្ហាខ្លាំងដែលបានបញ្ជូនទៅមន្ទីរសន្តិបាល ។"*

លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ការធ្វើវិសុទ្ធកម្មប្រឆាំងនឹងអតីតសមាជិករដ្ឋាភិបាល និងទាហាននៃរបប លន់ នល់

គឺទទួលបានតាមរយៈរបាយការណ៍ដែលធ្វើឡើងនៅក្នុងជំរុំជនភៀសខ្លួន និងនៅក្នុងឯកសារកម្ពុជាប្រជាធិបតេយ្យមួយចំនួន ហើយឯកសារទាំងអស់នោះលោកមិនបានជួបប្រទះនៅអំឡុងពេលនៃការសរសេរសៀវភៅរបស់លោកទេ ។ លោកពន្យល់ត្រង់ចំណុចនេះថា ជាការពិតមានភស្តុតាងបង្ហាញថា ប្រសិនបើប្រជាជនថ្មីត្រូវបានរកឃើញថាធ្លាប់បានបម្រើការនៅក្នុងរបប លន់ នល់ អ្នកទាំងនោះនឹងត្រូវនាំចេញពីកន្លែងធ្វើការយកទៅឃុំឃាំងនៅក្នុងគុក ហើយនៅក្នុងករណីជាច្រើនអ្នកទាំងនោះត្រូវបានសម្លាប់ចោលតែម្តង ។

## ២.១.១៩) ការកម្ទេចខ្មាំងផ្ទៃក្នុងបក្ស

ឆ្លើយតបនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំឲ្យធ្វើការពន្យល់ពាក់ព័ន្ធនឹងមនោគមវិជ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលផ្តោតលើការតស៊ូវណ្ណៈ និងការកម្ទេចខ្មាំង លោកសាស្ត្រាចារ្យបានអះអាងថា ខ្មាំងផ្ទៃក្នុងចាប់ផ្តើមមានឡើងរួចទៅហើយនៅខែធ្នូ ឆ្នាំ១៩៧៥ ប៉ុន្តែការធ្វើវិសុទ្ធកម្មខ្មាំងផ្ទៃក្នុងមិនទាន់ចាប់ផ្តើមនៅឡើយទេនៅពេលនោះ គឺគ្រាន់តែមានការជំរុញឲ្យសមាជិករបស់ខ្លួនមានការប្រុងប្រយ័ត្នត្រៀមប្រឆាំងនឹងខ្មាំងខាងក្នុង ។ ឆ្លើយតបនឹងសំណួរថា តើនរណាជាអ្នកសរសេរទស្សនាវដ្តីទង់បដិវត្ត ឬទស្សនាវដ្តីទាំងនោះតំណាងឲ្យនរណា? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា អត្ថបទទាំងនោះត្រូវបានរៀបចំដោយសមាជិកជាន់ខ្ពស់របស់បក្ស ហើយអត្ថបទទាំងនោះឆ្លុះបញ្ចាំងអំពីសុន្ទរកថាដែលផ្តល់ដោយមេដឹកនាំជាន់ខ្ពស់របស់បក្ស ប៉ុន្តែជាទូទៅមិនមានដាក់ឈ្មោះឡើយ ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសាកសួរទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្តប្រចាំខែកក្កដា ឆ្នាំ១៩៧៦ ដោយផ្តោតលើចំណុចដែលសរសេរថាៈ

*"ទិដ្ឋភាពយាយីវានៅតែជាប្រចាំ បំផ្លាញយើងតាមគ្រប់វិធីបែបយ៉ាង ។ បំផ្លាញពីក្រៅ បំផ្លាញពីក្នុង តែពីខាងក្រៅវាវាយយើងមិនបានទេ ទាល់តែវាយពីក្នុង ។ ដើម្បីវាយពីក្នុងបានទាល់តែវាយមាគ៌ា ធ្វើឲ្យមាគ៌ាច្របូកច្របល់នៅផ្ទៃក្នុងបក្ស នៅក្នុងយោធា នៅក្នុងចំណោមប្រជាជន ដើម្បីឲ្យគេវាយបំបែក ។"*

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានអានឃ្លាមួយទៀតដែលសរសេរថាៈ

*"កាលពីមុន ការខុសឆ្គងនាមមួយចំនួន គឺមានច្រើន ក៏ប៉ុន្តែខុសឆ្គងនាមមួយចំនួននោះ គឺវាធ្វើឡើងក្នុងឆ្នាំ៧០-៧១ ដូច្នេះសមាសភាព កាសនិយមវាចូលបានច្រើន ។ តែបក្សបិទទ្វារសម្រិតសម្រាំងបានជាអតិបរមា ។"*

*"នៅក្នុងនោះ តាមបទពិសោធន៍ត្រូវក្តាប់ប្រវត្តិរូបឲ្យបាន ។ បើប្រវត្តិរូបមិនច្បាស់ ទោះជាល្អក៏ដោយ ក៏កុំអាលបញ្ចូល ប្រយ័ត្នពួក សេ.អ៊ី.អា វាជ្រៀតចូល ។ សេ.អ៊ី.អា វាវាយបដិវត្តន៍ដោយបញ្ចូលថ្នាំតាមសរសៃឈាមរបស់បដិវត្តន៍"* ។

លោក ថារីក បានស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់នៅត្រង់ចំណុចនេះ ថាតើឃ្លាទាំងអស់ដែលលោកបានអានមានឆ្លុះបញ្ចាំងអំពីទស្សនៈអ្វីចំពោះខ្មាំង ដែលមានជាប់ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ? សាស្ត្រាចារ្យ ឆេនដល័រ ពន្យល់ថា ឃ្លាទាំងអស់ដែលព្រះរាជអាជ្ញាបានរៀបរាប់ គឺបង្ហាញអំពីការកំណត់ខ្មាំង ជាពិសេសបុគ្គលដែលត្រូវបានបញ្ចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែមិនមានចំនួនតួលេខច្បាស់លាស់ដែលបញ្ជាក់អំពីចំនួនសមាជិកដែលបានចូលរួមនៅក្នុងបក្សនៅពេលនោះទេ ។ លោកបញ្ជាក់ថា ចំនួនអ្នកចូលរួមក្នុងបក្សកុម្មុយនីស្តកម្ពុជានៅពេលនោះអាចមានដល់ចំនួនរាប់ពាន់ រាប់ម៉ឺននាក់ ។ ជាក់ស្តែង នៅអំឡុងពេលសង្គ្រាមស៊ីវិល ខ្មែរក្រហមបានធ្វើប្រតិបត្តិការយ៉ាងខ្លាំងដោយខ្លួនឯង ជាជាងប្រតិបត្តិការរួមជាមួយនឹងប្រទេសវៀតណាមប្រឆាំងនឹងរបប លន់ នល់ ។ ខ្មែរក្រហមយល់យ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការអភិវឌ្ឍកម្មាភិបាលដែលខ្លួនទុកចិត្ត និងដាក់បញ្ចូលអ្នកទាំងអស់នោះជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា ដោយផ្តល់តួនាទីជាសមាជិកយោធា និងតួនាទីផ្សេងៗទៀត ។ លោកបន្តទៀតថា បក្សកុម្មុយនីស្តកម្ពុជាមានការព្រួយបារម្ភចំពោះបុគ្គលដែលខ្លួនបានជ្រើសរើសនៅអំឡុងពេលសង្គ្រាម ដោយសារមិនទាន់មានការបញ្ជាក់អំពីប្រវត្តិរូបគ្រប់គ្រាន់ ព្រោះបុគ្គលខ្លះបានអះអាងថា ខ្លួនស្ថិតក្នុងវណ្ណៈកសិករក្រីក្រ ប៉ុន្តែ៣ឆ្នាំបន្ទាប់មកអ្នកទាំងនោះត្រូវបានរកឃើញថាមានវណ្ណៈដើមផ្សេងពីនេះ ឬក៏ធ្លាប់ជាប់ទាក់ទងនឹងរបប លន់ នល់ ។ ដូច្នេះបក្សត្រូវតែសម្រិតសម្រាំងបុគ្គលទាំងនោះឡើងវិញ ជាពិសេស

អ្នកដែលពាក់ព័ន្ធនឹងរបប លន់ នល់ ដែលនៅសេសសល់ ។

### ២.១.២០) ការសរសេរប្រវត្តិរូបផ្ទាល់ខ្លួន

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការធ្វើប្រវត្តិរូបរបស់កម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់លើបញ្ហានេះ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ប្រវត្តិរូបត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយការធ្វើប្រវត្តិរូបគឺជាគំនិតថ្មីមួយនៅក្នុងប្រទេសកម្ពុជា ដែលតម្រូវឲ្យម្នាក់ៗនៅក្នុងរបបនោះត្រូវតែធ្វើប្រវត្តិរូបដើម្បីប្រើនៅក្នុងវគ្គសិក្សា ។ មេដឹកនាំបក្សមួយចំនួនក៏បានធ្វើប្រវត្តិរូបដែរ ដូចជា ប៉ុល ពត ដែលឃើញមាននៅក្នុងចម្លើយសារភាពមួយក្នុងចំណោមចម្លើយសារភាពជាច្រើន ។ ការធ្វើប្រវត្តិរូប គឺជាកត្តាសំខាន់មួយ ក្នុងការលាតត្រដាងអំពីជីវិតអតីតកាល ថាតើនរណាម្នាក់ធ្លាប់ធ្វើអ្វីខ្លះ ឬនិយាយម្យ៉ាងទៀតថា ប្រសិននរណាម្នាក់ស្ថិតនៅក្នុងវណ្ណៈកសិករមធ្យម អ្នកនោះមិនសូវមានភាពស្មោះត្រង់នឹងបក្សកុម្មុយនីស្ត ដូចជាអ្នកដែលស្ថិតនៅក្នុងវណ្ណៈកសិករក្រីក្រទេ ។ ប្រសិនបើនរណាម្នាក់មានជាប់ពាក់ព័ន្ធនឹងរបប លន់ នល់ ឬធ្លាប់ធ្វើជាព្រះសង្ឃ អ្នកនោះនឹងត្រូវបានសង្ស័យថាបុគ្គលមិនបរិសុទ្ធ និងត្រូវបានចោទសួរជាច្រើនដងដើម្បីយកព័ត៌មាន ។ ទោះបីជាបុគ្គលដែលមិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុសក៏ដោយ ក៏អ្នកទាំងនោះត្រូវបានស្នើឲ្យធ្វើប្រវត្តិរូបជាច្រើនលើកច្រើនសារ ដើម្បីដឹងថាតើមានការផ្លាស់ប្តូរ ឬលុបព័ត៌មានសំខាន់ៗចេញពីប្រវត្តិរូបឬទេ ។ លោកសាស្ត្រាចារ្យបានសង្កត់ធន់ថា “ការធ្វើប្រវត្តិរូប គឺជាឧបករណ៍សំខាន់មួយ ដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់ដើម្បីធ្វើការត្រួតត្រានិងស្វែងរកនរណាម្នាក់» ។

### ២.១.២១) ភាពមន្ទិលក្រោយហេតុការណ៍ផ្ទុះគ្រាប់បែកឆ្នាំ១៩៧៦

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរសំណួរដោយផ្តោតលើសំណេរដែលមាននៅក្នុងសៀវភៅ “សំឡេងពីមន្ទីរស-២១» ទាក់ទងនឹងផ្នែកដែលនិយាយអំពីហេតុការណ៍នៅក្នុងឆ្នាំ១៩៧៦ ដែលកើតមានការគប់គ្រាប់បែកនៅក្រោយព្រះបរមរាជវាំង និងការផ្ទុះគ្រាប់បែកនៅឯខេត្តសៀមរាប ។ លោក ថារីក បានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់ពីហេតុការណ៍ទាំងពីរដែលបានកើតឡើងនាពេលនោះ ។ ឆ្លើយតបសំណើរបស់តំណាងសហព្រះរាជអាជ្ញា លោកសាស្ត្រាចារ្យ បានពន្យល់ថា ការផ្ទុះគ្រាប់បែកនៅខេត្តសៀមរាប មិនទាន់មានបុគ្គលណាម្នាក់ធ្វើការពន្យល់លើបញ្ហានេះទេ ប៉ុន្តែអ្នកស្រាវជ្រាវមួយចំនួនបានធ្វើការសិក្សាលើអ្វីដែលបានកើតឡើងនៅពេលនោះ ។ លោកបន្ថែមថា ការផ្ទុះនោះអាចបណ្តាលមកពីការផ្ទុះគ្រាប់យុទ្ធភ័ណ្ឌដោយចៃដន្យ ។ ប៉ុន្តែអ្នកខ្លះគិតថា ការផ្ទុះនោះគឺកើតឡើងដោយសារការវាយឆ្មក់ពីលើអាកាសរបស់ប្រទេសថៃ ។ មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ការផ្ទុះនោះកើតឡើងដោយសារអាជ្ញាធរមូលដ្ឋាននោះទេ ប៉ុន្តែព្រឹត្តិការណ៍នេះបានធ្វើឲ្យរបបគ្រប់គ្រងមានការព្រួយបារម្ភ ដោយសារជាព្រឹត្តិការណ៍មួយដែលបានកើតឡើងដោយមិននឹកស្មានដល់ ។ រីឯ ការផ្ទុះគ្រាប់បែកនៅជិតព្រះបរមរាជវាំង នៅទីក្រុងភ្នំពេញ ដែលបានកើតឡើងនៅជិតកន្លែងមេដឹកនាំរស់នៅ ត្រូវបានបក្សចាត់ទុកការផ្ទុះគ្រាប់បែកនោះថា គឺជាការវាយប្រហារលើរបបទាំងមូល ។ ក្រុមកងទ័ពដែលមកពីភូមិភាគបូព៌ាត្រូវបានសង្ស័យថា ជាអ្នកដាក់គ្រាប់បែកឲ្យផ្ទុះដោយមានការបញ្ជាពីកម្មាភិបាលមកពីភូមិភាគបូព៌ា ។ បន្ទាប់មក របបកម្ពុជាប្រជាធិបតេយ្យបានចាត់ទុកកម្មាភិបាលដែលរស់នៅជាប់ព្រំប្រទល់វៀតណាមថាគឺជាជនសង្ស័យ បន្ទាប់ពីមានការស៊ើបអង្កេត ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានសង្កត់ធន់ថា “ហេតុការណ៍នេះ គឺជាចំណុចចាប់ផ្តើមនាំឲ្យមានការបង្កើតមន្ទីរស-២១ភ្លាមៗនៅក្នុងវិទ្យាល័យពញាយ៉ាត ក្រោយពីមានព្រឹត្តិការណ៍នេះបានកើតឡើង» ។ លោកបានបញ្ជាក់បន្ថែមថា ការចាប់ខ្លួន កុយ ធួន មិនមានជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ខាងដើមទេ ។ ការចាប់ខ្លួននេះ គឺទាក់ទងនឹងការបោសសម្អាតលើកទីបីប្រហែលមួយឆ្នាំក្រោយពីព្រឹត្តិការណ៍នោះកើតឡើង ហើយការចាប់ខ្លួន កុយ ធួន នាពេលនោះ បានក្លាយជាការចាប់ផ្តើមនៃការបោសសម្អាតនូវក្រុមបញ្ញវន្តក្នុងបក្សដែលមានជាប់ខ្សែជាមួយ កុយ ធួន ដែលធ្លាប់បានរៀនជាមួយគ្នានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ការធ្វើវិសុទ្ធកម្មប្រឆាំងនឹងក្រុមយោធាបានធ្វើឡើងរហូតដល់ឆ្នាំ១៩៧៦ ហើយនៅក្នុងឆ្នាំ១៩៧៧ ការធ្វើវិសុទ្ធកម្មត្រូវបានប្តូរ

ទិសដៅទៅរកកម្មាភិបាលនៅតាមតំបន់ផ្សេងៗ នៅក្នុងប្រទេស ដែលត្រូវបានចាត់ទុកថាជាសមាសភាពអាក្រក់ ។ ម្យ៉ាងវិញទៀត ការបោសសម្អាតនោះបណ្តាលមកពីចម្លើយសារភាពរបស់ កុយ ធួន ដែលមានកម្រាស់ចំនួនជាង៨០០ទំព័រ ។

**២.១.២២) ការចូលកាន់តំណែងរបស់ ខៀវ សំផន នៅមន្ទីរ ៨៧០ ជំនួស ឡឿន**

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តដកស្រង់ផ្នែកមួយចំនួននៃសៀវភៅសំឡេងពីមន្ទីរស-២១ ហើយស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់ ។ ផ្នែកដែលតំណាងសហព្រះរាជអាជ្ញាបានលើកយកមកស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ គឺទាក់ទងនឹងការចាប់ខ្លួនឈ្មោះ ឡឿន ដែលជាអ្នកគ្រប់គ្រងនៅមន្ទីរ៨៧០ ពីរសប្តាហ៍ក្រោយការចាប់ខ្លួន កុយ ធួន ហើយបន្ទាប់មកបក្សបានតែងតាំង ខៀវ សំផន ឲ្យគ្រប់គ្រងមន្ទីរ៨៧០វិញ ។ ត្រង់ចំណុចនេះលោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ប្រសិនបើអាច លោកនឹងធ្វើការកែប្រែសៀវភៅរបស់លោកនៅត្រង់ផ្នែកនេះឡើងវិញ ដោយសារ៨៧០គឺជាអាស័យដ្ឋានសម្រាប់ផ្ញើសារ ជាកន្លែងបញ្ជូនលិខិតចេញចូល និងជាមន្ទីរមួយដែរ ប៉ុន្តែ៨៧០នេះ អាចច្រឡំជាមួយនឹងលេខកូដសម្រាប់សម្គាល់ឈ្មោះរបស់ ប៉ុល ពត ។ លោកបន្តថា អ្នកដែលធ្វើការនៅក្នុងមន្ទីរនោះ គឺជាបុគ្គលដែលត្រូវបានមេដឹកនាំថ្នាក់កំពូលរបស់បក្សស្ទើរតែទាំងអស់ជឿទុកចិត្ត ។ មន្ទីរ៨៧០ គឺជាមន្ទីរសរសៃឈាមយ៉ាងសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា ដែលសម្រាប់ខ្លួនលោកសាស្ត្រាចារ្យផ្ទាល់ លោកហៅមន្ទីរ៨៧០នេះថា ជាគណៈកម្មាធិការមជ្ឈិម លោកយល់ថា មន្ទីរនេះ គឺជាកន្លែងដែលត្រូវបានរួមបញ្ចូលគ្នាដោយគណៈកម្មាធិការមជ្ឈិម, គណៈកម្មាធិការអចិន្ត្រៃយ៍, ៨៧០ , មន្ទីរក-១ , អគ្គការ ឬអគ្គការលើ ។ កន្លែងទាំងនេះ គឺសំដៅលើកន្លែងសម្រាប់ចេញសេចក្តីសម្រេចរបស់បុគ្គលថ្នាក់កំពូល ។ បន្ទាប់មកលោកបានឆ្លើយនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាថា ដំណែងរបស់ ឡឿន ពិតជាត្រូវបានជំនួសបុគ្គលផ្សេង ក្រោយពេលចាប់ខ្លួន ។

**២.១.២៣) ការចាប់ខ្លួន ហ៊ូ នឹម**

ដោយដកស្រង់ចេញពីសៀវភៅ សំឡេងពីមន្ទីរស-២១ ដដែល លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការចាប់ខ្លួន ហ៊ូ នឹម ហៅ ភាស់ ដែលមានតួនាទីជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ ដោយសារ កុយ ធួន បានឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់ខ្លួន ។ តំណាងសហព្រះរាជអាជ្ញាបានស្នើឲ្យលោកសាស្ត្រាចារ្យ ធ្វើការពន្យល់ទាក់ទងនឹងតួនាទីរបស់ ហ៊ូ នឹម នៅក្នុងបក្ស និងអ្វីដែលជាចាំបាច់ដែលនាំឲ្យមានការចាប់ខ្លួនអ្នកផ្សេងទៀត ក្រោយការចាប់ខ្លួនរបស់ ហ៊ូ នឹម នោះ? សាស្ត្រាចារ្យបានបញ្ជាក់ថា ហ៊ូ នឹម គឺជាបុគ្គលមួយរូបក្នុងចំណោមបុគ្គលបីរូបដែលត្រូវបានហៅថា **“ខ្មោចទាំងបី”** ហើយមានតួនាទីក្នុងការដឹកនាំនៅក្នុងរដ្ឋាភិបាលរណសិរ្សរបស់សម្តេច សីហនុ ហើយខ្មោច២រូបផ្សេងទៀតគឺ ហ៊ូ យន់ និង ខៀវ សំផន ដែលត្រូវបានសន្មត់ថាស្លាប់បាត់ទៅហើយ ។ លោកបានបន្តទៀតថា នៅក្នុងចម្លើយសារភាពរបស់ខ្លួន ហ៊ូ នឹម មិនបានរៀបរាប់អំពីជីវិតអតីតកាលរបស់លោកឡើយ ហើយក៏មិនបានទម្លាក់កំហុសចំពោះនរណាម្នាក់ដែរ ។ ហ៊ូ នឹម ត្រូវបានឆ្លើយដាក់ដោយអ្នកដែលត្រូវបានចាប់ខ្លួនមកស-២១ អំពីស្ថានភាពក្រីក្រលំបាកនៅភូមិភាគពាយ័ព្យ ។ លោកបញ្ជាក់បន្ថែមថា ហ៊ូ នឹម គឺជាបុគ្គលដែលមានចំណេះដឹង និងតួនាទីខ្ពស់ជាង កុយ ធួន ។ ជីវិតរបស់ ហ៊ូ នឹម នៅក្នុងបក្សត្រូវបានលាក់បាំងយ៉ាងជិតនៅក្នុងអំឡុងទសវត្សរ៍១៩៦០ ប៉ុន្តែបានក្លាយជាទិសដៅ



ហ៊ូ នឹម (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់សម្តេច សីហនុ ដោយសារមានទំនាក់ទំនងជិតស្និតជាមួយសហគមន៍ចិននៅទីក្រុងភ្នំពេញ ។ នៅអំឡុងពេលនោះ ហ៊ូ នឹម បានចូលរួមនៅក្នុងចលនាម៉ៅនិយម ដែលជាហេតុផលមួយធ្វើឲ្យលោកត្រូវរត់ចូលព្រៃជាមួយ ខៀវ សំផន នៅក្នុងឆ្នាំ១៩៦៧ ។

**២.១.២៤) ការចាប់ខ្លួនអ្នកការទូត និងបញ្ញវន្ត**

ឆ្លើយតបនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញា ដែលស្នើសុំលោកសាស្ត្រាចារ្យធ្វើការពន្យល់ទាក់ទងនឹងការបោសសម្អាតអ្នកការទូត និងបញ្ញវន្ត ដែលគាំទ្រវៀតណាម និងសូវៀត និងអ្នកធ្វើការនៅក្នុងក្រសួងការបរទេស ។ លោកសាស្ត្រាចារ្យបានពន្យល់ថា របបកម្ពុជាប្រជាធិតេយ្យមិនដែលទុកចិត្តនរណាដែលខ្លួនមិនបានតាមដានមើលសកម្មភាពទេ ហើយជាពិសេសគឺអ្នកដែលរស់នៅបរទេស ។ លោកបន្ថែមថា អ្នកដែលត្រូវបានជ្រើសរើសឲ្យធ្វើការនៅក្នុងការងារការបរទេសនេះ គឺជាអ្នកដែលធ្លាប់បានរស់នៅបរទេស និងអ្នកដែលធ្លាប់មានបទពិសោធន៍ពីបរទេស ។ លោកសាស្ត្រាចារ្យមិនច្បាស់ទេថា តើការបោសសម្អាតអ្នកទាំងនោះដោយសារមូលហេតុអ្វីពិតប្រាកដ ប៉ុន្តែលោកគ្រាន់តែដឹងថា នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមមានបំណងផ្តាច់ទំនាក់ទំនងជាមួយប្រទេសវៀតណាម ។ ខ្មែរក្រហមបានហៅអ្នកដែលធ្វើការនៅវៀតណាមត្រឡប់មកវិញ ហើយបញ្ជូនទៅស-២១ បន្ទាប់មកខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះចោល ។ ចំណែកឯអ្នកដែលធ្វើការនៅប្រទេស ឡាវ និងប្រទេស ចិន មិនត្រូវបានហៅឲ្យត្រឡប់មកវិញឡើយ ។ ប៉ុន្តែសម្រាប់បុគ្គលដែលធ្លាប់ធ្វើការជាអ្នកការទូតនៅក្នុងរដ្ឋាភិបាលរួបរួមជាតិ និងរណសិរ្សរួបរួមជាតិកម្ពុជា ដែលត្រូវបានអនុញ្ញាតឲ្យធ្វើការនៅក្នុងមន្ទីរប-១ ចាប់ផ្តើមក្លាយជាជនគួរឲ្យសង្ស័យ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាដែលសួរថា តើស្ថាប័នណាដែលមានសិទ្ធិអំណាចក្នុងការចេញសេចក្តីសម្រេចឲ្យធ្វើការចាប់ខ្លួនមនុស្សដូចជានៅមន្ទីរប-១នេះ? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា មិនមានភស្តុតាងណាមួយបញ្ជាក់ច្បាស់អំពីបញ្ហានេះទេ ប៉ុន្តែលោកយល់ថា ជនជាប់ចោទ អៀង សារី ពិតជាបានដឹងអំពីការចាប់ខ្លួនអ្នកការទូតនិងបុគ្គលិកចេញពីមន្ទីរប-១ ដោយសារពេលនោះ អៀង សារី មានតួនាទីជារដ្ឋមន្ត្រី ហើយមុនពេល ឬក្រោយពេលចាប់ខ្លួនមានការ



(រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បញ្ជូនព័ត៌មានឬចម្លងជូន អៀង សារី ។ ដូច្នេះ អៀង សារី មិនអាចបដិសេធថាមិនបានដឹងអំពីការចាប់ខ្លួនឡើយ ។

### ២.១.២៥) ការបោសសម្អាតក្រុម "ក្បាលយួន ខ្លួនខ្មែរ"

លោក ជារីក បានបន្តសួរអំពីសៀវភៅ សំឡេងពីមន្ទីរស-២១ នៅត្រង់ផ្នែកដែលនិយាយអំពីការបោសសម្អាតក្រុមដែលត្រូវបានខ្មែរក្រហមចោទថា ជា "ពួកក្បាលយួន ខ្លួនខ្មែរ" និងការបង្ខំឲ្យអ្នកទោសថ្វាយបង្គំរូបគំនូរដែលមានក្បាលហូជីមិញ ហើយខ្លួនជាសត្វឆ្កែ ។ លោកសាស្ត្រាចារ្យបានបានបញ្ជាក់ថា នៅពាក់កណ្តាលឆ្នាំ១៩៧៨ ប្រជាជនកម្ពុជាបានដឹងអំពីការជាឈ្លានពានរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា ហើយនិងការជ្រៀតចូលដោយសម្ងាត់នៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៧៧ ។ ហេតុការណ៍នេះបានធ្វើឲ្យលេចចេញនូវរឿងពីរ ។ ទីមួយ គឺផ្លាស់ប្តូរទិសដៅរបស់បក្សពីការបោសសម្អាតផ្ទៃក្នុងបក្សនៅភូមិភាគបស្ចិម និងក្រុមបញ្ញាវន្ត មកផ្តោតលើជនជាតិភាគតិចរបស់វៀតណាម និងអ្នកដែលពាក់ព័ន្ធនៅក្នុងការវាយប្រហារមកលើរបបខ្មែរក្រហម ។ ទីពីរ ការវាយប្រហាររបស់ខ្មែរក្រហមឆ្លងព្រំដែននៅក្នុងឆ្នាំ១៩៧៧ ដែលជាកាយវិការបង្កហេតុនាំឲ្យមានសង្គ្រាមនោះ បានធ្វើឲ្យមានការវាយច្បាំងរុញគ្នាទៅវិញទៅមកនៅតាមព្រំដែន ។ សង្គ្រាមជាមួយវៀតណាម បានធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យមានការធ្លាក់ចុះខ្សោយ និងបង្កឲ្យមានការភ័យខ្លាច ជាហេតុធ្វើឲ្យការបោសសម្អាតមានកាន់តែខ្លាំង ។ ភ្ជាប់នឹងបញ្ហាការបោសសម្អាតក្រុមដែលត្រូវបានចាត់ទុកថាជា "ពួកក្បាលយួន ខ្លួនខ្មែរ" លោកតំណាងសហព្រះរាជអាជ្ញាបានលើកយកសេចក្តីថ្លែងការណ៍ជាសាធារណៈមួយរបស់ ខៀវ សំផន ដែលបានថ្លែងនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ទាក់ទងនឹងការលើកទឹកចិត្តឲ្យប្រជាជនចូលរួមការពារបដិវត្តន៍ ដោយរារាំងការឈ្លានពាន និងការជ្រៀតជ្រែក និងការធ្វើវិទ្ធង្សនារបស់សត្រូវកម្ពុជាប្រជាធិបតេយ្យ ។ លោកតំណាងសហព្រះរាជអាជ្ញា ជារីក បានស្នើឲ្យលោកសាស្ត្រាចារ្យពន្យល់ថា តើសេចក្តីថ្លែងការណ៍នោះមានពាក់ព័ន្ធនឹងគោលបំណងនៃការរៀបចំ និងការពិភាក្សាអំពីខ្មាំងដែរឬទេ? លោកបានបញ្ជាក់ដោយខ្លីៗថា សេចក្តីថ្លែងការណ៍នោះពិតជាមានគោលបំណងក្នុងការរៀបចំ និងពិភាក្សាអំពីខ្មាំង ។

### ២.១.២៦) នរណាជា "បងនួន បងលេខ២ ឬបងទី២"

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ជារីក បានលើកយកចម្លើយសារភាពចំនួនបីរបស់ឈ្មោះ ដូក ញ៉ៅ, ចាប មិត លេខាស្រុកខ្សាច់កណ្តាល តំបន់២២ ភូមិភាគបូព៌ា និង គង់ គៀន ហៅ អ៊ីង វេត ដើម្បីឲ្យសាស្ត្រាចារ្យ ឆេនដល័រ អាន និងធ្វើការបញ្ជាក់ ។ ចំណារលើចម្លើយសារភាព ដូត ញ៉ៅ គឺមានពាក្យថា **ជូនបង នួន** ហើយនៅលើចម្លើយសារភាពរបស់ ចាប មិត ក៏មានចំណារថា **ជូនបងលេខ២** ។ លោកបញ្ជាក់ថា បងលេខ២ គឺជាឈ្មោះដែលកំណត់សម្រាប់ នួន ជា ។ ទាក់ទងនឹងចម្លើយសារភាពទីបីរបស់ គង់ គៀន ហៅ អ៊ីង វេត មានសរសេរថា **ជូន បង នួន មួយច្បាប់** ។ លោកបន្តថា **បង នួន** និង **បងទី២** គឺជាពាក្យដោយឡែកពីគ្នាដែលប្រើប្រាស់ដោយកម្មាភិបាលនៅពេលអ្នកទាំងនោះផ្ញើឯកសារជូន នួន ជា ។ ឯកសារភាគច្រើនត្រូវបានចម្លងជូនមួយច្បាប់ទៅ នួន ជា ហើយបងទី២ គឺ នួន ជា ជាអ្នកផ្តល់ការណែនាំដល់ សុន សេន និងបញ្ជូនបន្តទៅ ឌុច ហើយបន្ទាប់មកបញ្ជូនបន្តទៅកម្មាភិបាលថ្នាក់ក្រោមបន្តទៀត បន្ទាប់ពី នួន ជា បានពិនិត្យមើលចម្លើយសារភាពទាំងអស់រួចហើយ ។

### ២.១.២៧) ទំនាក់ទំនងរវាងស-២១ និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ជារីក បានស្នើសុំការពន្យល់ពីលោកសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងទំនាក់ទំនងរវាងមន្ទីរស-២១ និងថ្នាក់លើនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកសាស្ត្រាចារ្យបានពន្យល់ថា ចម្លើយសារភាពមួយចំនួនត្រូវបានផ្ញើជូន សុន សេន ហើយចម្លើយសារភាពទាំងនោះត្រូវបានរកឃើញនៅក្នុងបណ្ណសារនៃក្រសួងការពារប្រទេស និងនៅក្នុងបណ្ណសារផ្ទាល់ខ្លួនរបស់ សុន សេន បន្ទាប់មក សុន សេន បានផ្ញើចម្លើយសារភាពទាំងអស់នោះទៅថ្នាក់លើ គឺទៅគណៈមជ្ឈិម ដោយសារ សុន សេន គឺជាសមាជិកជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យស្រាប់ ។ លោកបានអះអាងថា ចំណារដែលមាននៅលើឯកសារចម្លើយសារភាពនោះ លោកមិនដឹងច្បាស់ថាជារបស់ សុន សេន ឬជាចំណាររបស់នរណាឡើយ ដែលបានសរសេរថា ផ្ញើជូនបងនួនមួយច្បាប់ឬនៅក្នុងករណីមួយចំនួនទៀត

មានសរសេរថា ផ្ញើជូនមួយច្បាប់រួមជាមួយបងវ៉ន ឬផ្ញើជូនបងប៉ុល ដែលលោកគិតថា ប៉ុល គឺជាឈ្មោះ របស់ ប៉ុល ពត ។ លោកបាន បន្ថែមថា លោកមិនបានដឹងថា តើចម្លើយសារភាពទាំងអស់នោះ ត្រូវបានអាន ឬយ៉ាងណានោះទេ ប៉ុន្តែអ្វីដែលលោកដឹង ចម្លើយ សារភាពទាំងនោះប្រហែលជាត្រូវបានផ្ញើចេញ ប៉ុន្តែមិនត្រូវ បានទទួល ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបាន លើកយកឯកសារទាក់ទងនឹងសំបុត្ររបស់ ហ៊ូ នឹម ដែលបាន សរសេរនៅពេលដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅស-២១ ដើម្បី ស្នើសុំឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់ ។ ឃ្លាមួយនៃសំបុត្រ នោះមានខ្លឹមសារថាៈ

*“គោរពបក្សកុម្មុយនីស្តកម្ពុជាលើសពីជីវិតខ្ញុំ ។ គោរព បងប៉ុល, បង នួន, បងវ៉ាន់, បងវ៉ន, សមមិត្ត ខៀវ, សមមិត្ត ហែម ជាទីគោរពស្នេហា! ។ ថ្ងៃនេះ ១០មេសា ឆ្នាំ ១៩៧៧ ពេលដែល ខ្ញុំកំពុងមមាញឹករៀបចំកម្មវិធីផ្សាយវិទ្យុទទួលអំណរបុណ្យខួបទីពីរ នៃមហាជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ តាមទូរស័ព្ទ មិត្ត ប៉ង់ បានហៅខ្ញុំមកធ្វើការជាមួយអង្គការ ។ ពេលមិត្តយុទ្ធជនចាប់ខ្ញុំ ខ្ញុំភ្ញាក់ក្រញាង ខ្ញុំមិនស្មានយ៉ាងនេះសោះ ។*

*ខ្ញុំព្យាយាមបញ្ជាក់ពីភាពស្មោះត្រង់របស់ខ្ញុំជូនអង្គការ ដើម្បីឲ្យអង្គការវិនិច្ឆ័យខ្ញុំ ។ ខ្ញុំធានាចំពោះអង្គការថា ខ្ញុំមិនដែល ក្បត់អង្គការទេ ខ្ញុំមិនពាក់ព័ន្ធជាមួយសេ.អ៊ី.អា នោះទេ ឬក៏ពាក់ព័ន្ធ ជាមួយនឹងភ្នាក់ងារ សុីង ស៊ុំកថាញ់ នោះទេ” ។*

លោកតំណាងសហព្រះរាជអាជ្ញាបានសួរថា តើសំបុត្រ ខាងលើមានសារៈសំខាន់អ្វីដែល ហ៊ូ នឹម ត្រូវផ្ញើជូនអ្នកដែលមាន ឈ្មោះនៅក្នុងសំបុត្រនោះ? លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ ថា ឈ្មោះទាំងអស់ដែលមានក្នុងសំបុត្រនោះ គឺជាឈ្មោះបដិវត្តន៍ របស់សមាជិកគណៈមជ្ឈិមដែលមានចាប់ពី ប៉ុល ពត រហូតដល់ ខៀវ សំផន ។ ហ៊ូ នឹម គឺជាអ្នកដែលមានតួនាទីខ្ពស់នៅក្នុងគណៈមជ្ឈិម ហើយក៏ជាអ្នកដែលដឹងអំពីការងាររបស់បក្ស ។ ចំណុចដែល សំខាន់នៅក្នុងសំបុត្រនោះ គឺជាការសរសេរសុំការអភ័យទោស ពីថ្នាក់ដឹកនាំខាងលើ ប៉ុន្តែលិខិតដូច្នេះមិនដែលត្រូវបានបញ្ជូន ទៅដល់ថ្នាក់លើនោះទេ គឺត្រូវបានយកទុកនៅក្នុងសំណុំឯកសារ របស់ស-២១ប៉ុណ្ណោះ ។ ដូច្នេះឯកសារដែលបង្ហាញ គឺជា ឯកសារដើមដែលចេញពីមន្ទីរស-២១ ។ លោកបន្តថា បុគ្គល ដែលចូលដល់មន្ទីរស-២១ គឺពុំមានឱកាសនឹងផ្ញើលិខិតទៅកាន់ ថ្នាក់លើបានទេ ។

### ២.ខ.២៨) ការទទួលខុសត្រូវជាសមូហភាពនៃថ្នាក់លើ

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ថារីក ទាក់ទងនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ការដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានលក្ខណៈជាសមូហភាព ហើយសេចក្តីសម្រេចដែលចេញពី ប៉ុល ពត គឺជាសេចក្តីសម្រេចចុងក្រោយ ។ ដូច្នេះ ប៉ុល ពត គឺជា ថ្នាក់ដឹកនាំនៅក្នុងស្ថាប័ននីតិប្រតិបត្តិក្នុងប្រទេស ដោយមាន ប្រជាជនកម្ពុជាជាច្រើនបានហៅរបបនោះថា ជា *“របប ប៉ុល ពត”* ។

## ៣) ការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដល័រ ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ បន្ទាប់ពីសហ ព្រះរាជអាជ្ញាបានបញ្ចប់ការសាកសួររបស់ខ្លួន សហមេធាវីនាំមុខ ជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ ត្រូវបាន អង្គជំនុំជម្រះប្រគល់វេទិកាសួរដេញដោលលោកសាស្ត្រាចារ្យ ឆេនដល័រ ដើម្បីសាកសួរទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រនៃ ប្រទេសកម្ពុជា និងសៀវភៅដែលលោកបានសរសេរទាក់ទង ប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ពេជ អង្គ បានប្រគល់វេទិកាបន្តជូនលោកមេធាវី ហុង គីមសួន ដែលជា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីសាកសួរលោក សាស្ត្រាចារ្យ ឆេនដល័រ បរិបទនៃប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ។

### ៣.ក) ការសួរដេញដោលដោយមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

#### ៣.ក.១) ទំនាក់ទំនងរវាងបក្សប្រជាជនបដិវត្តន៍ខ្មែរ និងក្រុមឥស្សរៈ

សំណួរដំបូងរបស់លោកមេធាវី គីមសួន បានសួរទាក់ទង បក្សប្រជាជនបដិវត្តខ្មែរ ថាតើបក្សប្រជាជនបដិវត្តន៍ខ្មែរមាន ទំនាក់ទំនងអ្វីខ្លះជាមួយនឹងក្រុមខ្មែរឥស្សរៈនៅពេលកកើតដំបូងចន្លោះ ឆ្នាំ១៩៤៧ និងឆ្នាំ១៩៤៨? លោកសាស្ត្រាចារ្យ ឆេនដល័រ



មេធាវី ហុង គីមសួន

បានបញ្ជាក់ថា នៅអំឡុងនៃរយៈកាលនោះបក្សប្រជាជនបដិវត្តខ្មែរមិនទាន់ត្រូវបានបង្កើតនៅឡើយទេ ។ ក្រុមឥស្សរៈមានទំនាក់ទំនងជាមួយនឹងក្រុមផ្សេងៗគ្នា ដែលក្រុមខ្លះមានការគាំទ្រពីសំណាក់ប្រទេសថៃក្រុមខ្លះមានការគាំទ្រពីអ្នកនៅក្នុងស្រុក និងក្រុមខ្លះមានការគាំទ្រពីបក្សកុម្មុយនីស្តឥណ្ឌូចិន ។ លោកបន្តថាបក្សប្រជាជនបដិវត្តខ្មែរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥១ ដោយមានការរួមបញ្ចូលគ្នាពីសំណាក់ក្រុមទាំងបីខាងលើ ក្នុងគោលបំណងធ្វើការទាមទារឯករាជ្យកម្ពុជាពីប្រទេសបារាំង ។ នៅក្នុងកំណត់ត្រាបានបញ្ជាក់យ៉ាងច្បាស់ថា បក្សប្រជាជនបដិវត្តខ្មែរត្រូវបានបង្កើតឡើង ដោយមានការគាំទ្រពីប្រទេសវៀតណាម ហើយអ្នកដឹកនាំបក្សនេះគឺជនជាតិខ្មែរដែលទទួលរងឥទ្ធិពលពីប្រទេសវៀតណាម ។ រយៈពេលជាច្រើនឆ្នាំបក្សនេះបានធ្វើការជាមួយបក្សកុម្មុយនីស្តឥណ្ឌូចិនដែលជាអាវុធនយោបាយមួយនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ ដោយមានការជំរុញពីវៀតណាមឲ្យតស៊ូប្រឆាំងជាមួយនឹងបារាំង ។ លោកសាស្ត្រាចារ្យបានបន្តទៀតថា គោលបំណងមួយក្នុងចំណោមគោលបំណងជាច្រើនរបស់បក្សនេះ គឺចូលរួមជាមួយប្រទេសវៀតណាម និងឡាវ នៅក្នុងសហព័ន្ធឥណ្ឌូចិនដើម្បីតស៊ូប្រឆាំងនឹងបារាំង ។ លោកបានទទួលស្គាល់ថា ចម្លើយរបស់លោកហាក់បីដូចជាលម្អិត ប៉ុន្តែ ដើម្បីឆ្លើយតបនឹងសំណួរដែលមានសភាពស្មុគស្មាញ និងរៀបរាប់អំពីឫសគល់នៃបក្សកុម្មុយនីស្តកម្ពុជា លោកត្រូវតែបរិយាយលម្អិត ។

លោកមេធាវីបានបន្តសួរសំណួរសាស្ត្រាចារ្យ ឆេនដល័រ ទៀតថា តើមានឥស្សរជនដែលតស៊ូក្នុងសម័យខ្មែរឥស្សរៈបានក្លាយខ្លួនជាសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជានៅក្រោយពេលកម្ពុជាទទួលបានឯករាជ្យពីប្រទេសបារាំងដែរឬទេ? សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមិនគិតថាអ្នកទាំងឡាយដែលសកម្មនៅក្នុងចលនាខ្មែរឥស្សរៈដែលគាំទ្រដោយប្រទេសថៃ ឬកម្ពុជា ក្រោយមកបានក្លាយជាសមាជិកសំខាន់នៃបក្សកុម្មុយនីស្តកម្ពុជាទេ ។ ទូ សាមុត និង សឺង ង៉ុកមិញ ជាអ្នកដែលមកពីវៀតណាមភាគខាងត្បូង ធ្លាប់ស្ថិតនៅក្នុងចលនាដែលគាំទ្រដោយវៀតណាម ប៉ុន្តែនៅពេលនោះបក្សពុំទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ។ ទូ សាមុត ក្រោយមកបានក្លាយជាលេខាបក្សរហូតដល់ពេលបាត់ខ្លួន និងអាចត្រូវសន្មត់បានថា ត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៦២ ។ បន្ទាប់មកលោកមេធាវី គីមសួន បានបន្ត សំណួររបស់ខ្លួនទៀតថា តើ ស៊ីវ ហេង និង ឡុង ប៊ុនរួត ដែលក្រោយមកមានឈ្មោះថា នួន ជា បានក្លាយខ្លួនពីខ្មែរឥស្សរៈមកជាសកម្មជន ឬមន្ត្រីបក្សកុម្មុយនីស្តកម្ពុជាមែនដែរឬទេ? លោកសាស្ត្រាចារ្យបានឆ្លើយថា ឡុង ប៊ុនរួត ដែលមានឈ្មោះថា នួន ជា បានត្រឡប់មកពីប្រទេសថៃ ដើម្បីចូលរួមជួយ នៅក្នុងចលនាប្រឆាំងប្រហែលជានៅក្នុងឆ្នាំ ១៩៤៩ ឬ១៩៥០ ។ នួន ជា គឺសមាជិកមួយរូបនៃបក្សកុម្មុយនីស្តថៃ និងជាសមាជិកធ្វើការយ៉ាងសកម្មដោយមានការគាំទ្រពីរដ្ឋាភិបាលថៃដើម្បីធ្វើការប្រឆាំងនឹងប្រទេសបារាំង ។ លោកបន្តថា នួន ជា គឺជាបុគ្គលស្នេហាជាតិមួយរូបដែលចំណាយពេលយ៉ាងច្រើននៅក្នុងប្រទេសថៃ និងមើលឃើញពីភាពអយុត្តិធម៌ អំពើឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងសម័យកាលអាណានិគមបារាំង ដែលធ្វើឲ្យ នួន ជា សម្រេចចិត្តចូលរួមនៅក្នុងចលនាប្រឆាំងនឹងអាណានិគមបារាំង ។

### ៣.ក.២) ការបាត់ខ្លួន ទូ សាមុត

លោកមេធាវី គីមសួន បានបន្តសួរទាក់ទងនឹងការបាត់ខ្លួន ទូ សាមុត ដោយចោទសួរលោកសាស្ត្រាចារ្យថា តើមានហេតុការណ៍អ្វីកើតឡើងជុំវិញការបាត់ខ្លួន ទូ សាមុត នៅក្នុងឆ្នាំ១៩៦២? លោក សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមានការ

លំបាកក្នុងការឆ្លើយតបចំពោះសំណួរនេះ ប៉ុន្តែលោកអាចជម្រាបបានថា ការបាត់ខ្លួនរបស់ ទូ សាមុត ដែលជាលេខាបក្សពលករកម្ពុជានៅក្នុងឆ្នាំ១៩៦២ ត្រូវបានសន្មត់ជាទូទៅថាបណ្តាលមកពីប៉ូលីសរបស់សម្តេច សីហនុ ចាប់ខ្លួនយកទៅសម្លាប់ ។ ប្រជាជនដែលស្គាល់ ទូ សាមុត តែងតែនិយាយអំពីភក្តីភាពរបស់ ទូ សាមុត ចំពោះចលនាកុម្មុយនីស្ត ។ លោកបន្តថា មានអ្នកស្រាវជ្រាវអំពីរបប ប៉ុល ពត មួយចំនួនបានសរសេរថា ប៉ុល ពត បានជាប់ទាក់ទងជាមួយនឹងការបាត់ខ្លួនរបស់ ទូ សាមុត ។ ប៉ុន្តែលោកយល់ថា ការលើកឡើងដូច្នេះ គឺមិនទំនងទាល់តែសោះ ហើយក៏មិនទាន់មានការសិក្សាស្រាវជ្រាវណាមួយ បានឈានដល់ការធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានេះ ចាប់តាំងពីព្រឹត្តិការណ៍នោះបានកើតឡើងដែរ ។ បន្ទាប់មក លោកមេធាវី គឹមសួន បន្តសួរទៀតថា តើមូលហេតុអ្វីបានជា នួន ជា ដែលជាអ្នកស្និទ្ធជាមួយនឹង ទូ សាមុត មិនឡើងធ្វើជាលេខាបក្សជំនួស ទូ សាមុត ក្រោយការបាត់ខ្លួន តែបែរជា ប៉ុល ពត ឡើងជំនួសទៅវិញ? ឆ្លើយតបនឹងសំណួរនេះ សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា បញ្ហានេះនៅតែជាអាថ៌កំបាំង ប៉ុន្តែដែលលោកអាចបញ្ជាក់បាន គឺថាដោយសារប្រវត្តិរូបរបស់ នួន ជា ដែលរារាំងមិនឲ្យ នួន ជា ឡើងធ្វើជាលេខាបក្សតាមឋានានុក្រម ។ លោកសាស្ត្រាចារ្យយល់ថា បញ្ហានេះគឺមិនធ្ងន់ធ្ងររហូតដល់ធ្វើឲ្យប៉ះពាល់ដល់ការឡើងបន្តតំណែងពី ទូ សាមុត ទេ ព្រោះឆន្ទៈ និងសមត្ថភាពក្នុងការធ្វើការជាបុគ្គលទី២ ឬអនុលេខាបក្សរបស់ នួន ជា ដែលស្មោះស្ម័គ្រជាមួយនឹងចលនាកុម្មុយនីស្តអន្តរជាតិ និងចំពោះបក្សកុម្មុយនីស្តកម្ពុជា គឺអាចឲ្យ នួន ជា យកឈ្នះចំពោះលទ្ធភាពដែលថាខ្លួនមិនអាចចូលកាន់តំណែងជាអ្នកបញ្ជាបក្សនៅក្នុងប្រទេសកម្ពុជាបាន ។

### ៣.ក.៣) មូលហេតុនាំឲ្យមានការរត់ចូលព្រៃរបស់ក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា

ទាក់ទងនឹងការរត់ចូលព្រៃរបស់ក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា លោកមេធាវី គឹមសួន បានចោទសួរសាស្ត្រាចារ្យ ឆេនដល័រ ថា តើមានមូលហេតុអ្វីខ្លះដែលនាំឲ្យមានការរត់ចូលព្រៃរបស់ក្រុមមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅអំឡុងសម័យកាលនៃរបបសង្គមរាស្ត្រនិយមចន្លោះឆ្នាំ១៩៦០ និង៧០? និងថា តើសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាណាខ្លះដែលបានរត់ចូលព្រៃនៅពេលនោះ? ឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា សម្តេចសីហនុនៅពេលនោះទ្រង់មិនដឹងថានរណាជាអ្នកគ្រប់គ្រងបក្សកុម្មុយនីស្តកម្ពុជាទេ ហើយទ្រង់ក៏មិនបានដឹងអំពីការរៀបចំចាត់ចែងនៅក្នុងបក្សកុម្មុយនីស្តនោះដែរ ។ ព្រះអង្គដឹងត្រឹមតែថាមានក្រុមខ្មែរក្រហម ប៉ុន្តែទ្រង់មិនបានស្គាល់អ្នកទាំងនោះឡើយ ។ លោកសាស្ត្រាចារ្យបានបន្តថា ប្រហែលជានៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦៣ នៅក្នុងសុន្ទរកថាមួយរបស់ទ្រង់ សម្តេច សីហនុ បានអានឈ្មោះជនឆ្វេងនិយមទាំង៣៤រូប ដែលលោក លន់ នល់ បានប្រគល់បញ្ជីឈ្មោះជូនព្រះអង្គ ហើយព្រះអង្គបានអញ្ជើញអ្នកទាំង៣៤រូបនោះដើម្បីបង្កើតរដ្ឋាភិបាល និងចូលកាន់តំណែងរបស់ព្រះអង្គ ។ ក្នុងចំណោមអ្នកទាំង៣៤រូបនោះ រួមមាន ប៉ុល ពត, អៀង សារី ដែលបង្រៀននៅសាលាឯកជនមួយនៅក្នុងទីក្រុងភ្នំពេញ ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងបក្ស



ប៉ុល ពត និង

កុម្មុយនីស្ត ។ សុន សេន ក៏ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះអ្នកទាំង៣៨នាក់នោះដែរ ។ អ្នកទាំងបីរូបនេះបានរត់ទៅភូមិភាគបូព៌ានៃប្រទេសកម្ពុជាភ្លាមៗបន្ទាប់ពីមានការប្រកាសនោះ ដោយស្នាក់នៅក្នុងមូលដ្ឋានយោធារបស់ប្រទេសវៀតណាមកុម្មុយនីស្ត ។ លោកបានបញ្ជាក់ទៀតថា លោកមិនចាំឈ្មោះអ្នកទាំង៣៨នាក់នោះទេ ប៉ុន្តែអ្វីដែលលោកមានការចាប់អារម្មណ៍ គឺមានបុគ្គលពីររូបមិនបានរត់ទៅក្នុងព្រៃទេ ។ អ្នកទាំងពីររូបនោះគឺ ខៀវ សំផន



នួន ជា ពេលគេស៊ូនៅក្នុងព្រៃ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និង នួន ជា ។ ខៀវ សំផន មិនរត់ចូលព្រៃនៅពេលនោះ ដោយសារតែខ្លួនមានតំណែង និងមានការធានាចំពោះអនាគតរបស់ខ្លួននៅទីក្រុងភ្នំពេញ ចំណែកឯ នួន ជា វិញ គឺមិនមានឈ្មោះនៅក្នុងចំណោមអ្នកទាំង៣៨រូបនោះ ។ លោកសាស្ត្រាចារ្យ បានពន្យល់បន្ថែមថា នួន ជា និង ប៉ុល ពត បានយល់ស្របជាមួយគ្នាថា អ្នកដែលមិនមានឈ្មោះនៅក្នុងបញ្ជីរបស់សម្តេច សីហនុ ត្រូវតែបន្តធ្វើសកម្មភាពសម្រាប់បក្សនៅទីក្រុងដើម្បីធ្វើការទាក់ទងគ្នា ។ លោកបានគត់សម្គាល់ថា នៅពេលបន្ទាប់មកទៀត ខៀវ សំផន ក៏បានរត់ចូលក្នុងព្រៃដែរ ។

ឆ្លើយតបចំពោះសំណួររបស់លោកមេធាវី គីមសួន ដែលសួរថា តើមានការធ្វើទុក្ខបុកម្នេញ ឬការចាប់ខ្លួនក្រោមរដ្ឋាភិបាលរបស់សម្តេចសីហនុនៅចន្លោះឆ្នាំ១៩៦០ និង១៩៧០ ដែរឬទេ? លោកសាស្ត្រចារ្យ ឆេនដល័រ បានអះអាងថា ពិតជាមាន ដោយនៅក្នុងឆ្នាំ១៩៦៧ មានការបះបោរនៅសំឡូតដែលបណ្តាលឲ្យមានការកាប់សម្លាប់យ៉ាងរង្គាល ។ មានសិស្សសមាគមអ្នកគាំទ្រប្រទេសចិននៅទីក្រុងភ្នំពេញ ដែលយកគំរូតាមបដិវត្តន៍វប្បធម៌របស់ម៉ៅ សេទុង ត្រូវទទួលរងការធ្វើទុកបុកម្នេញ ការធ្វើបាប ឬត្រូវបានចាប់ដាក់គុក ហើយ ឌុច ក៏ត្រូវបានចាប់ដាក់គុកនៅសម័យនោះដែរ ។ លោកសាស្ត្រាចារ្យបានសង្កត់ធ្ងន់ថា អ្នកទាំង៣៨រូបដែលមាននៅក្នុងបញ្ជីនោះ មិនទាន់ត្រូវបានបញ្ជាក់ថាសុទ្ធតែជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ អ្នកទាំង៣៨នាក់នោះ ត្រូវបានហៅថា ជនដែលបង្កគ្រោះថ្នាក់ដល់សង្គមកម្ពុជា និងជាជនឆ្វេងនិយម ដោយនៅក្នុងនោះក៏មានអ្នកកាសែត សមាជិករដ្ឋសភា ដូចជា ខៀវ សំផន ជាដើម ។

**កំណត់សម្គាល់៖** នៅអំឡុងពេលនៃការសួរដេញដោលរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ហុង គីមសួន លើលោកសាស្ត្រាចារ្យ ឆេនដល័រ មេធាវីជាតិការពារក្តី អៀង សារី គឺលោក អាង ឧត្តម បានលើកសំណើជូនអង្គជំនុំជម្រះដើម្បីស្នើសុំឲ្យលោកសាស្ត្រាចារ្យប្រគល់ជូននូវកំណត់ត្រា ឬកំណត់ហេតុសរសេរដៃរបស់លោក ដល់អង្គជំនុំជម្រះដើម្បីទុកក្នុងសំណុំរឿង ។ លោកមេធាវីបានអះអាងថា ការស្នើសុំរបស់ខ្លួន មិនខុសគ្នានឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំកំណត់ហេតុសរសេរដៃពីជនជាប់ចោទ នួន ជា នៅខណៈពេលដែល នួន ជា អានកំណត់ត្រាសរសេរដៃរបស់ខ្លួននៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ។ ប៉ុន្តែសំណើនេះត្រូវបានអង្គជំនុំជម្រះបដិសេធ ។

### ៣.ក.៤) បក្សកុម្មុយនីស្តកម្ពុជាយកសម្តេចសីហនុជាខែល?

បន្ទាប់មកលោកមេធាវី ហុង គីមសួន បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានបញ្ជូន អៀង សារី ទៅទីក្រុងប៉េកាំងជួបជាមួយសម្តេច

សីហនុ នៅឆ្នាំ១៩៧១ ថាតើនយោបាយនោះ គឺជាការគ្រោងទុករបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងយកសម្តេច សីហនុ ធ្វើជាខែលឬយ៉ាងណា? ភ្ជាប់នឹងសំណួរនេះ លោកមេធាវីបានអានឃ្លាមួយនៃឯកសាររបស់ខ្មែរក្រហមដែលចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ ស្តីអំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស ដើម្បីឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់ ។ ឃ្លានោះបានសរសេរថាៈ

*"សីហនុក៏បានក្តាប់បាន ដោយគាត់គ្មានអ្វីទាំងអស់ ទាំងសេដ្ឋកិច្ច ទាំងអំណាច ។ ដូច្នេះត្រូវរណបយើង ទាំងស្រុង ទាំងសម្ភារៈ ទាំងនយោបាយ ។ បើប្រៀបធៀបទៅ គាត់នៅតែមានឥទ្ធិពលជាងអ្នកដទៃ ។ ពីមុនយើងហ៊ានថា បើចេញពីយើង គាត់ត្រូវស្លាប់ ដល់ឥឡូវយើងក្តាប់គាត់បានច្រើនជាងមុន ដោយយើងឈ្នះខ្លាំង យើងមានអ្វីៗទាំងអស់ អ្វីក៏នៅលើយើង រហូតដល់វាំង ក៏ជាវាំងយើង ក៏ប៉ុន្តែយើងដំណើរការជាមួយគាត់បានស្រួល ។ បច្ចុប្បន្នគាត់ឃើញថា គាត់នៅជាមួយយើងបាន បើប៉ុណ្ណឹងគាត់ពេញចិត្តហើយ ឲ្យតែបាននៅក្នុងប្រទេសខ្លះ ទៅក្រៅប្រទេសខ្លះ ។ នេះជាសភាពការណ៍ដែលពន្យាពេលឲ្យយើងពង្រឹង និងពង្រីកកម្លាំងយើងបាន បើថ្ងៃក្រោយគាត់ប្រែប្រួល យើងប្រដូចគាត់បានទៅនឹងក្រមរ គឺជ្រុះឯង គ្មាននរណាធ្វើអ្វីទេ ដោយគ្មានការឈឺចាប់ ។"*

ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា លោកមិនអាចអះអាងឲ្យបានច្បាស់ថា ការបញ្ជូនអៀងសារីឲ្យជួបជាមួយសម្តេច សីហនុ នៅទីក្រុងប៉េកាំង គឺជាការគ្រោងទុករបស់បក្សកុម្មុយនីស្តកម្ពុជាទេ ប៉ុន្តែខ្មែរក្រហមមិនដែលមានបំណងចង់ឲ្យទ្រង់ត្រឡប់មកកាន់ដំណែងវិញឡើយ ។

### ៣.ក.៤) ការរត់ចូលព្រៃម៉ាគីជាការបោកប្រាស់របស់ខ្មែរក្រហម ឬជានយោបាយសម្តេច សីហនុ?

លោកមេធាវី គឹមសួន បានស្នើសុំអង្គជំនុំជម្រះសួរសំណួរមួយចំពោះលោកសាស្ត្រាចារ្យ ដែលលោកអះអាងថា ជាចម្ងល់របស់ប្រជាជនកម្ពុជាទាក់ទងនឹងការរត់ចូលព្រៃម៉ាគី ថាតើការអំពាវនាវឲ្យចូលព្រៃម៉ាគី គឺជានយោបាយរបស់សម្តេចសីហនុ ឬជាការបោកប្រាស់របស់ខ្មែរក្រហម? ឆ្លើយតបសំណួរនេះ សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ចម្លើយគឺទាំងពីរ ។ លោកបានពន្យល់បន្ថែមថា ការអំពាវនាវនោះ គឺជាសម្តីផ្ទាល់របស់ព្រះអង្គ ហើយការអំពាវនាវនេះក៏មិនមែនខ្មែរក្រហមប្រាប់ព្រះអង្គឲ្យធ្វើដែរ ហើយក៏មិនមែនជាល្បិចកលទាំងស្រុងដែរ ។ ការអំពាវនាវរបស់ព្រះអង្គបានធ្វើឲ្យខ្មែរក្រហមកាន់តែមានប្រជាប្រិយភាព ដោយខ្មែរក្រហមគិតថាសម្តេច សីហនុ ទ្រង់មានប្រជាប្រិយភាពខ្ពស់នៅតាមទីជនបទ ហើយខ្មែរក្រហមគិតថាខ្លួនអាចទទួលបានការគាំទ្រកាន់តែខ្លាំងតាមរយៈការចូលរួមក្នុងរណសិរ្សដែលបង្កើតឡើងនៅទីក្រុង ប៉េកាំង ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកមិនបានដឹងច្បាស់ថា តើមានប្រជាជនប៉ុន្មាននាក់ដែលបានឮការអំពាវនាវរបស់ព្រះអង្គ ហើយប្រជាជនប៉ុន្មាននាក់ដែលធ្វើតាមការអំពាវនាវរបស់ព្រះអង្គ និងថាមាននរណាខ្លះដែលយល់ឃើញស្ថានការណ៍ពេលនោះ គឺធ្វើឲ្យខ្លួនមិនពេញចិត្ត និងចាកចេញពីចលនានោះវិញ ឬមានមនុស្សប៉ុន្មាននាក់ត្រូវបានសម្លាប់ទេ ។


ក្រុមយុវជន និងយុវនារី នៅក្នុងសន្និសីទមួយក្នុងខេត្តសៀមរាប

លោកបន្តថា មានប្រជាជនខ្លះបានពុការអំពាវនាវ ហើយអ្នកខ្លះបានទទួលយកការអំពាវនាវនោះ ប៉ុន្តែលោកមិនអាចបញ្ជាក់បានទេថា ការអំពាវនាវនោះមានប្រសិទ្ធភាពប៉ុណ្ណានោះទេ ។ លោកបានលើកឡើងពីព្រឹត្តការណ៍ជាក់ស្តែងមួយ ដែលបានកើតឡើងនៅខេត្តកំពង់ចាម ដែលមានការសម្លាប់ប្អូនប្រុសរបស់សេនាប្រមុខ លន់ នល់ ដោយសារលោកត្រូវបានចាត់ទុកថាជាអ្នកដែលចូលរួមបង្ករឲ្យមានបញ្ហាដូចជាបងប្រុសរបស់ខ្លួន ។

### ៣.ក.៦) គោលការណ៍៨ចំណុចរបស់ខ្មែរក្រហមមុនរំដោះទីក្រុងភ្នំពេញ

លោកមេធាវី គីមសួន បានស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់ទាក់ទងនឹងគោលការណ៍ ៨ចំណុចរបស់បក្សកុម្មុយនីស្តកម្ពុជាចុះថ្ងៃទី២០ ខែឧសភា ១៩៧៥ ដែលសម្រេចដោយគណៈមជ្ឈិម ។ គោលការណ៍ទាំង៨ចំណុចនោះរួមមាន៖

១) ជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ ។

២) លុបបំបាត់លុយផ្សារទាំងអស់ ។

៣) លុបបំបាត់រូបិយវត្ថុក្នុងរបប លន់ នល់ និងដកទុកនូវរូបិយវត្ថុបដិវត្តន៍ដែលទើបតែបោះពុម្ព ហើយ ។



ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៣ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៤) ផ្សឹកព្រះសង្ឃទាំងអស់ ហើយឲ្យព្រះសង្ឃទាំងនោះទៅធ្វើស្រែ ។

៥) សម្លាប់អ្នកដឹកនាំក្នុងរបប លន់ នល់ ទាំងអស់ ដោយចាប់ផ្តើមពីថ្នាក់ដឹកនាំកំពូលមុនគេ ។

៦) បង្កើតសហករណ៍ក្នុងកម្រិតខ្ពស់ទូទាំងប្រទេស ដោយឲ្យហូបបាយរួម ។

៧) បណ្តេញជនជាតិភាគតិចវៀតណាមឲ្យអស់ ។ និង

៨) ពង្រាយកងទ័ពតាមព្រំដែន ជាពិសេសព្រំដែនវៀតណាម ។

ឆ្លើយតបនឹងសំណើរបស់មេធាវី គីមសួន លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា គោលការណ៍ទាំង៨ចំណុចដែលបានដាក់ចេញ គឺត្រូវបានបង្ហាញយ៉ាងច្បាស់ ដោយគោលការណ៍ទាំងនេះត្រូវបានគោរពតាមនៅគ្រប់ករណីទាំងអស់ ។ ប៉ុន្តែមន្ត្រីនៃរបប លន់ នល់ ដែលត្រូវបានសម្លាប់មិនមានភាពច្បាស់លាស់នៅឡើយទេ ។ គោលនយោបាយនេះត្រូវបានគោរពពេលមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ ទាក់ទងនឹងការលុបបំបាត់រូបិយវត្ថុ លោកសាស្ត្រាចារ្យបានអះអាងថា សន្លឹករូបិយវត្ថុដែលត្រៀមសម្រាប់ប្រើប្រាស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបោះពុម្ពនៅប្រទេសចិន ប៉ុន្តែក្រោយមករបបកម្ពុជាប្រជាធិបតេយ្យបានសម្រេចចិត្តបដិសេធការប្រើប្រាស់រូបិយវត្ថុ ។

## ៣.ខ) ការសួរដេញដោលដោយមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

### ៣.ខ.១) គោលការណ៍រក្សាការណ៍សម្ងាត់របស់ខ្មែរក្រហម

លោកស្រី គ្រីស្ទីន ម៉ាទីណូ (Christin MARTINEAU) មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានសញ្ជាតិបារាំង ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាសួរដេញដោលលោកសាស្ត្រាចារ្យ ឆេនដល័រ ។ លោកស្រីមេធាវី ម៉ាទីណូ បានចាប់ផ្តើមសំណួរដំបូងរបស់លោកស្រីទាក់ទងនឹង "គោលការណ៍រក្សាការណ៍សម្ងាត់" របស់បក្សកុម្មុយនីស្តកម្ពុជា ដោយលោកស្រីមេធាវីបានសួរលោកសាស្ត្រាចារ្យថា មូលហេតុអ្វីបានជាគោលការណ៍រក្សាការសម្ងាត់នៅតែត្រូវបានយកមកអនុវត្តដោយខ្មែរក្រហមនៅក្រោយពេលដែលខ្លួនទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ?

លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា គោលការណ៍រក្សាការណ៍សម្ងាត់ គឺជាគោលការណ៍មួយចាំបាច់សម្រាប់មេដឹកនាំ ដោយសារនយោបាយនេះបានផ្ដល់ជោគជ័យតាំងពីយូរណាស់មកហើយដល់មេដឹកនាំទាំងនោះ និងជួយឲ្យមេដឹកនាំរបស់ខ្លួនគេចផុតពីការចាប់ដាក់គុកពីសំណាក់សម្ដេចសីហនុ ។

លោកស្រីមេធាវី ម៉ាទីណូ បានបន្តសួរទៀតថា អ្នកដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់ ព័ទ្ធជុំវិញដោយការណ៍សម្ងាត់ ប៉ុន្តែហេតុអ្វីបានជាប្រជាជនត្រូវបានដាក់ឲ្យស្ថិតនៅក្រោមសម្ងាតភាព ដោយមិនឲ្យមានការលាក់លៀមសម្ងាត់អ្វីចំពោះអង្គការទៅវិញ? តើនេះជាយុត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ឬយ៉ាងណា? សាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយតបនឹងសំណួរនេះថា តាមការពិតក្នុងចំណោមមេដឹកនាំរបស់បក្ស គឺមានតម្លាភាពចំពោះគ្នាទៅវិញទៅមក ដោយសារគ្រប់មេដឹកនាំបក្សទាំងអស់ត្រូវតែរៀបចំប្រវត្តិរូបរបស់ខ្លួន ដើម្បីទទួលបានការត្រួតពិនិត្យដោយមេដឹកនាំដទៃទៀត និងធ្វើស្វ័យតិតៀននៅក្នុងវគ្គសិក្សារៀនសូត្រ ដោយទាមទារឲ្យមានតម្លាភាពចំពោះគ្នាទៅវិញទៅមក ។ បក្សក៏ទាមទារឲ្យមានតម្លាភាពនៅក្នុងចំណោមប្រជាជន ដោយមិនត្រូវមានការស្ងាត់ស្ងៀមចំពោះបុគ្គលដែលមិនស្ថិតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ប្រជាជនត្រូវបានបង្ខំឲ្យមានតម្លាភាពចំពោះគ្នាទៅវិញទៅមកក្នុងវគ្គសិក្សារៀនសូត្រ ដោយត្រូវសរសេរប្រវត្តិរូប បន្ទាប់មកទើបត្រូវបានទុកចិត្ត ។ អ្នកដែលមានរក្សាការសម្ងាត់ គឺមិនត្រូវបានទុកចិត្ត ហើយអ្នកទាំងនោះនឹងត្រូវតម្រូវឲ្យលាតត្រដាងជូនអង្គការថាតើខ្លួនជានរណា និងធ្វើអ្វីខ្លះ ។ លោកបានបន្តទៀតថា តម្លាភាពនៅផ្ទៃក្នុងរបស់បក្ស គឺមានកម្រិតខ្ពស់បំផុត ដោយលើកឧទាហរណ៍ពីសំបុត្ររបស់ ហ៊ូ នឹម ដែលសរសេរទៅកាន់មេដឹកនាំបក្ស ដោយ ហ៊ូ នឹម បានដឹងអំពីរបៀបសរសេរជូនមេដឹកនាំទាំងនោះ ព្រោះខ្លួនគឺជាបុគ្គលស្ថិតក្នុងផ្ទៃក្នុងបក្ស ហើយគ្មាននរណាម្នាក់នៅក្នុងប្រទេសអាចប្រើប្រាស់ឈ្មោះមេដឹកនាំទាំងអស់នោះនៅក្នុងសំបុត្រតែមួយបានទេ ។

### ៣.១.២) អង្គការជានរណា?

លោកស្រីមេធាវី ម៉ាទីណូ បានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការពន្យល់ទាក់ទងនឹងពាក្យ "អង្គការ" ឬ "អង្គការដឹកនាំបក្ស" ។ លោកសាស្ត្រាចារ្យបានពន្យល់ថា ប្រជាជនមិនបានដឹងថា អង្គការជានរណានោះទេ ។ នៅពេលដែលលោកបានធ្វើសម្ភាសន៍ជាមួយអ្នកដែលនៅរស់រានមានជីវិតពីសម័យខ្មែរក្រហម អ្នកខ្លះយល់ថា អង្គការ គឺជាមនុស្ស ហើយអ្នកខ្លះយល់ថា អង្គការ ជាឈ្មោះស្ថាប័ន ឬឈ្មោះរបស់មនុស្ស ។ រីឯអ្នកខ្លះ ទៀតយល់ថា មានមនុស្សនៅពីក្រោយអង្គការ និងថាអង្គការមានភ្នែកច្រើនណាស់ដូចជាផ្លែម្នាស់ ។ លោកបន្តថា អង្គការអាចមើលឃើញអ្វីៗទាំងអស់ មើលឃើញអ្វីៗដែលកំពុងដំណើរការ និងមើលឃើញនរណាជានរណា ។ អ្នកខ្លះនៅតាមភូមិ ក៏ប៉ុន្តែតំណាងឲ្យបក្ស ហើយមិនមាននរណាដឹងថា អ្នកនោះគឺជានរណានោះទេ ។

### ៣.១.៣) ប្រជាជនថ្មីជាខ្មាំងទីមួយ

ឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងប្រជាជនថ្មីដែលត្រូវបានចោទប្រកាន់ថាជាខ្មាំង លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា បើនិយាយឲ្យស្រួលយល់ ប្រជាជនថ្មី គឺជាប្រជាជនដែលរស់នៅទីក្រុង និងមិនបានចូលរួមជាមួយបដិវត្តន៍ ហើយអ្នកទាំងនេះត្រូវបានចាត់ទុកថាជា ខ្មាំងឬ ជនក្បត់ចំពោះបក្សកុម្មុយនីស្តកម្ពុជា ។ ម្យ៉ាងវិញទៀត ប្រជាជនថ្មី ក៏ត្រូវបានចាត់ទុកថាជាខ្មាំងនៅក្នុងចំណោមប្រជាជនដែលរស់នៅតាមទីជនបទដែរ ដោយប្រជាជននៅតាមទីជនបទត្រូវបានប្រាប់ថា អ្នកទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកពីភ្នំពេញ ដែលជាហេតុធ្វើឲ្យមានការខឹងសម្បាជាខ្លាំងចំពោះប្រជាជនដែលទៅពីទីក្រុងភ្នំពេញ ។

### ៣.១.៤) ស្ថានភាពនៃប្រជាជនដែលត្រូវបានជម្លៀស

មេធាវី ម៉ាទីណូ បានបន្តសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ទាក់ទងនឹងស្ថានភាពនៃប្រជាជនដែលត្រូវបានជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថាតើប្រជាជនទាំងនោះជួបប្រទះនឹងស្ថានភាពដូចម្ដេចខ្លះនៅអំឡុងពេលនៃការជម្លៀសនោះ? សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា មានការរៀបរាប់ស្របគ្នាពីសំណាក់អ្នកដែលនៅរស់រានមានជីវិតពីសម័យខ្មែរក្រហមថា លក្ខខណ្ឌរបស់អ្នកដែលត្រូវបានជម្លៀសនៅពេលនោះ គឺមានស្ថានភាពគួរឲ្យព្រឺខ្លាច ។ លោកបន្តថា ខ្មែរក្រហមទទួលបានជ័យជម្នះនៅអំឡុងពេលដែលប្រទេសកម្ពុជាកំពុងតែប្រារព្ធ

ពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងជាពេលដែលអាកាសធាតុមានសភាពក្តៅហួតហែងជាទីបំផុត ខ្វះទឹកបរិភោគ ហើយសីតុណ្ហភាពមិនអំណោយផល ។ ប្រជាជនត្រូវបានបណ្តេញចេញពីទីក្រុងដោយមិនគិតថាអ្នកទាំងនោះមានអាយុប៉ុន្មាន តើមានសុខភាពបែបណា តើកំពុងមានអ្វីកើតឡើងចំពោះអ្នកដែលត្រូវជម្លៀសទាំងអស់នោះឡើយ ។ លោកសាស្ត្រាចារ្យយល់ថា នេះគឺជាស្ថានភាពមួយដ៏ឃោរឃៅជាទីបំផុត ហើយមានប្រជាជនជាច្រើននៅតែចងចាំអំពីព្រឹត្តិការណ៍នៃការជម្លៀសនៅពេលនោះ ។ លោកបានអះអាងថា លោកមិនអាចនិយាយពង្រីកបន្ថែមលើព្រឹត្តិការណ៍នេះបានទេ ប៉ុន្តែការជម្លៀសនេះគឺស្របគ្នាជាមួយនឹងគោលនយោបាយជាច្រើនរបស់កម្ពុជាប្រជាធិបតេយ្យ ហើយខ្មែរក្រហមយល់ថា ការធ្វើកិច្ចការអ្វីមួយលឿនរហ័ស គឺជាមធ្យោបាយត្រឹមត្រូវក្នុងការធ្វើការ ហើយការធ្វើយឺតយ៉ាវ គឺជាមធ្យោបាយចាស់គំរិលក្នុងការងារ ។ ដូច្នេះហើយទើបប្រជាជនមិនត្រូវបានអនុញ្ញាតឲ្យរៀបចំឥវ៉ាន់មុនពេលជម្លៀសចេញពីទីក្រុង ។

លោកស្រីមេធាវីបានបន្តសួរលោកសាស្ត្រាចារ្យទៀតថា ក្នុងឋានៈជាប្រវត្តិវិទូ តើលោកសាស្ត្រាចារ្យអាចធ្វើការប្រៀបធៀបការជម្លៀសដ៏រន្ធត់នេះ ជាមួយនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលកើតមានការជម្លៀសនៅកន្លែងផ្សេងទៀតបានដែរឬទេ? ឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យបញ្ជាក់ថា ព្រឹត្តិការណ៍ជម្លៀសប្រជាជនក៏ធ្លាប់បានកើតឡើងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះដែរ គឺការជម្លៀសប្រជាជនភូមាចេញពីទីក្រុងអយុធ្យានៅក្នុងឆ្នាំ១៧៧៦ ។ នៅក្នុងឆ្នាំ១៨៣២ ថៃបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅពេលដែលប្រទេសថៃបានចូលឈ្លានពានប្រទេសកម្ពុជា ។ នៅប្រទេសចិនធ្លាប់មានការជម្លៀសប្រជាជននៅផ្នែកខ្លះចេញពីទីក្រុង ប៉ុន្តែមិនមានសភាពធ្ងន់ធ្ងរក្នុងកំណត់ត្រាប្រវត្តិសាស្ត្រទេ ។

### ៣.១.៥) កម្រិតអប់រំប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៧៥

អង្គជំនុំជម្រះបានប្រគល់វេទិកាជូនលោកមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក អូលីវីយេ បាហូញ (Olivier BAHOUGNE) ជនជាតិ បារាំង សួរដេញដោលបន្តពីលោកស្រីមេធាវី ម៉ាទីណូ ។ សំណួរដំបូងរបស់លោកមេធាវីបាហូញ គឺបានសួរទាក់ទងនឹងកម្រិតនៃការអប់រំរបស់ប្រជាជនកម្ពុជានៅអំឡុងពេលនៃឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា លោកមិនមានស្ថិតិជាក់ច្បាស់ទេប៉ុន្តែលោកអាចពន្យល់បានថាកម្រិតអនក្ខរភាពរបស់ស្ត្រី និងមនុស្សចាស់ គឺមានអត្រាខ្ពស់ ហើយអត្រានេះមានកម្រិតទាបបំផុតចំពោះកុមារដែលបានទៅសាលារៀន ។ លោកបានបញ្ជាក់ថា មានកុមារជាច្រើននៅក្នុងសម័យសម្តេច សីហនុ បានចូលសាលារៀន ហើយតាមរយៈការពិនិត្យមើលឯកសារដែលមាននៅទួលស្លែងឃើញថា កម្រិតនៃអ្នកធ្វើការនៅទីនោះអាចសរសេរអក្សរ និងអាចវាយអង្គុលីលេខបាន ។ ចំណែកឯអ្នកស្រែចម្ការវិញ កម្រិតអប់រំមិនខ្ពស់ទេ ។ លោកបន្តថា បញ្ហាអនក្ខរភាព គឺដោយសារកម្ពុជាមានសាលាមិនគ្រប់គ្រាន់ និងមិនស្របជាមួយនឹងកំណើនប្រជាជន ព្រោះនៅតាមជនបទខ្លះមិនមានសាលារៀន មិនមានការអប់រំ ។ លោកបានសន្និដ្ឋានថា បុគ្គលិកដែលធ្វើការនៅស-២១ ប្រាកដជាបានទៅសាលារៀនក្នុងកម្រិតណាមួយដែលអាចយល់ ឬអាចមានការអប់រំក្នុងសម័យខ្មែរក្រហមដើម្បីសរសេរ ។

### ៣.១.៦) ការរើសអើង ការធ្វើទុកបុកម្នេញ និងការសម្លាប់ជនជាតិចាម

លោកមេធាវី បាហូញ បានបន្តសួរលោកសាស្ត្រាចារ្យទាក់ទងនឹងការរើសអើងពូជសាសន៍ ដោយលោកមេធាវីបានលើកយកសម្តីរបស់កូនក្តីរបស់លោកមួយរូប ដែលជាដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះបានប្រាប់លោកមេធាវីថា ខ្មែរក្រហមបានហៅខ្លួនថា *"អាចាម ឯងអត់មានប្រទេស អ៊ីចឹងត្រូវតែកម្ទេចចោល"* ។ លោកសាស្ត្រាចារ្យបានពន្យល់ ចំពោះឃ្លាដែលបានលើកឡើងថា ពាក្យថា *"អា"* គឺជាបុព្វបទមួយដែលសំដៅមើលងាយមនុស្សឲ្យមានឋានៈទាប ។ ចំពោះពាក្យដែលហៅថា *"អាចាម"* នេះ គឺជាពាក្យដែលមានអត្ថន័យធ្ងន់ធ្ងរ ដែល បន្ទាបបន្ថោកជនជាតិចាម ។

លោកមេធាវីបានសួរសាស្ត្រាចារ្យ ឆេនដល័រ ទៀតថា បើតាមបទពិសោធន៍របស់លោកសាស្ត្រាចារ្យ តើការបោះបង់ចោលសាកសពនៅកណ្តាលភ្លៀង ខ្យល់ ដោយគ្មានការធ្វើពិធីបូជា

ឬក៏បញ្ហុះ ជាការបន្ទាបបន្ថោកចំពោះជនរងគ្រោះដែរឬទេ? សំណួរនេះត្រូវបានជំទាស់ដោយលោក ហ្សាស្តើ ប៉ៅ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា ដោយលោកបានអះអាងថា សំណួររបស់លោកមេធាវី បាហួញ មិនមានភាពជាប់ពាក់ព័ន្ធនឹងសវនាការនាពេលនេះទេ ។ សេចក្តីជំទាស់របស់ក្រុមមេធាវី នួន ជា ត្រូវបាន អង្គជំនុំជម្រះយល់ស្រប និងស្នើឲ្យលោកមេធាវី បាហួញ សួរសំណួរថ្មី ។

លោកមេធាវីបានលើកយកមាត្រា៤ នៃលក្ខខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជាដើម្បីស្នើសុំការពន្យល់ពីលោកសាស្ត្រាចារ្យឆេនដល័រ ប៉ុន្តែសំណួររបស់លោកមេធាវីនៅតែទទួលការជំទាស់ពីសំណាក់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ។ អង្គជំនុំជម្រះបានយល់ស្របជាមួយនឹងក្រុមមេធាវីការពារក្តី ដោយបង្គាប់ឲ្យលោកសាស្ត្រាចារ្យមិនចាំបាច់ឆ្លើយតបចំពោះសំណួររបស់លោកមេធាវី ។

បន្ទាប់មកលោកមេធាវី បាហួញ បានបន្តសួរលោកសាស្ត្រាចារ្យទៀតថា តើហេតុអ្វីបានជាមានការហាមឃាត់មិនឲ្យគោរពសាសនាអ៊ីស្លាម សូម្បីតែសាសនានេះមិនត្រូវបានចាត់ទុកថាជាសាសនាប្រតិកិរិយា? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកមិនមានបទពិសោធន៍ចំពោះការគិតរបស់ខ្មែរក្រហមទាក់ទងនឹងសាសនាទេ ប៉ុន្តែលោកអាចពន្យល់បានថា អ្វីដែលធ្វើឲ្យខ្មែរក្រហមមានការខឹងសម្បាចំពោះជនជាតិចាម គឺដោយសារភាពរឹងរូសក្នុងការប្រកាន់ខ្ជាប់សាសនារបស់ខ្លួន ហើយបដិសេធមិនព្រមទទួលយក ឬគោរពតាមសាសនាថ្មីរបស់ខ្មែរក្រហម ។ លោកបន្ថែមថា មិនមានសាសនាណាមួយដែលខ្មែរក្រហមមិនចាត់ទុកថាជាសាសនាប្រតិកិរិយាទេ សាសនាណាក៏ដោយ គឺសុទ្ធតែជាសាសនាប្រតិកិរិយា ។ ការចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្មែរក្រហមដែលសរសេរថា "ប្រជាជនកម្ពុជាមានសេរីភាពក្នុងប្រតិបត្តិគ្រប់សាសនា លើកលែងតែសាសនាប្រតិកិរិយាចេញ" គឺគ្រាន់តែជាប្រយោគមួយឃ្លាសម្រាប់បង្ហាញទស្សនិកជនបរទេសប៉ុណ្ណោះ ប៉ុន្តែនៅពេលបន្ទាប់មិនមានឡើយការអត់ធ្មត់ និងការអត់ឱនសម្រាប់សកម្មជនសាសនា ។ នេះក៏ជាអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តលើជនជាតិចាមដែរ ។ លោកសាស្ត្រាចារ្យបន្តថា មានការបង្ហាញនៅក្នុងឯកសារជាច្រើនដែលថា ហេតុអ្វីបានជាការវាយប្រហារលើជនជាតិចាមមិនបានចាប់ផ្តើមភ្លាមៗនៅក្នុងឆ្នាំ១៩៧៥ នេះគឺដោយសារតែជនជាតិចាមមិនត្រូវបានខ្មែរក្រហមចាត់ទុកជាសត្រូវរបស់រដ្ឋ ដូចជាប្រទេសវៀតណាមទេ ។ ប៉ុន្តែការវាយប្រហារលើជនជាតិចាមបានចាប់ផ្តើមនៅពេលដែលក្រុមទាំងនោះចង់ធ្វើបដិវត្តន៍ប្រឆាំងនឹងខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៦


ជនជាតិចាមកំពុងអង្គុយថ្វាយបង្គំព្រះ (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលធ្វើឲ្យខ្មែរក្រហមបានផ្លាស់ប្តូរគំនិតរបស់ខ្លួន ហើយចាត់ទុកជនជាតិចាមទាំងនោះថាជាក្រុមដែលប្រកបដោយគ្រោះថ្នាក់ និងបានធ្វើការសម្លាប់ជាប្រព័ន្ធនូវក្រុមជនជាតិចាម នៅពេលក្រោយមកទៀត ។ ប៉ុន្តែការសម្លាប់នេះ មិនមែនដោយសារតែជំនឿសាសនារបស់ជនជាតិចាមទាំងនេះទេ គឺដោយសារតែការបដិសេធក្នុងការទទួលយក និងឥរិយាបថរបស់អ្នកទាំងនោះ ។

លោកមេធាវីបានបន្តសួរទៀតថា តើសាសនាគឺជាមធ្យោបាយមួយក្នុងការកំណត់អំពីអត្តសញ្ញាណរបស់ជនជាតិចាម? ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា គឺពិតជាដូច្នេះ ។ ដោយសារ សំលៀកបំពាក់ ប្រាសាទ និងភាសា មានទំនាក់ទំនងជាមួយនឹងជនជាតិឥណ្ឌូនេស៊ី និងម៉ាឡេស៊ី ហើយជនជាតិចាមអាចត្រូវបានជួបប្រទះនៅតាមបណ្តាខេត្តមួយចំនួនដូចជា កំពត និង កំពង់ចាម ។

បន្ទាប់មកលោកមេធាវី បាហួញ បានស្នើសុំការបញ្ជាក់ពីសំណាក់លោកសាស្ត្រាចារ្យ ថាតើការបង្ខំឲ្យហូបសាច់ជ្រូក

គឺជាមធ្យោបាយដើម្បីធ្វើការកំណត់អត្តសញ្ញាណជនជាតិចាមមែនដែរឬទេ? ហើយក្រោយមក អ្នកដែលបដិសេធមិនព្រមហូបសាច់ជ្រូកនោះត្រូវបានបោសសម្អាត ឬក៏កម្ទេចមែនដែរឬទេ? សាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយតបនឹងសំណួរនេះថា តាមការពិតខ្មែរក្រហមបានដឹងថាអ្នកទាំងនោះ គឺជាជនជាតិចាមរួចទៅហើយ ហើយខ្មែរក្រហមបង្ខំឲ្យអ្នកទាំងនោះបរិភោគសាច់ជ្រូក ដោយមិនអាចពិពណ៌នាបាន ក្រៅអំពីភាពទុកសោក ។ លោកសាស្ត្រាចារ្យគិតថា នេះមិនមែនជាការធ្វើតេស្តរបស់ខ្មែរក្រហមទេ ប៉ុន្តែកាលៈទេសៈដូច្នេះ ត្រូវបានប្រើនៅក្នុងអំពើសម្លាប់រង្គាល(Holocaust) ដូចជាមធ្យោបាយដែលខ្មែរក្រហមកំណត់អំពីអត្តសញ្ញាណរបស់ជនជាតិចាមដែរ ។ លោកអះអាងទៀតថា ជនជាតិចាមមិនបានព្យាយាមលាក់បាំងអំពីអត្តសញ្ញាណរបស់ខ្លួនឡើយ អ្នកទាំងនោះដឹងថាខ្លួនត្រូវធ្វើអ្វីដែលខ្លួនត្រូវធ្វើ ប៉ុន្តែការបង្ខំឲ្យបរិភោគសាច់ជ្រូកនេះ គឺគ្រាន់តែជាការធ្វើដើម្បីបន្ទាបបន្ថោក និងជាអំពើមួយក្នុងចំណោមអំពើជាច្រើន ដែលកម្មាភិបាលខ្មែរក្រហមធ្វើជារៀងរាល់ថ្ងៃប៉ុណ្ណោះ ។

លោកមេធាវី បានលើកយកលិខិតមួយដែលមានកាលបរិច្ឆេទចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ១៩៧៥ ស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ អត្ថន័យក្នុងលិខិតនោះបានសរសេរថាៈ

“នេះគឺជាទូរលេខ លេខ១៥ ផ្ញើជូនដល់សមមិត្ត ប៉ុលជាទីគោរពស្នេហា ។ ជាគោលការណ៍ ភូមិភាគបញ្ជូនប្រជាជន ៥០,០០០នាក់ទៅភូមិភាគខាងជើង ហើយយើងបានរក្សាទុកពួកម៉ូស្លីមជាង១០០,០០០នាក់ នៅភូមិភាគឦសាន និងនៅតាមបណ្តោយទន្លេជាប់ព្រំដែន ។ គោលការណ៍នេះនៅតែរក្សាទុកដដែល ប៉ុន្តែមិនបានធ្វើនៅត្បូងឃ្មុំទេ ។ ការជម្លៀសប្រជាជននេះគឺជាការបំបែកមនុស្សដែលយើងបានពិភាក្សាជាមួយបង ។ ចុះថ្ងៃទី៣០ ខែ១១ ឆ្នាំ១៩៧៥ ។”

បន្ទាប់លោកមេធាវី បានចោទសួរលោកសាស្ត្រាចារ្យថា បើជាជនជាតិចាមមិនមែនជាក្រុមខ្មាំងដែលប្រឆាំងនឹងខ្មែរក្រហមទេ តើហេតុអ្វីបានមានការរៀបចំជម្លៀស និងបំបែកអ្នកទាំងនោះនៅក្នុងឆ្នាំ១៩៧៥? មុនពេលឆ្លើយតបសំណួរ លោកសាស្ត្រាចារ្យបានធ្វើការកែតម្រូវចម្លើយរបស់លោកដែលបានឆ្លើយ នៅផ្នែកខាងលើ ដែលថាជនជាតិចាមមិនបានធ្វើបដិវត្តន៍ប្រឆាំងនឹងខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៥ ។ លោកបានពន្យល់ចំពោះអត្ថន័យនៅក្នុងលិខិតនោះថា ការបំបែកជនជាតិចាមដោយសារក្រុមជនជាតិចាមមានសហគមស្វយ័តជាមួយនឹងរចនាសម្ព័ន្ធគ្រប់គ្រងបែបរបៀបសាសនា ហើយបែងចែកជាសាខាតូចៗ ដែលធ្វើឲ្យខ្មែរក្រហមចង់ធ្វើការបំបែកពីក្រុមគ្រួសារបំបែកចេញពីទីក្រុង បំបែកអ្នកដែលធ្វើជាទាហាន និងព្រះសង្ឃជាដើម ។ ខ្មែរក្រហមយល់ថា ក្រុមទាំងនេះបានបង្កការគំរាមកំហែងដល់ខ្លួន ដោយសារតែអត្តសញ្ញាណរួម ការចងរក្សា និងបន្តការរស់នៅប្រមូលគ្នានៃក្រុមទាំងអស់នោះ ទើបខ្មែរក្រហមត្រូវបំបែកចេញពីគ្នា ។

ឆ្លើយបតនឹងសំណួររបស់មេធាវីដែលសួរថា តើនៅចុងឆ្នាំ១៩៧៨ ជនជាតិចាមបានក្លាយជាកម្មវត្ថុនៃគោលនយោបាយសម្លាប់រង្គាលរបស់ខ្មែរក្រហមដែរឬទេ? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមពិតជាបានសម្លាប់ជនជាតិចាម ពីព្រោះនៅចុងឆ្នាំ១៩៧៨ខ្មែរក្រហមមានគោលនយោបាយសម្លាប់ជនជាតិវៀតណាម ហើយបក្សបានលើកទឹកចិត្តប្រជាជនឲ្យធ្វើសង្គ្រាមប្រឆាំងនឹងវៀតណាម មិនមែនប្រឆាំងនឹងជនជាតិចាមទេ ។ ប៉ុន្តែការប្រឆាំងនេះ ក៏ធ្វើឡើងដើម្បីប្រឆាំងនឹងបុគ្គលផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ដែលមិនមែនជាជនជាតិខ្មែរដែរ ។

**សូមបញ្ជាក់ថា** ការសួរដេញដោលដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ។ អង្គជំនុំជម្រះបានប្រកាសថា វេទិកាសួរដេញដោលសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដោយក្រុមមេធាវីការពារក្តីទាំងបីក្រុមនឹងបន្តនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ជាបន្តបន្ទាប់ ។

## ៤) ការសួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដល័រ ដោយមេធាវីការពារក្តីទាំងបីក្រុម

ថ្ងៃទី២៣-២៥ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារទាំងបីក្រុម ដើម្បីសាកសួរអ្នកជំនាញសាស្ត្រាចារ្យ ដេវីដ ឆេនដល័ ទាក់ទងនឹងការស្រាវជ្រាវរបស់លោកពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

អង្គជំនុំជម្រះបានផ្តល់ឱកាសជូនក្រុមមេធាវីការពារក្តី នួន ជា សួរដេញដោលមុន បន្ទាប់មកបន្តទៅក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ។

## ៤.ក)ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី នួន ជា

ក្រុមមេធាវីការពារក្តី នួន ជា បានចំណាយពេលពេញមួយថ្ងៃនៅក្នុងការសួរដេញដោលរបស់ខ្លួនលើសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដោយផ្តោតសំខាន់លើសៀវភៅដែលលោកសាស្ត្រាចារ្យបានសរសេរ រួមមាន សៀវភៅ «សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា» និង«បងធំទី១» ជាដើម ។ មុនពេលនៃការបញ្ចប់ការសួរដេញដោលរបស់ខ្លួន មេធាវីអន្តរជាតិការពារក្តី នួន ជា តែងប្រើយុទ្ធសាស្ត្ររបស់ខ្លួន ដោយភ្ជាប់ឈ្មោះមេដឹកនាំមួយចំនួនរបស់កម្ពុជានាពេលបច្ចុប្បន្នចូលក្នុងការសួរដេញដោល និងស្នើឲ្យបុគ្គលទាំងនោះចូលផ្តល់សក្ខីកម្មក្នុងសវនាការ ដើម្បីស្វែងរកការពិត និងផ្តល់យុត្តិធម៌ដល់កូនក្តីរបស់ខ្លួន ។

### ៤.ក.១) ប្រភពឯកសារនៃសៀវភៅរបស់សាស្ត្រាចារ្យ ឆេនដល័រ

លោក សុន អរុណ មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា បានចាប់ផ្តើមសំណួរដំបូងទាក់ទងនឹងភាពជឿជាក់នៃឯកសារដែលលោកសាស្ត្រាចារ្យ ឆេនដល័រ បានធ្វើការស្រាវជ្រាវ ។ លោកសាស្ត្រាចារ្យបានឆ្លើយតបចំពោះសំណួរនេះថា សៀវភៅ «សោកនាដកម្មនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា» គឺផ្អែកលើឯកសារចំនួន៧៥ និងបទសម្ភាសន៍២៥ ។ សៀវភៅ «បងធំទី១» បានផ្អែកលើឯកសារចំនួន៨០ និងបទសម្ភាសន៍ចំនួន២០ ។ សៀវភៅ «សំឡេងពីមន្ទីរស-២១» បានផ្អែកលើឯកសារចំនួន ៩៥ និងបទសម្ភាសន៍ចំនួន៥ ។ លោកបានបន្តទៀតថា ក្នុងនាមជាអ្នកប្រវត្តិសាស្ត្រ លោកសាស្ត្រាចារ្យត្រូវធ្វើការជ្រើសរើសក្នុងចំណោមឯកសារទាំងអស់ដោយហេតុថា ឯកសារដែលលោកមិនទុកចិត្តលោកនឹងមិនយកមកប្រើប្រាស់ទេ ហើយចំពោះបទសម្ភាសន៍ក៏ដូចគ្នាដែរ ។ ចំណែកទីតាំងសម្លាប់មនុស្ស លោកមិនមានលទ្ធភាពធ្វើការសិក្សានៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យបានឡើយ ។ រហូតដល់ឆ្នាំ១៩៩០ ទើបលោកអាចសម្ភាសន៍ជាមួយអ្នកដែលនៅរស់រានមានជីវិតពីរបប ប៉ុល ពត ។

### ៤.ក.២) ការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យពីសំណាក់បរទេស

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការទទួលស្គាល់កម្ពុជាប្រជាធិបតេយ្យពីសំណាក់បរទេស លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា កម្ពុជាប្រជាធិបតេយ្យមានការយកចិត្តទុកដាក់ខ្លាំងចំពោះការទទួលស្គាល់ពីបរទេស ប៉ុន្តែកម្ពុជាប្រជាធិបតេយ្យមិនទទួលស្គាល់ ប្រទេសដែលមិនមានទំនាក់ទំនងជិតស្និតជាមួយខ្លួននោះឡើយ ។ លោកមេធាវីបានបន្តដកស្រង់ចម្លើយរបស់អ្នកជំនាញទាក់ទងនឹងការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យដោយអង្គការសហប្រជាជាតិ ប៉ុន្តែការលើកឡើងនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាជំទាស់ ដោយសារមេធាវីមិនបានយោងទៅលើឯកសារណាមួយ ដើម្បីធ្វើការសួរដេញដោល ។ អង្គជំនុំជម្រះបានយល់ស្របជាមួយនឹងការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា និងស្នើឲ្យលោកមេធាវី សុន អរុណ បន្តសួរសំណួរថ្មី ។

### ៤.ក.៣) រចនាសម្ព័ន្ធបក្ស

លោកមេធាវីបានបន្តសំណួរទាក់ទងនឹងរចនាសម្ព័ន្ធរបស់បក្សពីថ្នាក់លើដល់ថ្នាក់ក្រោម ដែលនៅក្នុងនោះលោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកបានឃើញឯកសារដែលអាចឲ្យលោកស្វែងយល់ពីរចនាសម្ព័ន្ធដែលមាននៅពេលនោះតាមរយៈលក្ខន្តិកៈរបស់បក្សដែលមានចាប់ពីលេខាគណៈមជ្ឈិមរបស់បក្ស ថ្នាក់តំបន់



មេធាវី សុន អរុណ

និងមន្ទីរ ក្រៅពីនោះលោកបានធ្វើការសិក្សាលើឯកសារនិយាយអំពីរចនាសម្ព័ន្ធមួយចំនួនទៀត ដូចជា រដ្ឋធម្មនុញ្ញ និងអគ្គការលេខជាច្រើនទៀត ។ លោកមេធាវី អរុណ បានបន្តសួរទៀតថា តើមូលហេតុអ្វីបានជាលោកសាស្ត្រាចារ្យដាក់ចំណងជើងសៀវភៅរបស់ខ្លួនថា "បងធំទី១"? ឆ្លើយតបនឹងសំណួរនេះ លោកបានពន្យល់ថា នេះជាឈ្មោះដែលត្រូវបានស្គាល់ថា ជាឈ្មោះរបស់ ប៉ុល ពត ហើយមានឈ្មោះច្រើនទៀតដែលសំដៅលើ ប៉ុល ពត ដូចជា អ៊ំលេខ ជាដើម ។ ការហៅបែបនេះ គឺពោរពេញដោយការគោរព ហើយមិនមាននរណាម្នាក់ហៅឈ្មោះបុគ្គលដែលមានលំដាប់ទាបជាងខ្លួនថាជា បងទីមួយ នោះទេ ដោយសារ ប៉ុល ពត ជាលេខាបក្ស ដូច្នេះលោកយល់ថា ចំណងជើងដូច្នេះ គឺសាកសមសម្រាប់សៀវភៅរបស់លោក ។

ចំពោះរចនាសម្ព័ន្ធនៃមន្ទីរស-២១ លោកបានបញ្ជាក់ថា ពេលខ្លះមន្ទីរនេះមានរចនាសម្ព័ន្ធជាពី រ៉ាមីត ដូចជារចនាសម្ព័ន្ធថ្នាក់លើដែរ ។ ឌុច គឺជាមនុស្សម្នាក់ដែលត្រូវបានអនុញ្ញាតឲ្យធ្វើការទាក់ទងជាមួយថ្នាក់លើគឺ សុន សេន ។ ចំណែកនៅតាមតំបន់ផ្សេងៗ មានផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដោយមិនមានទម្រង់ជាពីរ៉ាមីតដូចទ្រឹស្តីរបស់បក្សកុម្មុយនីស្តកម្ពុជាឡើយ ហើយបុគ្គលខ្លះមានអំណាចខ្លាំង ឬខ្សោយជាងតួនាទីដែលមាននៅក្នុងអគ្គការលេខទៅទៀត ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា តាមការស្រាវជ្រាវកន្លងមក លោកមិនគិតថាលោកធ្លាប់បានឃើញឯកសារដែលមានហត្ថលេខា និងត្រារបស់កម្មាភិបាលថ្នាក់លើទេ ប៉ុន្តែលោកធ្លាប់បានឃើញឯកសារសរសេរដោយដៃរបស់ សុន សេន ដែលមានតំណែងទីពនៅក្នុងអគ្គការ ។ មនុស្សភាគច្រើនបានស្វែងរកហត្ថលេខារបស់ ប៉ុល ពត ប៉ុន្តែលោកមិនគិតថាមាននរណាម្នាក់រកឃើញឡើយ ។ លោកសាស្ត្រាចារ្យបានលើកឡើងពីឯកសាររបស់សុន សេន ដែលផ្ញើឲ្យ ឌុច ដែលអត្ថន័យនៅក្នុងលិខិតនោះបានបញ្ជាក់ថា ឲ្យ ឌុច ខិតខំធ្វើការងារ និងធ្វើការកម្ទេចនៅមន្ទីរស-២១ ។ លោកបន្តថា រាល់ការបញ្ជាពីថ្នាក់លើមិនមានចុះហត្ថលេខាទេ ប៉ុន្តែបញ្ជាទាំងនោះត្រូវបានគោរពយ៉ាងខ្ជាប់ខ្ជួន ។ ចំពោះឯកសារទូរលេខដែលផ្ញើពីខាងយោធា និងភូមិភាគជូនមកបង ដែលសំដៅលើមេដឹកនាំមួយចំនួន ដោយមានចម្លងជូនមេដឹកនាំមួយចំនួនទៀត លោកសាស្ត្រាចារ្យបញ្ជាក់ថា តាមលក្ខណៈដឹកនាំជាសមូហភាព ត្រូវតែមានការចម្លងជូនទៅកាន់មនុស្សផ្សេងទៀត ប៉ុន្តែភាពពិតអ្នកទាំងនោះមិនមានសិទ្ធិសម្រេចអ្វីឡើយ ហើយអ្នកដែលមានអំណាចសម្រេច គឺអ្នកដែលត្រូវបានផ្ញើជូនតែប៉ុណ្ណោះ ។



ឯកសារចម្លើយសារភាពនៅគុកទួលស្លែង (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

**គួរកត់សម្គាល់ថា** បន្ទាប់ពីមេធាវីជាតិការពាររបស់ខ្លួនបានបញ្ចប់ការសួរដេញដោលលើលោកសាស្ត្រាចារ្យ ឆនដល័រ ជនជាប់ចោទ នួន ជា បានស្នើសុំអង្គជំនុំជម្រះសាកសួរលោកសាស្ត្រាចារ្យចំនួន២សំណួរ ។ សំណើនេះត្រូវបានអង្គជំនុំជម្រះបានយល់ស្រប និងបានប្រគល់វេទិកាឲ្យជនជាប់ចោទ នួន ជា ដើម្បីសាកសួរលោកសាស្ត្រាចារ្យ ។

សំណួរទីមួយរបស់ជនជាប់ចោទ នួន ជា បានសួរថា "តើតាំងពីដើមមករហូតដល់ឥឡូវ ទំនាស់រវាងបក្ស រវាងប្រជាជនកម្ពុជា និងវៀតណាម មានមូលហេតុសំខាន់មកពីបញ្ហាព្រំដែន

*ឬមកពីបញ្ហាអ្វីជាសំខាន់?»* មុនឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា នួន ជា គឺជាបុគ្គលមួយរូបដែលលោកគោរពជាទីបំផុត ហើយដើម្បីឆ្លើយនឹងសំណួរដែលមានលក្ខណៈជាប្រវត្តិសាស្ត្រខាងលើ ចាំបាច់ត្រូវពិនិត្យមើលឯកសាររាប់រយទំព័រ និងត្រូវទាមទារឲ្យមានការពន្យល់ច្រើនដែលអាចហួសពីព្រំដែនតុលាការដែលមានយុត្តាធិការលើព្រឹត្តិការណ៍កើតមានចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ប៉ុន្តែលោកអាចបញ្ជាក់បានថាមូលហេតុដែលសំខាន់ គឺបណ្តាលមកពីការស្តីបន្ទោសគ្នា ការមិនគោរពតាមយោបល់គ្នាទៅវិញទៅមក ការមិនពិភាក្សាគ្នា និងការមិនទុកចិត្តគ្នា ។ ចំពោះសំណួរទី២របស់ជនជាប់ចោទ នួន ជា បានសួរថា *«តើកំណើតរបស់បក្សកុម្មុយនីស្តកម្ពុជាមានមកដោយសារចលនារបស់ប្រជាជនកម្ពុជា ឬមានកំណើតដោយជនបរទេសនាំពីក្រៅចូលមក?»* លោកសាស្ត្រាចារ្យ ឆេនដល័រ



ជនជាប់ចោទ នួន ជា នៅក្នុងបន្ទប់សវនាការ

បានឆ្លើយតបចំពោះជនជាប់ចោទ នួន ជា ថា បក្សកុម្មុយនីស្តកម្ពុជាគឺជាឈ្មោះមួយរបស់ចលនាកុម្មុយនីស្តកម្ពុជា ដែលមានកាលបរិច្ឆេទចាប់ពីឆ្នាំ១៩៦៧ ហើយដើម្បីដឹងអំពីបញ្ហានេះត្រូវពិនិត្យមើលលើឫសគល់នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបក្សកុម្មុយនីស្តវៀតណាម ។ លោកបានសង្កត់ធ្ងន់លើព្រឹត្តិការណ៍នៅចុងឆ្នាំ១៩៤០ រហូតដល់ដើមឆ្នាំ១៩៥០ ដែលនិយាយពីគំរូចលនាកុម្មុយនីស្តកម្ពុជាដែលបានទទួលឥទ្ធិពលពីចលនាកុម្មុយនីស្តរបស់វៀតណាម ប៉ុន្តែតាមរយៈមហាសន្និបាតឆ្នាំ១៩៦០ និងការរៀបចំលក្ខន្តិកៈរបស់បក្សឥទ្ធិពលរបស់វៀតណាមត្រូវបានបដិសេធដោយបក្សកុម្មុយនីស្តកម្ពុជា ។ នៅអំឡុងពេលនៃសង្គ្រាមស៊ីវិល ឥទ្ធិពលនេះបានធ្លាក់ចុះកាន់តែខ្លាំង ។ តាមរយៈប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជាជាចលនាស្វ័យភាពមួយដែលមានទំនាក់ទំនងជាមួយវៀតណាម ប៉ុន្តែក្រោយមកទំនាក់ទំនាក់ទំនងនេះត្រូវបានកាត់ផ្តាច់ទៅវិញ ។

បន្ទាប់ពីជនជាប់ចោទ នួន ជា បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីអន្តរជាតិការពារក្តី នួន ជា ដើម្បីបន្តសាកសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ។

### ៤.ក.៤) ការអានឯកសារតុលាការមុនចូលផ្តល់សក្ខីកម្ម

លោក ហ្សាស្ពើ ប៉ៅ (Jasper Pauw) មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា បានចាប់ផ្តើមសំណួរដំបូងទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់លោកសាស្ត្រាចារ្យ ឆេនដល័រ ដែលបានធ្វើនៅថ្ងៃដំបូង ដោយនោះពេលនោះលោកបាននិយាយថា លោកបានអានឯកសារដែលលោកមិនធ្លាប់បានអានពីមុនមក ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យបានរៀបរាប់អំពីឯកសារដែលលោកបានអាននោះ រួមមាន លិខិតចំហររបស់សម្តេច សីហនុ មានចំណងជើងថា «ប្រវត្តិសាស្ត្រមន» ដែលមាននៅក្នុងជើងទំព័រនៃដីការដំណោះស្រាយ ។ ឯកសារនោះមានរៀបរាប់អំពីការសន្ទនារបស់ទ្រង់ជាមួយនឹង ប៉ុល ពត នៅដើមឆ្នាំ ១៩៧៩ ។

បន្ទាប់មកលោកមេធាវី ហ្សាស្ពើ ប៉ៅ បានសួរទៀតថា បើលោកសាស្ត្រាចារ្យបានអានដីកាដំណោះស្រាយ តើលោកបានអានកំណត់សម្គាល់ជើងទំព័រទាំងអស់ដែរឬទេ? លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកមិនបានមើលឯកសារដែលមាននៅក្នុងកំណត់សម្គាល់ជើងទំព័រទាំងអស់នោះទេ ដោយសារឯកសារទាំងនោះមានចំនួនច្រើនជាងប្រាំមួយពាន់ឯណោះ លោកអានតែឯកសារដែលទាក់ទាញការចាប់អារម្មណ៍របស់លោកតែប៉ុណ្ណោះ ។ លោកតែងតែកត់ត្រាទុកចំពោះឯកសារបើកចំហរ ប៉ុន្តែឯកសារដែលលោកមិនអាចប្រើប្រាស់បានជាលក្ខណៈប្រវត្តិសាស្ត្របាន លោកមិនកត់ត្រាទេ ។ បន្ថែមលើនេះ លោកបានបន្តថា លោកមិន

បានអានឯកសារសម្ងាត់របស់សហចៅក្រមស៊ើបអង្កេតឡើយ ប៉ុន្តែមុនពេលមកផ្តល់សក្ខីកម្ម ក្នុងតុលាការ លោកបានអានឯកសារ និងសៀវភៅមួយចំនួនដែលទាក់ទងនឹងតុលាការ ដូចជា សៀវភៅរបស់លោក ចន ឆរឆីអារី (John Ciorciari) និងមានឯកសារច្រើនទៀតដែលមិនមែនជាឯកសារសម្ងាត់របស់តុលាការ ដើម្បីជាការរំឭកដល់ការចងចាំរបស់លោក ។ ឆ្លើយតបនឹងសំណួររបស់មេធាវីដែលបានសួរទាក់ទងនឹងការតាមដានសវនាការនៅក្នុងសំណុំរឿង០០២ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកបានតាមដានពីដំណើរការរបស់តុលាការតាមរយៈការអានកាសែត និងរបាយការណ៍ផ្សេងៗ ។ ទាក់ទងនឹងសក្ខីកម្មរបស់ ឌុច លោកបានអះអាងថាលោកមិនបានអានព័ត៌មាន ដែលទាក់ទងនឹងការធ្វើសក្ខីកម្មនោះឡើយ ។ លោកសាស្ត្រាចារ្យបន្តថា លោកបានជួបជាមួយអ្នកដែលមានការយល់ដឹងច្រើនពីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែលោកមិនទទួលបានការណែនាំក្នុងការផ្តល់សក្ខីកម្មរបស់លោកឡើយ ។

### ៨.ក.៥) កំណើនប្រជាជនទីក្រុងដោយសារការទម្លាក់គ្រាប់បែកសហរដ្ឋអាមេរិក

ឆ្លើយតបនឹងសំណួររបស់លោកមេធាវី ហ្សាស្តេ ទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាមុនរបបកម្ពុជាប្រជាធិបតេយ្យ លោកសាស្ត្រាចារ្យ ឆេនដល័រ បានលើកឡើងថា ក្នុងនាមលោកជាជនជាតិអាមេរិកមួយរូប និងជាអ្នកស្រាវជ្រាវអំពីប្រទេសកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ លោកពិតជាមានការតក់ស្លុតចំពោះការទម្លាក់គ្រាប់បែកដ៏ច្រើនបំផុតរបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា នៅពេលដែលអាមេរិកមិនមែនជាភាគីជម្លោះនៅក្នុងសង្គ្រាមផងនោះ ។ លោកបានបន្តថា ផលប៉ះពាល់ពីការទម្លាក់គ្រាប់បែកលើក្រុមខ្មែរក្រហមបានធ្វើឲ្យមានការពិភាក្សាគ្នាយ៉ាងទូលំទូលាយ ថាតើការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកជាកត្តាជំរុញឲ្យប្រជាជនចូលរួមជាមួយចលនាខ្មែរក្រហម ឬការទម្លាក់គ្រាប់បែកនោះជំរុញឲ្យប្រជាជនរត់គេចចូលទីក្រុងភ្នំពេញ ។ សម្រាប់ខ្លួនលោកផ្ទាល់ លោកគិតថា គឺទាំងពីរ ។ លោកសាស្ត្រាចារ្យបន្តទៀតថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅពេលនោះ គឺជារយៈកាលដែលគួរឲ្យអៀនខ្មាសមួយសម្រាប់ប្រវត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក លោកពិតជាសោកស្តាយ មិនត្រឹមតែចំពោះប្រវត្តិសាស្ត្ររបស់អាមេរិកទេ ប៉ុន្តែការទម្លាក់គ្រាប់បែកនោះក៏ជាព្រឹត្តិការណ៍គួរឲ្យអៀនខ្មាសមួយចំពោះប្រជាជនកម្ពុជាដែរ ។ លោកមេធាវី ហ្សាស្តេ បានបន្តសួរលោកសាស្ត្រាចារ្យទៀតថា តើអាមេរិកទម្លាក់គ្រប់បែកលើប្រទេសកម្ពុជាតែនៅក្នុងឆ្នាំ១៩៧៣ ឬអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកនៅឆ្នាំ១៩៧៣? ឆ្លើយតបនឹងសំណួរនេះលោកសាស្ត្រាចារ្យបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៣ គឺជាឆ្នាំដែលមានការទម្លាក់គ្រាប់បែកច្រើនជាងគេបង្អស់ និងជាពេលដែលសហរដ្ឋអាមេរិកបានបញ្ចប់សកម្មភាពអសីលធម៌របស់ខ្លួន ដោយសារការសម្រេចរបស់រដ្ឋសភាអាមេរិក ។ លោកសាស្ត្រាចារ្យបានបន្តថា ការទម្លាក់គ្រាប់បែកនៅតាមបណ្តោយព្រំដែនវៀតណាមបានចាប់ផ្តើមនៅឆ្នាំ១៩៦០ និងចាប់ផ្តើមជាផ្លូវការនៅក្នុងឆ្នាំ១៩៦៨ និង១៩៦៩ ហើយការទម្លាក់គ្រាប់បែកនេះបានរាលដាលឆ្លងដែនមកដល់ប្រទេសកម្ពុជា ។ នៅខណៈពេលដែលយុទ្ធនាការទម្លាក់គ្រាប់បែកបានចាប់ផ្តើមខ្លាំង ជាពិសេសនៅក្នុងឆ្នាំ១៩៧៣ បន្ទាប់មកនៅក្នុងឆ្នាំនោះដដែលប្រទេសវៀតណាម និងសហរដ្ឋអាមេរិកបានព្រមព្រៀងចុះហត្ថលេខាលើបទឈប់បាញ់មួយ ប៉ុន្តែនៅពេលនោះខ្មែរក្រហមបានបដិសេធមិនព្រមចុះហត្ថលេខា ។

បន្ទាប់មកលោកមេធាវី ហ្សាស្តេ បានលើកយកឃ្លាមួយនៃសៀវភៅ «បងធំទី១» ដែលរៀបរាប់ទាក់ទងនឹងផលប៉ះពាល់នៅតាមទីជនបទដែលបណ្តាលមកពីយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ដើម្បីស្នើសុំឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ចាប់តាំងពីពេលដែលលោកត្រឡប់មកដល់ប្រទេសកម្ពុជាជាថ្មីម្តងទៀត លោកបានមើលឃើញថា នៅតាមតំបន់ជនបទទទួលរងនូវមហន្តរាយដែលហាក់ដូចជាគ្មាននណាម្នាក់នឹកស្មានដល់ ដោយសារគ្រាប់បែកជាច្រើនតោនត្រូវបានទម្លាក់នៅលើតំបន់ដែលមិនមានមនុស្សរស់នៅដោយអចេតនា ។ លោកបានបន្ថែមថា ផលប៉ះពាល់សំខាន់គឺធ្វើឲ្យប្រជាជននៅតាមជនបទរត់គេចខ្លួនទៅនៅទីក្រុងភ្នំពេញ ប៉ុន្តែមិនមានតួលេខជាក់លាក់ពីចំនួនប្រជាជនទេ ។ លោកបន្តថា

នៅឆ្នាំ១៩៧១ទីក្រុងភ្នំពេញមានប្រជាជនរស់នៅប្រហែលកន្លះលាននាក់ រហូតដល់ឆ្នាំ១៩៧៥ចំនួនប្រជាជនមានប្រហែលពីរលានប្រាំសែននាក់ ប៉ុន្តែកំណើនប្រជាជននេះ គឺបណ្តាលមកពីការទម្លាក់គ្រាប់បែក ។ នៅឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ស្ថានភាពរស់នៅរបស់ប្រជាជននៅទីក្រុង មានការលំបាកគ្មានអនាម័យ និងខ្វះខាតអាហារជាដើម ។

## ៤.ក.៦) មូលហេតុដែលនាំឲ្យមានការជម្លៀសប្រជាជន

បន្ទាប់មកលោកមេធាវី ហ្សាស្តេ ប៉ោ បានលើកយកប្រតិចារឹកទាក់ទងនឹងចម្លើយរបស់លោកសាស្ត្រាចារ្យដែលបានឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ដែលនិយាយថា លោកសាស្ត្រាចារ្យយល់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយសារការភ័យខ្លាចសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក គឺជាហេតុផលមិនសមស្រប ។ លោកមេធាវីបានស្នើឲ្យសុំលោកសាស្ត្រាចារ្យធ្វើការពន្យល់នៅត្រង់ចំណុចនេះ ។ ជាការឆ្លើយតប លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញក្នុងហេតុផលខ្លាចការទម្លាក់គ្រាប់បែករបស់អាមេរិកនោះ មិនមែនជាហេតុផលសមស្របនោះទេ ដោយសារមិនមាន សញ្ញាណណាមួយដែលថាអាមេរិកនឹងត្រឡប់មកវិញនោះឡើយ ហើយលោកជឿជាក់ថា មេដឹកនាំខ្មែរក្រហមក៏បានដឹងអំពីបញ្ហានេះដែរ ។

លោកមេធាវីបានបន្តអានឃ្លាមួយ ដោយដកស្រង់ចេញពីសៀវភៅ «ប្រវត្តិសាស្ត្រប្រទេសកម្ពុជា» ទាក់ទងស្ថានភាពរស់នៅរបស់ប្រជាជនដែលត្រូវបានជម្លៀស ដើម្បីស្នើសុំលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ឃ្លានោះបានសរសេរថា ៖

«លក្ខខណ្ឌគឺមានលក្ខណៈធ្ងន់ធ្ងរ ជាពិសេសចំពោះអ្នកដែលមិនស៊ាំជាមួយនឹងការធ្វើការងារដោយប្រើកម្លាំង ប៉ុន្តែដោយសារនៅតាមស្រុកជាច្រើន គឺមានស្បៀងហូបចុកគ្រប់គ្រាន់ អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលធ្លាប់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ពេលដែលមើលទៅក្រោយកាលពីប៉ុន្មានខែមុនគឺប្រៀបដូចជាសករាជមាសអញ្ចឹង» ។

លោកសាស្ត្រាចារ្យបានបញ្ជាក់ត្រង់ចំណុចនេះថា ប្រជាជនដែលទៅជនបទ គឺមានអាហារហូបចុក ប៉ុន្តែមិនច្រើនទេ ។ ប្រជាជនទាំងនោះត្អូញត្អែរថាអាហារហូបចុក គឺពិតជាមិនគ្រប់គ្រាន់ទេ ប៉ុន្តែក៏មិនទាន់ដល់ថ្នាក់អត់ឃ្លានដែរ ហើយក៏មិនមានការដាក់កម្រិតខ្លាំងពេកទេ ព្រោះភាគច្រើននៃអ្នកដែលលោកបានធ្វើសម្ភាសន៍ជាមួយ គឺពេញចិត្តនឹងទិសដៅដែលខ្លួនឆ្ពោះទៅ ដោយសារប្រហែលភូមិដែលអ្នកទាំងនោះកំពុងធ្វើដំណើរទៅ គឺជាកន្លែងដែលសាច់ញាតិរបស់ខ្លួនរស់នៅ ហើយនៅជនបទក៏មានស្តុកស្រូវនៅសល់ខ្លះៗដែរ ។

## ៤.ក.៧) សាក្សីដែលបានចូលរួមកិច្ចប្រជុំថ្ងៃទី២០ ឧសភា ១៩៧៥

លោកមេធាវី ហ្សាស្តេ បានរំឭកអំពីសំណួរដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានសួរលោកសាស្ត្រាចារ្យក្នុងសវនាការថ្ងៃទី២០ កក្កដា ឆ្នាំ២០១២ ទាក់ទងនឹងសន្និបាតថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ «ថាតើសេចក្តីសម្រេចនោះស្របជាមួយនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?» ។ បន្ទាប់មក លោកមេធាវីបានសួរថា តើឯកសារទាំងនោះជាឯកសារដែលស្រង់ចេញពីសៀវភៅរបស់លោក ប៉ែន ឃៀវនិន ឬជាឯកសារដែលនៅសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ? ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា ឯកសារដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនាពេលនោះ មិនមែនជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យនោះទេ ដោយលោកបញ្ជាក់ថា ឯកសារទាក់ទងនឹងកិច្ចប្រជុំនោះត្រូវបានដកស្រង់ចេញពីសៀវភៅរបស់លោកសាស្ត្រាចារ្យ ប៉េន ឃៀវនិន ។ លោកបន្តថា ក្រោយពេលរបបខ្មែរក្រហមដួលរលំ លោក ឃៀវនិន បានជួបជាមួយអ្នកដែលធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំនោះ ដោយបានបញ្ជាក់ថា បុគ្គលដែលលោក ឃៀវនិន បានជួបនៅពេលនោះគឺលោក ហេង សំរិន, ជា ស៊ីម និងមន្ត្រីជាន់ខ្ពស់មួយរូបទៀតនៃរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ។ ប៉ុន្តែ បុគ្គលដែលប្រាប់លោក ប៉ែន ឃៀវនិន មុនគេអំពីកិច្ចប្រជុំនោះ គឺប្រហែលជាលោក ហេង សំរិន ។

លោកមេធាវីបានបន្តលើកឡើងពីកិច្ចសម្ភាសន៍ ដែលលោក ប៉ែន ឃៀវនិន បានធ្វើជាមួយនឹងលោក ហេង សំរិន និងលោក ជា ស៊ីម ទាក់ទងនឹងកិច្ចប្រជុំថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ។

លោកបានស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបកស្រាយអំពីពាក្យសម្តីរបស់លោក ហេង សំរិន និងលោក ជា ស៊ីម ដែលបានផ្តល់នៅក្នុងកិច្ចសម្ភាសន៍ជាមួយលោក យៀរនិន ទាក់ទងនឹងពាក្យ “កំចាត់” និងពាក្យ “ចំបាច់ត្រូវតែសម្លាប់” ។ លោកមេធាវីបានលើកឡើងថា លោក ហេង សំរិន អះអាងនៅក្នុងបទសម្ភាសន៍នោះថា នៅក្នុងវគ្គសិក្សាយោធាដែលលោករៀនជាមួយ សុន សេន គឺមិនមានការប្រើប្រាស់ពាក្យ “សម្លាប់” ទេ ប៉ុន្តែមានការប្រើប្រាស់ពាក្យថា “កំចាត់” ដែលត្រូវបានប្រើប្រាស់ជាមួយនឹងអ្នកដែលធ្លាប់ធ្វើការនៅក្នុងរបបចាស់ ។ ហើយ នួន ជា ក៏បានប្រើពាក្យ “កំចាត់” នេះដែរ ។ ប៉ុន្តែលោក ជា ស៊ីម បាន លើកឡើងថា នៅក្នុងកិច្ចប្រជុំនោះមានការលើកឡើងអំពីពាក្យថា “ចាំបាច់ត្រូវតែសម្លាប់” ចំពោះអ្នកធ្វើការនៅក្នុងរដ្ឋការចាស់ ។ ឆ្លើយតបនឹងសំណួរនេះលោកសាស្ត្រាចារ្យបានលើកឡើងថា ពិតជាមានព័ត៌មានផ្សេងគ្នារវាងបុគ្គលទាំងពីរ ប៉ុន្តែលោកមិនអាចនិយាយថា ព័ត៌មានរបស់បុគ្គលណាម្នាក់ជាព័ត៌មានត្រឹមត្រូវនោះទេ ព្រោះលោកមិនបានអានកិច្ចសម្ភាសន៍ទាំងស្រុងរបស់អ្នកទាំងពីរ ។ ដូច្នេះលោកមិនអាចប្រកាន់ជំហរណាមួយទាក់ទងនឹងការអះអាងរបស់បុគ្គលទាំងពីររូបនេះបានទេ ។

## ៤.ក.៨) សំណួរដែលទទួលរងការជំទាស់

នៅមុនពេលបញ្ចប់ការសួរដេញដោល សំណួរជាច្រើនរបស់លោកមេធាវី ហ្សាស្តេ ប៉ោ ដែលបានសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ពាក់ព័ន្ធនឹងការលាបពណ៌នយោបាយដោយរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងការបំផ្លាញកស្តុតាងដោយប្រទេសវៀតណាម ត្រូវបានជំទាស់ជាញឹកញាប់ដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ លោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អូលីវីយេ បាហូញ និងតំណាងសហព្រះរាជអាជ្ញា ថារីក អាប់ឌុលហាក់ បានជំទាស់ចំពោះសំណួរទាំងនោះ ដោយសារសំណួរដែលមេធាវី ហ្សាស្តេ បានសួរមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុ ហើយការលើកឡើងរបស់លោកមេធាវីក៏មិនមានកល្លណៈច្បាស់លាស់ ។ ការជំទាស់នេះត្រូវបានអង្គជំនុំជម្រះយល់ស្រប ដោយអះអាងថា សំណួររបស់ក្រុមមេធាវីការពារក្តី នួន ជា មិនមានពាក់ព័ន្ធនឹងអង្គហេតុ និងមិនមាន



កម្មាភិបាលខ្មែរក្រហមចូលរួមក្នុងវគ្គសិក្សា, នួន ជា អង្គុយនៅគុមុខខាងឆ្វេងបង្អស់ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកសារគ្រប់គ្រាន់ដើម្បីគាំទ្រសំណួរ ដែលខ្លួនបានលើកឡើង ។

បន្ទាប់ពីអង្គជំនុំជម្រះបានបដិសេធការសួរសំណួររបស់ខ្លួន លោកមេធាវី ហ្សាស្តេ ប៉ោ បានបន្តសំណួរថ្មីដែលមានលក្ខណៈស្រដៀងគ្នា ដោយលោកបានសួរលោកសាស្រ្តាចារ្យ ឆេនដល័រ ថា តើការបំផ្លាញឯកសារភស្តុតាងដែលនៅសល់ពីសម័យខ្មែរក្រហម មានទទួលរងឥទ្ធិពលពីការលាបពណ៌នយោបាយ នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរឬទេ? សំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការជំទាស់សារជាថ្មី ដោយអះអាងថា សំណួររបស់មេធាវីការពារក្តី គឺជាសំណួរដែលនាំឲ្យអ្នកជំនាញឆ្លើយស្មានៗ និងជាសំណួរដែលមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុ ។ លោកមេធាវី ហ្សាស្តេ បានឆ្លើយតបចំពោះការជំទាស់នោះថា សំណួររបស់លោកគឺជាសំណួរបែបប្រវត្តិសាស្រ្ត ដែលលោកសាស្រ្តាចារ្យ ឆេនដល័រ ក្នុងឋានៈលោកជាអ្នកប្រវត្តិសាស្រ្ត និងធ្វើការសិក្សាស្រាវជ្រាវជាច្រើនអំពីប្រវត្តិសាស្រ្តប្រទេសកម្ពុជា និងបានអានឯកសារចម្លើយសារភាពជាច្រើន ដូច្នេះលោកពិតជាអាចឆ្លើយតបចំពោះសំណួរនេះបាន ។ បន្ទាប់ពីមានការពិភាក្សារួចមក ចៅក្រមអង្គជំនុំជម្រះបានសម្រេចឲ្យលោកសាស្រ្តាចារ្យ ឆេនដល័រ ឆ្លើយតបចំពោះសំណួរដែលចោទសួរដោយមេធាវីការពារក្តី នួន ជា ។ លោកសាស្រ្តាចារ្យ ឆេនដល័រ បានបញ្ជាក់ ថាការបំផ្លាញឯកសារនោះលោកមិនអាចរៀបរាប់បានទេ ថាតើមានឯកសារអ្វីខ្លះ ថាតើកម្ពុជាប្រជាធិបតេយ្យជាអ្នកបំផ្លាញដោយខ្លួនឯង ឬយ៉ាងណា ហើយលោកក៏មិនបានដឹងពីមូលហេតុដែលនាំឲ្យមានការបំផ្លាញឯកសារនោះដែរ ។

លោកមេធាវីបន្តសួរសំណួរទាក់ទងនឹងការធ្វើការរបស់មន្ត្រីនៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ក្រោយពេលរបបខ្មែរក្រហមដួលរលំ ថាតើការធ្វើការរបស់មន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺផ្តោតសំខាន់លើកំហឹងរបស់ប្រជាជនកម្ពុជាលើរបបប្រល័យពូជសាសន៍ សូម្បីតែមន្ត្រីទាំងនោះធ្លាប់មានតួនាទីជាសមាជិករបស់ខ្មែរក្រហម ឬយ៉ាងណា? លោកសាស្រ្តាចារ្យយល់ស្របនឹងការលើកឡើងរបស់មេធាវី ដោយបញ្ជាក់ថា មន្ត្រីនៅក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា គឺជាអតីតកម្មាភិបាលខ្មែរក្រហមដែលរត់ភៀសខ្លួនទៅវៀតណាម ដែលក្នុងនោះក៏មានលោក ហ៊ុន សែន បានទៅមុនអ្នកទាំងឡាយទៀត ហើយបន្ទាប់មកអ្នកទាំងនោះបានសុំស្នាក់នៅ និងការគាំទ្រពីប្រទេសវៀតណាម ។ បន្ទាប់ពីលោកសាស្រ្តាចារ្យបានលើកឡើងថា លោក ហ៊ុន សែន បានរត់ទៅប្រទេសវៀតណាមមុនបុគ្គលផ្សេងទៀត លោកមេធាវីបានសួរទៀតថា តើលោកសាស្រ្តាចារ្យអាចបញ្ជាក់បានទេថា លោក ហ៊ុន សែន និងអ្នកដទៃទៀតបានរត់ទៅប្រទេសវៀតណាមនៅឆ្នាំណា? ប៉ុន្តែនៅពេលសួរមកដល់សំណួរនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ថារីក បានជំទាស់ ដោយអះអាងថា សំណួររបស់មេធាវីការពារក្តី មិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលមានចោទប្រកាន់ ។ ទោះបីជាមានការបកស្រាយពីលោកមេធាវីការពារក្តីឆ្លើយតបនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានបង្គាប់ឲ្យលោកសាស្រ្តាចារ្យ ឆេនដល័រ មិនចាំបាច់ឆ្លើយតបចំពោះសំណួររបស់មេធាវីការពារក្តី នួន ជា ឡើយ ដោយអះអាងថា ការជំទាស់របស់តំណាង សហព្រះរាជអាជ្ញាមានមូលដ្ឋានត្រឹមត្រូវ ។

បន្ទាប់ពីការជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរដែលពាក់ព័ន្ធនឹងពេលវេលាដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានភៀសខ្លួនទៅប្រទេសវៀតណាម លោកមេធាវីការពារក្តី នួន ជា បានព្យាយាមសួរសំណួរជាច្រើនទាក់ទងនឹងការយល់ឃើញរបស់លោកសាស្រ្តាចារ្យ ឆេនដល័រ ទាក់ទងនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនាំឲ្យមានការអាម៉ាស់ដល់រដ្ឋាភិបាលបច្ចុប្បន្ន ប៉ុន្តែលោកសាស្រ្តាចារ្យបានអះអាងថា លោកមិនអាចឆ្លើយតបចំពោះសំណួរនេះបានទេ ។

**គួរកត់សម្គាល់ថា** មុនពេលបញ្ចប់ការសួរដេញដោលរបស់ខ្លួន លោកមេធាវី ហ្សាស្តេ ប៉ោ បានព្យាយាមសួរម្តងហើយម្តងទៀតទាក់ទងនឹងការកោះអញ្ជើញមន្ត្រីរដ្ឋាភិបាលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ និងព្យាយាមលើកឡើងអំពីឥរិយាបថរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែសំណួរទាំងនេះត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុផលថា លោកសាស្រ្តាចារ្យ ឆេនដល័រ

មិនអាចឆ្លើយតបចំពោះប្រភេទសំណួររបស់មេធាវីការពារក្ដី នួន ជា បានទេ ។ ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានយល់ស្របជាមួយការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយបង្គាប់ឲ្យលោកសាស្ត្រាចារ្យ មិនចាំបាច់ឆ្លើយតបចំពោះសំណួរដែលលើកឡើងដោយលោកមេធាវីការពារក្ដីទេ ដោយសារសំណួរទាំងនេះមិនទាក់ទងនឹងអង្គហេតុ ។ ឆ្លើយតបនឹងការបដិសេធរបស់អង្គជំនុំជម្រះ លោកមេធាវី ហ្សាស្តើ បានលើកឡើងថា អង្គជំនុំជម្រះមិនផ្ដល់ឱកាសឲ្យខ្លួនសួរសំណួរដែលខ្លួនចង់សួរ នៅពេលដែលការផ្ដល់សក្ខីកម្មក្នុងសវនាការមុនរបស់លោកសាស្ត្រាចារ្យ ឆេនដល័រ មានភាពខុសគ្នានឹងឯកសារដែលលោកបានសរសេរ ហើយក្រុមមេធាវីការពារក្ដី នួន ជា មានបំណងប្រើប្រាស់ឯកសារទាំងនោះដើម្បីសាកសួរ ។ ឆ្លើយតបនឹងការលើកឡើងរបស់លោកមេធាវី ហ្សាស្តើ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានបង្គាប់ឲ្យលោកមេធាវីធ្វើសេចក្ដីសន្និដ្ឋានលាយលក្ខណ៍អក្សរតាមវិធាន៩២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ជាជាងការលើកឡើងនៅក្នុងសវនាការ ។

ដោយមានចេតនាក្នុងការតបតចំពោះការលើកឡើងរបស់អង្គជំនុំជម្រះ លោកមេធាវីបានឆ្លើយតបភ្លាមៗថា ក្នុងនាមជាប្រធានអង្គជំនុំជម្រះ លោកប្រធានមានតួនាទីយ៉ាងសំខាន់ក្នុងការធានាឲ្យមានសិទ្ធិទទួលបានការកាត់ក្ដីដោយយុត្តិធម៌ចំពោះភាគីការពារក្ដី ។ លោកប្រធានបានបញ្ជាក់ជាថ្មីម្ដងទៀត ដោយស្នើឲ្យលោកមេធាវីដាក់ឯកសារជាលាយលក្ខណ៍អក្សរចំពោះសេចក្ដីសន្និដ្ឋានរបស់ខ្លួន ។

បន្ទាប់ពីលោកមេធាវី ហ្សាស្តើ ជ៉ោ បានបញ្ចប់ការសាកសួរ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីអន្តរជាតិការពារក្ដី នួន ជា មួយរូបទៀត គឺលោកមេធាវី អេនឌ្រូ អ៊ីនូហ្ស៊ី (Andrew IANUZZI) ដើម្បីបន្តសាកសួរលោក សាស្ត្រាចារ្យដេវីត ឆេនដល័រ ។ លោកមេធាវី អ៊ីនូហ្ស៊ី បានរំឭកអំពីសក្ខីកម្មរបស់លោកសាស្ត្រាចារ្យ ឆេនដល័រ និងបានស្នើឲ្យលោកសាស្ត្រាចារ្យពន្យល់ ដោយលោកមេធាវីធ្វើការប្រៀបធៀបលេខាគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជានឹងអនុប្រធានគណៈបក្សប្រជាជនកម្ពុជាសព្វថ្ងៃ ប៉ុន្តែសំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាជំទាស់ដោយសារមិនពាក់ព័ន្ធនឹងអង្គហេតុ ។ បន្ទាប់មក លោកមេធាវីបានព្យាយាមបន្តសំណួរទាក់ទងនឹងយោបល់ផ្ទាល់របស់លោកសាស្ត្រាចារ្យចំពោះការមិនផ្ដល់សក្ខីកម្មរបស់កម្មាភិបាលខ្មែរក្រហមចំពោះអំពើរបស់កម្មាភិបាលផ្សេងទៀត ដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។ ជាថ្មីម្ដងទៀតសំណួរនេះត្រូវបានជំទាស់ដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ ដោយលោកអះអាងថា អ្នកជំនាញមិនគួរឲ្យផ្ដល់យោបល់លើការសង្កេតរបស់ខ្លួនឡើយ ។ ចំពោះសំណួរចុងក្រោយរបស់ខ្លួន លោកមេធាវីនៅតែព្យាយាមម្ដងហើយម្ដងទៀតសំដៅដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែទោះបីជាមានការព្យាយាមក្នុងការបង្វែរសំណួរយ៉ាងណាក៏ដោយ សំណួររបស់លោកមេធាវីនៅតែត្រូវបានបដិសេធដោយភាគីសហព្រះរាជអាជ្ញា ។

មុនពេលបញ្ចប់ការសាកសួររបស់ខ្លួន លោកមេធាវីបានលើកឡើងថា ជំហររបស់ខ្លួនគឺនៅតែចង់បញ្ជាក់ថា កាយវិការរបស់រដ្ឋាភិបាល គឺពិតជាអាចជះឥទ្ធិពលដល់ដំណើរការស្វែងរកយុត្តិធម៌នៅក្នុងតុលាការ ហើយជាបញ្ហាចំបាច់ដែលត្រូវដោះស្រាយ ។

## ៤.២) ការសាកសួរដោយក្រុមមេធាវីការពារក្ដី អៀង សារី

បន្ទាប់ពីក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្ដី អៀង សារី បន្តការសាកសួរដេញដោលលោកសាស្ត្រាចារ្យ ឆេនដល័រ អំពីសៀវភៅដែលលោកបានសរសេរទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងការផ្ដល់សក្ខីកម្មរបស់លោកចំពោះសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។ ក្នុងអំឡុងពេលនៃការសួរដេញដោល មានតែមេធាវីអន្តរជាតិការពារក្ដី អៀង សារី មួយរូបប៉ុណ្ណោះ ដែលបានចោទសួរលោកសាស្ត្រាចារ្យ ឆេនដល័រ ។ ភាគច្រើននៅក្នុងការសួរដេញដោលរបស់ខ្លួន ក្រុមមេធាវីការពារក្ដី អៀង សារី មិនបានផ្ដោតសំខាន់លើសៀវភៅដែលលោកសាស្ត្រាចារ្យបានសរសេរទេ ប៉ុន្តែបានប្រើយុទ្ធសាស្ត្រផ្ដោតសំខាន់លើប្រតិចារឹក ឬចម្លើយដែលលោកសាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយចំពោះសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅអំឡុងពេលសវនាការ ។ មេធាវីអន្តរជាតិការពារក្ដី

អៀង សារី បានប្រើប្រាស់ពេលវេលា ស្ទើរពេញមួយថ្ងៃនៅក្នុងការសួរដេញដោលរបស់ខ្លួន ។

***៤.១.១) កំណត់សម្គាល់មេធាវី កាណាវ៉ាស លើរូបលោកសាស្ត្រាចារ្យ ឆេនដល័រ***

មុនពេលចាប់ផ្តើមសួរសំណួរ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស (Micheal KANAVAS) បានធ្វើការកត់សម្គាល់ថា លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ហាក់បីដូចជាមានការលម្អៀងទៅភាគីសហព្រះរាជអាជ្ញាដោយសារសំណួររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដែលសាកសួរអ្នកជំនាញអំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនោះ លោកមិនបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះថាគួរឆ្លើយតបនឹងសំណួរនោះបុយ៉ាងណាឡើយ ។ ដោយឡែក លោកសាស្ត្រាចារ្យបានស្នើសុំការអនុញ្ញាតអង្គជំនុំជម្រះ នៅពេលមានការសាកសួរសំណួរក្នុងប្រធានបទដូចគ្នាពីសំណាក់មេធាវីការពារក្តី ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្តី លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកសុំការអនុញ្ញាតដូច្នេះ ដោយសារប្រធានបទនេះចាកឆ្ងាយពីរបបខ្មែរក្រហម ហេតុនេះលោកមិនចង់លើកយកបញ្ហានេះមកពិភាក្សានៅក្នុងសវនាការទេ ។

លោកមេធាវី កាណាវ៉ាស បានលើកឡើងនូវបញ្ហាដែលលោកកត់សម្គាល់មួយទៀត ទាក់ទងនឹងការជួបគ្នារវាងលោកសាស្ត្រាចារ្យ ឆេនដល័រ និងលោក ស្ទីវ ហេដឺរ (Steve Heder) ដែលជាបុគ្គលិករបស់តុលាការ ។ ឆ្លើយតបនឹងការលើកឡើងដូច្នេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា លោកពិតជាធ្លាប់បានជួបគ្នា ប៉ុន្តែមុនពេលលោកចូលមកផ្តល់សក្ខីកម្ម លោកមិនបានសួរនាំពីការផ្តល់សក្ខីកម្មនៅក្នុងតុលាការឡើយ ។ លោកបានបន្តថា លោកបានជួបជាមួយលោក ហេដឺរ ក្នុងនាមជាមិត្តភក្តិជាងសាមសិបឆ្នាំ ម្យ៉ាងវិញទៀតការពិភាក្សានេះ គឺផ្តោតលើការវិវឌ្ឍរបស់តុលាការតែប៉ុណ្ណោះ ។ លោកសាស្ត្រាចារ្យបានលើកឡើងទៀតថា លោកធ្លាប់បានទទួលបានឯកសារពីលោក ហេដឺរ ប៉ុន្តែឯកសារនោះលោកមិនបានប្រើប្រាស់ឡើយ ដោយសារមានការហាមឃាត់ពីលោក ហេដឺរ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ថារីក បានកត់សម្គាល់ចំពោះសំណួររបស់មេធាវីការពារក្តី ដោយបានលើកឡើងថា មេធាវីការពារក្តីគួរតែសួរសំណួរ ដែលអាចឲ្យអ្នកជំនាញផ្តល់យោបល់ ជៀសជាងការសួរសំណួរពីការជួបគ្នារបស់អ្នកជំនាញ ដែលជាបញ្ហាដោយឡែក ។ ឆ្លើយតបនឹងការកត់សម្គាល់នេះ លោកមេធាវី កាណាវ៉ាស បានអះអាងថា លោក ហេដឺរ ជាអ្នកបម្រើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដូច្នេះលោកមិនគួរពិភាក្សាជាមួយអ្នកខាងក្រៅឡើយ ។ បន្ថែមពីលើនេះ បញ្ហានឹងអាចកើតឡើង ប្រសិនបើលោក ហេដឺរ ដែលធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា និងបន្ទាប់មកផ្លាស់



លោកមេធាវី ម៉ៃឃើល កាណាវ៉ាស

ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ពិភាក្សាគ្នាជាមួយអ្នកជំនាញមុនពេលផ្តល់សក្ខីកម្ម ។ ដើម្បីដោះស្រាយបញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី លោកចៅក្រម ហ្សង់ម៉ាក ឡាវែរញ (Jean-Marc LAVERGNE) បានរំឭកដល់មេធាវីការពារក្តីថា អង្គជំនុំជម្រះនឹងធ្វើការពិភាក្សាតែលើសំណុំរឿង ០០២ប៉ុណ្ណោះ ដូច្នេះរាល់បញ្ហាផ្សេងៗមិនត្រូវបានអង្គជំនុំជម្រះយកមកពិភាក្សាឡើយ ។

លោកមេធាវី កាណាវ៉ាស បានលើកឡើងអំពីការកត់សម្គាល់របស់ខ្លួនទាក់ទងនឹងការអានដីកាដំណោះស្រាយ ដោយលោលសាស្ត្រាចារ្យ ឆេនដល័រ មុនពេលលោកចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ ឆ្លើយតបចំពោះការកត់សម្គាល់នេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា មុនពេលលោក

មកដល់ទីក្រុងភ្នំពេញ លោកមិនបានឃើញដីកាដំណោះស្រាយទេ ប៉ុន្តែលោកបានអានឯកសារនេះនៅពេលលោកមកដល់ទីក្រុងភ្នំពេញ ហើយបានអានត្រឹមតែកំណត់សម្គាល់ជើងទំព័រ(Footnotes) នៃដីកាដំណោះស្រាយមួយចំនួនប៉ុណ្ណោះ ។ ចំពោះឯកសារផ្សេងទៀត លោកបានអានឯកសាររបស់លោក ចន ឆរឆីអារី ដែលនិយាយអំពីសាលាក្ដីខ្មែរក្រហម និងសៀវភៅទាក់ទងនឹងបេក្ខជនទាំងប្រាំពីររូបដែលត្រូវបានចោទប្រកាន់របស់លោក ស្ទីវ ហេដឌ័រ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបន្តថា លោកមិនមានបំណងដកស្រង់គំនិតថ្មីៗចេញពីដីកាដំណោះស្រាយដែលនិយាយអំពីសេចក្ដីថ្លែងការណ៍របស់ ប៉ុល ពត នោះឡើយ ដោយលោក


លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

អះអាងថា ដីកាដំណោះស្រាយមិនអាចកែប្រែគំនិតយោបល់របស់លោកបានឡើយ ។

### ៤.១.២) ហេតុ និងផល នៃការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា

លោកមេធាវី កាណាវ៉ាស បានបន្តសំណួរទាក់ទងនឹងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកលើប្រទេសកម្ពុជា ដោយចោទសួរលោកសាស្ត្រាចារ្យថា តើហេតុអ្វីបានជាសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា? លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកគឺចាប់ផ្ដើមនៅឆ្នាំ១៩៦៧ ដែលជាផ្នែកមួយនៃសង្គ្រាមអាមេរិកប្រឆាំងនឹងវៀតណាមខាងជើង ដោយសារអាមេរិកគាំទ្រវៀតណាមខាងត្បូង ប៉ុន្តែមិនមែនជាសង្គ្រាមជាមួយកម្ពុជាទេ ។ លោកពន្យល់បន្ថែមថា គោលដៅនៃការទម្លាក់គ្រាប់បែកនោះគឺសំដៅផ្លូវលំហូ ជីមិញ ដែលកាត់ប្រទេសកម្ពុជា វៀតណាមខាងជើង ឡាវ ទៅកាន់វៀតណាមខាងត្បូង ។ លោកបានបន្តថា មានភាពពាក់ព័ន្ធគ្នាដែលថា សម្ដេច សីហនុ បានរៀបចំឲ្យមានការដឹកជញ្ជូនអាវុធពីចិនទៅវៀតណាមខាងជើង ដោយទ្រង់នៅតែមានបំណងរក្សាទំនងទំនងជាមួយអាមេរិក និងចិន ប៉ុន្តែក្រោយមកទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកត្រូវបានកាត់ផ្ដាច់នៅឆ្នាំ១៩៦៤ ។ ការភ្ជាប់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិកគឺជាការបន្តឲ្យមានការទម្លាក់គ្រាប់បែកនៅលើផ្លូវលំ ហូជីមិញ ដោយកម្ពុជាមិនខ្វល់ពីអ្វីដែលកើតឡើងនៅក្នុងប្រទេសវៀតណាមឡើយ ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទៀតថា តើមានផលប៉ះពាល់អ្វីខ្លះដែលបណ្ដាលមកពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកលើប្រទេសកម្ពុជានាពេលនោះ? លោកសាស្ត្រាចារ្យបានអះអាងថា ប្រជាជនកម្ពុជា និងប្រជាជនវៀតណាម ដែលរស់នៅតាមព្រំដែនមានការលំបាកយ៉ាងខ្លាំង នៅពេលទាហានវៀតណាមខាងជើងចូលដល់តំបន់ព្រំដែន ។ លោកមេធាវីបានបន្តសួរទាក់ទងនឹងផលប៉ះពាល់ផ្នែកផ្លូវចិត្តរបស់ប្រជាជន ដោយសារការទម្លាក់គ្រាប់បែកនាពេលនោះ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមិនបានធ្វើសម្ភាសន៍ជាមួយប្រជាជនទាក់ទងនឹងបញ្ហានេះឡើយ ប៉ុន្តែលោកជឿជាក់ថា ផលប៉ះពាល់ គឺពិតជាមាន ។

### ៤.១.៣) តួលេខចំនួនអ្នកស្លាប់ដោយសារខ្មែរក្រហម

ទាក់ទងនឹងតួលេខនៃចំនួនមនុស្សដែលបានស្លាប់បាត់បង់ជីវិតពីសម័យខ្មែរក្រហម លោកមេធាវីបានចោទសួរថា តើលោកសាស្ត្រាចារ្យមានតួលេខអំពីចំនួនមនុស្សដែលស្លាប់នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកដែរឬទេ? លោក ឆេនដល័រ បានអះអាងថា ផ្អែកតាមការស្រាវជ្រាវជនជាតិប៉ូឡូញដែលមានឈ្មោះ ស្លីវីនស្គី (Slivinski) ហើយម្នាក់ទៀតឈ្មោះ ផាទ្រិក ហេវើលីន (Patrick Heuveline) នៅឆ្នាំ១៩៦២ ប្រជាជនដែលស្លាប់ដោយសារការទម្លាក់គ្រាប់បែក មានចំនួនប្រាំសែននាក់ ហើយប្រជាជន

ទាំងអស់មានចំនួនប្រាំមួយលាននាក់ ។

លោកមេធាវី កាណាវ៉ាស បានបន្តការសាកសួរលោកសាស្ត្រាចារ្យទាក់ទងនឹងការគិតគូរផ្សេងៗគ្នា ចំពោះតួលេខមនុស្សដែលបានស្លាប់បាត់បង់ជីវិត ។ ឆ្លើយតបនឹងបញ្ហានេះ លោកដេវីដ ឆេនដល័រ បានអះអាងថា លោកកំណត់ចំនួន១.៥លាននាក់ តាមការសិក្សារបស់លោក ។ បន្ទាប់មកលោកមេធាវីបានលើកឡើងពីតួលេខខុសៗគ្នាដែលសាស្ត្រាចារ្យ ឆេនដល័រ បានផ្តល់នៅឆ្នាំ១៩៩១,១៩៩២ និង១៩៩៤ ដោយមិនមានការយោងទៅលើឯកសារណាមួយ ។ ឆ្លើយតបសំណួរនេះលោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកបានសរសេរថា ចំនួនមនុស្សស្លាប់មានជាងមួយលាននាក់នៅឆ្នាំ១៩៩០ ហើយមុនពេលលោកប្រឡប់មកប្រទេសកម្ពុជា លោកបានកែសម្រួលចំនួននោះទៅជា១.៥ ទៅ២លាននាក់ ។ លោកបានសុំអភ័យទោសចំពោះការដែលខកខានមិនបានយោងទៅលើឯកសារណាមួយ ដោយបញ្ជាក់ថា ចំនួនទាំងនោះគឺសុទ្ធតែជាចំនួនសន្មត់ ។ ទាក់ទងនឹងតួលេខដែលលោកទទួលបានពីអ្នកប្រជាសាស្ត្រ លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា លោកមិនអាចទាក់ទងអ្នកប្រជាសាស្ត្រទាំងនោះបានទេ នៅពេលដែលលោកមានការសង្ស័យចំពោះប្រភពដែលយោងនោះ ហើយលោកមិនអាចរកព័ត៌មានជំនួយពីនេះចេញពីឯកសារបោះពុម្ពផ្សាយណាមួយនោះឡើយ ។ លោកបានបន្តទៀតថា ចំនួនតួលេខពិតប្រាកដមិនអាចរកបានទេ ហើយអ្នកស្រាវជ្រាវទាំងអស់បានប្រើប្រាស់តួលេខដែលទទួលបានពីការធ្វើជំរឿនប្រជាជននៅឆ្នាំ១៩៦២និងឆ្នាំ១៩៩៨ ដែលអាចរកឃើញតួលេខមនុស្សស្លាប់នៅចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៩ ។

### ៤.១.៤) ការប្រជុំ និងសម្រេច

ទាក់ទងនឹងការប្រជុំ និងសម្រេចរបស់គណៈអចិន្ត្រៃយ៍ លោកមេធាវី កាណាវ៉ាស បានលើកយកប្រតិចារឹកនៃសវនាការដែលលោកសាស្ត្រាចារ្យបានឆ្លើយតបនឹងសំណួរសហព្រះរាជអាជ្ញា និងស្នើលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការបញ្ជាក់អំពីអ្វីដែលលោកបានលើកឡើងពាក់ព័ន្ធនឹងផែនការផលិតស្រូវឲ្យបាន៣តោនក្នុង១ហិចតារបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានអះអាងថា គោលនយោបាយនេះលោកបានសិក្សា និងសរសេរនៅក្នុងសៀវភៅដែលមានចំណងជើងថា "ប៉ុល ពត រៀបចំផែនការនៅថ្ងៃអនាគត" ។ លោកបានពន្យល់ទៀតថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យធ្វើការដឹកនាំជាលក្ខណៈសមូហភាព ដូច្នេះរាល់ការសម្រេច គឺត្រូវធ្វើឡើងដោយមានការចូលរួមពីសមាជិកទាំងអស់ ។ ប៉ុន្តែរាល់ការសម្រេចចុងក្រោយ គឺត្រូវធ្វើឡើងដោយលេខាបក្ស ដោយមិនមាននរណាម្នាក់មានសិទ្ធិលើសពីនេះទៀតឡើយ ។ កន្លងមកលោកមិនធ្លាប់បានឃើញឯកសារណាមួយដែលបញ្ជាក់ថា ប៉ុល ពត ជាអ្នកធ្វើការ



មេដឹកនាំកម្ពុជាប្រជាធិបតេយ្យជួបជាមួយគណៈប្រតិភូបរទេស (រូបថតឯកសារ

សម្រេចចិត្តតែម្នាក់ឯងឡើយ ប៉ុន្តែការអះអាងដូច្នេះ គឺគ្រាន់តែជាការសន្និដ្ឋានរបស់លោកតែប៉ុណ្ណោះ ។

លោកមេធាវី កាណាវ៉ាស បានបន្តការសួរសំណួរជាច្រើនទៀតទាក់ទងនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិម និងបុគ្គលដែលចូលរួមក្នុងកិច្ចប្រជុំនោះ ។ ឆ្លើយតបនឹងសំណួរទាំងនោះលោកសាស្ត្រាចារ្យ ឆេនដល័រ បានបដិសេធមិនផ្តល់ចម្លើយ ដោយសារលោកមិនច្បាស់ពីបញ្ហានេះ ហើយលោកមិនបានយកឯកសារពាក់ព័ន្ធនៅក្នុងកិច្ចប្រជុំនោះមកជាមួយ ។ លោកគ្រាន់តែបញ្ជាក់ជូនមេធាវីថា បើតាមឯកសារដែលលោកធ្លាប់ជួប កិច្ចប្រជុំ គឺធ្វើឡើងរៀង

រាល់សប្តាហ៍ ។

លោកមេធាវី កាណាវ៉ាស បានលើកយកប្រតិចារឹកសវនាការទាក់ទងនឹងការឆ្លើយសំណួររបស់លោកសាស្ត្រាចារ្យ ចំពោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ដើម្បីសាកសួរលោកសាស្ត្រាចារ្យទាក់ទងនឹងពាក្យថា "អង្គការ" ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ពាក្យ "អង្គការ" ត្រូវបានហៅនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ហើយពាក្យនេះត្រូវបានប្រជាជននៅតាមទីជនបទ



មជ្ឈមណ្ឌលឯកសារកម្ពុជា)

យល់ថា អង្គការគឺជាមនុស្ស ប៉ុន្តែមិនដឹងថាតើសំដៅលើបុគ្គលណាមួយ ឬជាក្រុមមនុស្សឡើយ ។ លោកមិនគិតថាមានឯកសារណាដែលអះអាងថា "អង្គការ" គឺសំដៅលើ ប៉ុល ពត នោះទេ ។

### ៤.១.៥) ឌុច មានទំនាក់ទំនងជាមួយគណៈមជ្ឈិមទាំងមូលឬយ៉ាងណា?

លោកមេធាវី កាណាវ៉ាស បានបន្តលើកយកប្រតិចារឹកសវនាការថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ ទាក់ទងនឹងការឆ្លើយសំណួររបស់លោកសាស្ត្រាចារ្យជាមួយនឹងតំណាងសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងផ្នែកដែលលើកឡើងអំពីទំនាក់ទំនងរវាងស-២១ ដែលគ្រប់គ្រងដោយ ឌុច ជាមួយគណៈមជ្ឈិម ដើម្បីធ្វើការបញ្ជាក់ ។ លោកមេធាវីបានដកស្រង់ពាក្យសម្តីរបស់លោកសាស្ត្រាចារ្យដែលបានអះអាងនៅពេលនោះ ដើម្បីឲ្យលោកធ្វើការបញ្ជាក់ឡើងវិញ ។ ឃ្លានោះលោកសាស្ត្រាចារ្យបានលើកឡើងថា "មិនមានឯកសារណាមួយដែលភ្ជាប់ ប៉ុល ពត និងអៀង សារី ទៅនឹងសេចក្តីសម្រេចម្តេចមនុស្សនៅស-២១ទេ" ។ លោកមេធាវីបានអានបន្តទៀតថា "ឌុច ខ្លួនឯងផ្ទាល់ ធ្វើការទំនាក់ទំនងជាមួយ សុន សេន ហើយពេល ខ្លះធ្វើការជាមួយ នួន ជា" ។ ឆ្លើយតបសំណើនេះ លោកសាស្ត្រាចារ្យបានសុំធ្វើការកែតម្រូវចំពោះចំណុចដែលលើកឡើងថា ឌុច មានទំនាក់ទំនងជាមួយគណៈមជ្ឈិម ដោយលោកបញ្ជាក់ ឌុច មានទំនាក់ទំនង ជាមួយ សុន សេន ហើយ សុន សេនគឺជាសមាជិកនៃគណៈមជ្ឈិម ។ដូច្នេះរាល់លិខិតទាំងឡាយ ឌុច បញ្ជូនឲ្យមជ្ឈិម គឺសំដៅលើ សុន សេន មិនមែនគណៈមជ្ឈិមទាំងមូលទេ ។ បន្ទាប់មកទើប សុន សេន បញ្ជូនលិខិតទាំងនោះឲ្យសមាជិកដទៃទៀតនៃគណៈមជ្ឈិម ។ ហេតុនេះ ឌុចមិនមានទំនាក់ទំនងជាមួយគណៈមជ្ឈិមទាំងមូលទេ ។

**កំណត់សម្គាល់៖** មេធាវីការពារក្តី អៀង សារី ចោទសំណួរនេះឡើង គឺដើម្បីបង្ហាញថា កូនក្តីរបស់ខ្លួនមិនមានជាប់ពាក់ព័ន្ធនឹងការសម្រេចកម្ទេចអ្នកទោស និងអ្នកជាប់ឃុំនៅស-២១ ។

### ៤.១.៦) បងធំទី៣

លោកមេធាវីកាណាវ៉ាស បានបន្តបង្ហាញឯកសារទាក់ទងនឹងសៀវភៅ "បងធំទី១" ដែលរៀបរាប់អំពីការរស់នៅរបស់មេដឹកនាំខ្មែរក្រហមដែលមាន អៀង សារី និងអ្នកដឹកនាំផ្សេងទៀត នៅខេត្តក្រចេះ មណ្ឌលគិរី ដែលប្រជាជនមានការខឹងសម្បាជាមួយរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានរក្សានូវជំហររបស់លោកចំពោះការលើកឡើងនេះ ដោយលោកបន្ថែមថា បញ្ហានេះក៏អាចជាមូលហេតុដែលនាំឲ្យប្រជាជនចូលរួមចលនាបដិវត្ត ឬយ៉ាងហោចណាស់ជាការជំរុញឲ្យមានការដឹកនាំបដិវត្តន៍ប្រឆាំងនឹងរដ្ឋាភិបាលដែរ ។

បន្ទាប់មក លោកមេធាវីបានបន្តការសាកសួរទាក់ទងនឹងការបកស្រាយរបស់សាស្ត្រាចារ្យ ឆេនដល័រ ដែលថា សុន សេន គឺជាបងទី៣នៅក្នុងបក្ស ។ ទាក់ទងនឹងបញ្ហានេះ លោកសាស្ត្រាចារ្យ

បានទទួលស្គាល់ចំពោះអ្វីដែលលោកបានលើកឡើងដូច្នេះ ដោយលោកបានបញ្ជាក់ថាករណីនេះ គឺមានភស្តុតាងបញ្ជាក់ ។

មុនពេលបញ្ចប់ការសាកសួរដេញដោលរបស់ខ្លួន លោកមេធាវី កាណាវ៉ាស បានថ្លែងអំណរគុណចំពោះការសហការណ៍របស់លោកសាស្ត្រាចារ្យក្នុងផ្តល់សក្ខីកម្មបំភ្លឺពីការងារស្រាវជ្រាវពីប្រវត្តិសាស្ត្ររបស់លោក ។ បន្ទាប់មកប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកានៃការសាកសួរដេញដោលជូនមេធាវីការពារក្តី ខៀវ សំផន ។

## ៤.គ) ការសាកសួរដោយក្រុមមេធាវីការពារក្តី ខៀវ សំផន

ក្នុងអំឡុងពេលនៃការសួរដេញដោល ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានផ្តោតជាសំខាន់លើប្រវត្តិតស៊ូផ្នែកនយោបាយ ដំណែង និងតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់កូនក្តីរបស់ខ្លួន និងឯកសារដែលប្រើប្រាស់នៅក្នុងតុលាការនាពេលបច្ចុប្បន្ន ។ ការសួរដេញដោលបានចាប់ផ្តើមដោយមេធាវីជាតិ គឺលោកមេធាវី គង់ សំអុន និងបន្ទាប់មក គឺមេធាវីអន្តរជាតិ អាកទូ វែកគែន ។

### ៤.គ.១) ប្រវត្តិតស៊ូនយោបាយរបស់ ខៀវ សំផន

មុនពេលសាកសួរសំណួរជាក់លាក់ លោកមេធាវី គង់ សំអុន បានចោទសួរលោកសាស្ត្រាចារ្យ ឆេនដល័រ នូវសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិនៃការសិក្សា និងស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចម្លើយនៃសំណួរទាំងនោះ គឺលោកសាស្ត្រាចារ្យធ្លាប់បានឆ្លើយចំពោះសំណួររបស់តំណាងសហព្រះរាជអាជ្ញារួចហើយ ។

បន្ទាប់មកលោកមេធាវីបានបន្តសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិតស៊ូផ្នែកនយោបាយរបស់ជនជាប់ចោទ ខៀវ សំផន ដោយស្នើលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ក្នុងឋានៈលោកជាប្រវត្តិវិទូដែលស្រាវជ្រាវអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ជាពិសេសរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមិនធ្លាប់បានជួបជនជាប់ចោទ ខៀវ សំផន ពីមុនមកទេ ប៉ុន្តែលោកមានការចាប់អារម្មណ៍ ដោយសារ ខៀវ សំផន មានភាពល្បីល្បាញ ហើយពេលនោះ សម្តេច សីហនុ ក៏មានការព្រួយបារម្ភអំពីភាពល្បីល្បាញរបស់ជនជាប់ចោទរូបនេះដែរ ។ ខៀវ សំផន មានទំនាក់ទំនងល្អជាមួយប្រជាជន មិនដែលជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ និងជាមនុស្សដែលមានសមត្ថភាពខ្ពស់ និងមានឥទ្ធិពលនៅក្នុងសង្គម ។

បន្ទាប់មកលោកមេធាវី បានបន្តសួរទាក់ទងនឹងមូលហេតុដែលនាំឲ្យ ខៀវ សំផន រត់ចូលក្នុងព្រៃ ។ សាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ពេលនោះគឺជាពេលលំបាកមួយសម្រាប់ប្រទេសកម្ពុជា ឬជាពេលដែលជម្លោះក្នុងប្រទេសកម្ពុជាចាប់ផ្តើមផ្ទុះឡើង ដូចជា អំពើបះបោរនៅសំឡូត ការប្រកាន់លទ្ធិម៉ៅរបស់ប្រជាជនដែលនាំឲ្យមានការចោទប្រកាន់ចំពោះ ហ៊ូ នឹម ។ លោកបានបន្តថាតាមរយៈការអានឯកសារប្រវត្តិរូបរបស់ ខៀវ សំផន លោកអាចដឹងថា ខៀវ សំផន បានរត់ចូលទៅក្នុងព្រៃដោយសារខ្លួនមានការភ័យខ្លាច ។ ខៀវ សំផន គឺជាសមាជិកសម្ងាត់របស់បក្សកុម្មុយនីស្ត ដោយលោកបានបញ្ជាក់ថាចំណុចនេះ មាននិយាយនៅក្នុងឯកសារ ប៉ុន្តែលោកមិនបានយកឯកសារនោះមកជាមួយនោះទេ ។ លោកមេធាវី សំអុន បានស្នើឲ្យសាស្ត្រាចារ្យ ឆេនដល័រ ពន្យល់អំពីការចូលជាសមាជិកសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ចំពោះសំណួរនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា នៅពេលនោះមិនមានការចូលជាសមាជិកបក្សកុម្មុយនីស្តដោយចំហរទេ ជាទូទៅសមាជិកទាំងអស់ត្រូវចូលជាសមាជិកសម្ងាត់របស់បក្ស ។

បន្ទាប់មកលោកមេធាវីបន្តសួរទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងបក្សកុម្មុនីស្ត ថាតើ ខៀវ សំផន នៅពេលនោះមាន



ខៀវ សំផន

(រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តួនាទីអ្វីខ្លះ? លោកសាស្ត្រាចារ្យអះអាងថា ខៀវ សំផន បានចូលជាសមាជិកត្រៀមរបស់គណៈមជ្ឈិមបក្សនៅឆ្នាំ១៩៧១ ដោយលោកយោងលើព័ត៌មាននៅក្នុងដីកាដំណោះស្រាយ និងឯកសារបទសម្ភាសន៍ជាមួយ ខៀវ សំផន ផ្ទាល់ ដែលមាននៅក្នុងកំណត់សម្គាល់ជើងទំព័រនៃដីកាដំណោះស្រាយ ។ ក្រោយមក ខៀវ សំផន បានចូលជាសមាជិកពេញសិទ្ធិនៃគណៈមជ្ឈិមនៅខែកក្កដា ឆ្នាំ១៩៧៦ ។

### ៤.ក.២) អំណាចនៃស្ថាប័ន និងអំណាចរបស់បក្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

លោកមេធាវី សំអុន បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើយោងតាមមាត្រាដែលមានបង្ហាញនៅក្នុងរដ្ឋធម្មនុញ្ញ មុខដំណែងដែលធំជាងគេ គឺតំណែងជាប្រធានគណៈប្រធានរដ្ឋ ។ លោកបានអះអាងបន្តថា ការអនុវត្តអំណាចគឺធ្វើឡើងតាមរយៈគណៈមជ្ឈិម និង គណៈអចិន្ត្រៃយ៍ ហើយអំណាចនេះអនុវត្តតាមបែបពីរ៉ាមីត ។ រីឯ សកម្មភាពរបស់រដ្ឋាភិបាល និងបក្សកុម្មុយនីស្តកម្ពុជា គឺគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាដែលមានអំណាចលើមន្ទីរផ្សេងៗ ដែលមន្ទីរខ្លះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ហើយមន្ទីរខ្លះទៀតមិនមានចែង ។ លោកបានបន្ថែមថា ការបែងចែកនេះមានរក្សាការសម្ងាត់ ដូច្នេះការបែងចែកនេះពេលខ្លះមានភាពស្រពិចស្រពិល ហើយពេលខ្លះមានការជាន់តួនាទីគ្នានៅក្នុងក្រសួងមន្ទីរ ។


អៀង សារី

បន្ទាប់មក លោកមេធាវីបានស្នើសុំអង្គជំនុំជម្រះបង្ហាញឯកសារទាក់ទងនឹងសេចក្តីសម្រេចរបស់គណៈមជ្ឈិម ដោយលោកបានអានត្រង់ឃ្លាមួយដើម្បីឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ ។ ឃ្លានោះបានសរសេរថា "ប៉ុល ពត ជាមនុស្សដែលមានឥទ្ធិពលខ្លាំងនៅក្នុងរដ្ឋាភិបាល" ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ទទួលស្គាល់ថា ព័ត៌មាននៅក្នុងឯកសារនោះ គឺពិតជាត្រឹមត្រូវ ។ ទាក់ទងនឹងឥទ្ធិពលរបស់ ប៉ុល ពត នៅក្នុងបក្ស និងតួនាទីនៅក្នុងរដ្ឋាភិបាល លោកបានបញ្ជាក់ថា ការងារនៅក្នុងបក្ស និងនៅក្នុងរដ្ឋាភិបាល គឺមិនខុសគ្នាទេ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីដែលសួរថា តើអ្វីទៅជាភាពខុសគ្នារវាងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម? លោកសាស្ត្រាចារ្យបានឆ្លើយថា គឺមានលក្ខណៈខុសគ្នារវាងគណៈទាំងពីរនេះ ដោយគណៈមជ្ឈិមមានលក្ខណៈតូច រីឯគណៈអចិន្ត្រៃយ៍មានលក្ខណៈធំជាង និងមានការងារច្រើនជាង ។ ម្យ៉ាងវិញទៀត បុគ្គលដែលជាសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ គឺមានឋានៈខ្ពស់ជាងសមាជិកគណៈមជ្ឈិម ។ គណៈមជ្ឈិម គឺជាស្ថានប័នមួយនៅក្រោមគណៈអចិន្ត្រៃយ៍ដែលទទួលបញ្ជា និងយោបល់ពីគណៈអចិន្ត្រៃយ៍ ហើយការប្រជុំសំខាន់ៗរបស់គណៈមជ្ឈិម គឺមានការចូលរួមពីសមាជិករបស់គណៈអចិន្ត្រៃយ៍ដើម្បីទទួលបានព័ត៌មាន ។

### ៤.ក.៣) ចំនួននៃគ្រាប់បែកដែលបានទម្លាក់លើប្រទេសកម្ពុជា

លោកមេធាវី សំអុន បានបន្តសួរទាក់ទងនឹងចំនួននៃគ្រាប់បែកដែលសហរដ្ឋអាមេរិកបានទម្លាក់លើប្រទេសកម្ពុជា នៅមុនពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា លោកមិនច្បាស់ទេថា តើមានគ្រាប់បែកចំនួនប៉ុន្មានដែលត្រូវបានទម្លាក់មកលើប្រទេសកម្ពុជា ប៉ុន្តែលោកគ្រាន់តែដឹងថាមានចំនួននោះ គឺច្រើនរាប់រយពាន់តោន ហើយតាមការប៉ាន់ស្មានអាចមានច្រើនជាងគ្រាប់បែកដែលទម្លាក់លើប្រទេសជប៉ុនទៅទៀត ។ លោកបានបន្ថែមថា ចំនួនដ៏ច្រើននេះបានបង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដែលមិនអាចស្មានដល់ ។

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ខ្លួន លោកមេធាវីគង់ សំអុន បានផ្ទេរវេទិកាជូនសហភាគារបស់ខ្លួន គឺលោកមេធាវីអន្តរជាតិ អាកទួ វែកគែន ។

### ៤.គ.៤) ខៀវ សំផន ស្ថិតក្នុងចំណោមបុគ្គល៣៤រូបដែលមានឈ្មោះក្នុងបញ្ជី

*លោកមេធាវី វ៉ែកគែន បានចាប់ផ្តើមដំបូងដោយស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ បង្ហាញពីការយល់ឃើញទាក់ទងនឹងលក្ខណៈនយោបាយរបស់ ខៀវ សំផន តាមរយៈការលើកឡើងរបស់លោក អំពីបុគ្គលឆ្វេងនិយមទាំង៣៤រូប ដែលមានឈ្មោះ*



*ខៀវ សំផន នៅពេលគស៊ូក្នុងព្រៃ (រូបថតឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅក្នុងបញ្ជីរបស់ លន់ នល់ ដែលបញ្ជូនថ្វាយសម្តេច សីហនុ នៅឆ្នាំ១៩៦៣ ។ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា សំណួរនេះធ្វើឲ្យលោកនឹកឃើញ ខៀវ សំផន កាលពីឆ្នាំ១៩៦០-១៩៦២ ពេលលោកស្នាក់នៅប្រទេសកម្ពុជា ។ លោកបានពន្យល់ថា មិនមានភស្តុតាងណាបញ្ជាក់ឲ្យលើសពីអ្វីដែលលោកយល់ឃើញថា ខៀវ សំផន ជាជនចម្រើននៅក្នុងចំណោមបញ្ញវ័ន្តកម្ពុជាទេ ។ ប៉ុន្តែក្រោយមក កាសែតជាភាសាបារាំងរបស់ ខៀវ សំផន ត្រូវបានសម្តេច សីហនុ បញ្ជាឲ្យបិទមិនឲ្យផ្សព្វផ្សាយ ដោយសារតែ ខៀវ សំផន ត្រូវបានចោទប្រកាន់ថា ជាជនឆ្វេងនិយម ។*

### ៤.គ.៥) បញ្ហាទាក់ទងតួលេខនៃចំនួនមនុស្សស្លាប់ក្នុងទសវត្សរ៍៧០

*មិនខុសគ្នាពីក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី លោកមេធាវី វ៉ែកគែន បានបន្តស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ បញ្ជាក់អំពីតួលេខនៃមនុស្សដែលស្លាប់នៅចន្លោះឆ្នាំ១៩៧០ និង ១៩៨០ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយតបចំពោះសំណួរនេះថា ដូចចម្លើយដែលលោកបានពន្យល់ពីមុនហើយថា តួលេខអ្នកស្លាប់គឺលោកយោងលើការស្រាវជ្រាវរបស់លោក និងយោងលើការធ្វើប្រជាសាស្ត្ររបស់លោក ហេវីរលីន ដែលថា ចំនួនអ្នកស្លាប់គឺស្ថិតនៅចន្លោះពី១លាន ទៅ៣លាន ។ លោកបន្តថា បើតាមតួលេខដែលប្រមូលដោយប្រទេសវៀតណាម ចំនួនអ្នកស្លាប់គឺមានរហូតដល់៣លាននាក់ ប៉ុន្តែចំនួននេះ ត្រូវបានជនដាប់ចោទនៅក្នុងសវនាការធ្លាប់បានលើកឡើងថា ចំនួន៣លាននាក់ គឺទាល់តែវៀតណាមជាអ្នកសម្លាប់ ។ ដូច្នេះមានការលំបាកក្នុងការកំណត់អំពីតួលេខ ហើយតួលេខទាំងអស់ គឺសុទ្ធតែជាការប៉ាន់ស្មាន ។*

### ៤.គ.៦) នយោបាយសមូហភាវូបនីយកម្ម

*ទាក់ទងនឹងប្រភេទសមូហភាវូបនីយកម្មនៅមុនឆ្នាំ១៩៧០ និងនៅឆ្នាំ១៩៧៥ លោកមេធាវីបានស្នើឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ពីលក្ខណៈខុសគ្នានៃសមូហភាវូបនីយកម្មទាំងពីរនេះ ។ លោកសាស្ត្រាចារ្យ បានពន្យល់ថា ដោយយោងលើការស្រាវជ្រាវរបស់លោក កេណ្ណេត ឃ្វីន ដែលទទួលព័ត៌មានបានពីជនភៀសខ្លួនទៅប្រទេសវៀតណាម បានបញ្ជាក់ថា ការអនុវត្តភាគច្រើនគឺត្រូវយកលំនាំតាមគោលនយោបាយសមូហភាពឆ្នាំ១៩៧៣ ដែលដឹកនាំដោយ តាម៉ុក ដែលជាសមាជិកនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ។ គោលនយោបាយទាំងនោះមានដូចជា ការ*

ប្រើប្រាស់សំលៀកបំពាក់ដូចគ្នា ការហូបអាហាររួម ការធ្វើការងារធ្ងន់ និងការដកហូតទ្រព្យសម្បត្តិឯកជនជាដើម ។ ប៉ុន្តែលោកបានទទួលស្គាល់ថា ការចាប់ផ្តើមគោលនយោបាយនេះគឺជាជោគជ័យមួយ ។ ការអនុវត្តគោលនយោបាយ គឺខុសៗគ្នានៅតាមតំបន់មួយចំនួន ដោយយោងលើការស្រាវជ្រាវរបស់លោក មីឆែល វីឃ័ររី (Michael Vikery) ដែលបានធ្វើសម្ភាសន៍ជាមួយជនភៀសខ្លួននៅឆ្នាំ១៩៨០ និង១៩៨១ ។ មានភស្តុតាងជាច្រើនបង្ហាញថា ការអនុវត្តនយោបាយនោះ មិនមានបុគ្គលណាតឹងរឹងដូចជា តាម៉ុក ទេ ។

### ៤.គ.៧) ការបោសសម្អាត

លោកមេធាវីបានចោទសំណួរទាក់ទងនឹងការបោសសម្អាតខ្មាំង ថាតើការបោសសម្អាតខ្មាំងគឺដោយសារបុគ្គលនោះជាជនជាតិភាគតិច ឬដោយសារតែអ្នកទាំងនោះមានជាប់ពាក់ព័ន្ធនឹងវណ្ណៈអ្វីមួយ? ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យ ឆេនដល័រ បានបញ្ជាក់ថា ការកម្ទេច គឺត្រូវពឹងផ្អែកលើមូលដ្ឋានជាក់លាក់ ហើយបញ្ហានេះ គឺពិតជាពិបាកក្នុងការនិយាយ ទោះបីជាមានការសម្លាប់ជនជាតិវៀតណាមនៅឆ្នាំ១៩៧៨ ដែលអាចនិយាយថាជាការបោសសម្អាតក៏ដោយ ។ សម្រាប់ខ្លួនលោកសាស្ត្រាចារ្យផ្ទាល់ លោកយល់ថា ការសម្លាប់ជនជាតិវៀតណាម គឺជាអំពើប្រល័យពូជសាសន៍ ដោយយោងលើអនុសញ្ញាអង្គការសហប្រជាជាតិ ហើយត្រង់ចំណុចនេះ លោកក៏បានសរសេរនៅក្នុងសៀវភៅរបស់លោកដែរ ។

### ៤.គ.៨) ឯកសារកំណត់ហេតុដែលបាត់បង់

លោកមេធាវី វែកគែន បានស្នើឲ្យលោកសាស្ត្រាចារ្យ ឆេនដល័រ ធ្វើការពន្យល់ពីស្ថានភាពក្នុងការសេរសេរប្រវត្តិសាស្ត្ររបស់លោក ដោយសារមានការបាត់បង់កំណត់ហេតុដែលធ្វើឡើងក្នុងពេលកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចំនួន៣០០ដង ប៉ុន្តែកំណត់ហេតុដែលបន្សល់ទុកមានតែចំនួន១៩ ។ ឆ្លើយតបនឹងការលើកឡើងដូច្នេះ លោកបានបំភ្លឺថា កិច្ចប្រជុំដែលធ្វើឡើងនោះជាទូទៅប្រជុំម្តងក្នុងមួយសប្តាហ៍ ដូច្នេះក្នុងរយៈពេលជាងបីឆ្នាំនៃរបបខ្មែរក្រហម កិច្ចប្រជុំនោះមានតែ១៥០តែប៉ុណ្ណោះ ។ ផ្ទុយទៅវិញ បើយោងលើការបញ្ជាក់របស់ ខៀវ សំផន ដែលបញ្ជាក់ថាកិច្ចប្រជុំពេលខ្លះធ្វើឡើងពីរដងក្នុងមួយសប្តាហ៍ ដូច្នេះចំនួន៣០០ដងនៃកិច្ចប្រជុំ គឺអាចជាចំនួនជាក់លាក់ ។ លោកបានធ្វើការប្រៀបធៀបថា នៅក្នុងរបបកុម្មុយនីស្តចិន និងសូវៀត មិនមានបន្សល់ទុកឯកសារកំណត់ហេតុណាដែលអាចឲ្យអ្នកនិពន្ធយោងបានទេ ។ ដូច្នេះហើយ ការសរសេរប្រវត្តិសាស្ត្រមិនចាំបាច់ទាល់តែមានឯកសារកំណត់ហេតុជាក់លាក់ទេ អ្នកសរសេរអាចយោងលើព័ត៌មានពីប្រភពផ្សេងៗ ។

បន្ទាប់មកលោកមេធាវីបានបង្ហាញឯកសារមួយទាក់ទងនឹងកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដើម្បីឲ្យលោកសាស្ត្រាចារ្យធ្វើការបញ្ជាក់ថា តើឯកសារទាំងនោះលោកធ្លាប់ឃើញជាឯកសារដើមដែរឬយ៉ាងណា? លោកសាស្ត្រាចារ្យបានឆ្លើយតបថា លោកពិតជាធ្លាប់បានឃើញឯកសារកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍នោះ ហើយលោកក៏ធ្លាប់បានថតចម្លងឯកសារនេះដែរ ។ លើសពីនេះទៅទៀត លោកក៏មានឯកសារចម្លើយសារភាព និងឯកសារថតចម្លងផ្សេងៗទៀតដែរ ។

### ៤.គ.៩) ឯកសារដែលផ្តល់ដោយលោក ខៀវ កាញ៉ារិទ្ធ

លោកមេធាវីបានសួរបន្តទាក់ទងនឹងកំណត់ហេតុនៃកិច្ចប្រជុំដែលធ្វើឡើងនៅថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៧៦ ដែលត្រូវបានរកឃើញនៅក្នុងផ្ទះមួយនៅឆ្នាំ១៩៧៩ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ឯកសារនោះត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុរបស់តុលាការ ហើយមិនមែនឯកសារសម្ងាត់ទេ ។ លោកបន្តថា ឯកសារនោះលោក ខៀវ កាញ៉ារិទ្ធ បានប្រគល់ជូនលោកសាស្ត្រាចារ្យ ប៊ែន ឃៀរនិន ។ លោកបានដឹងអំពីការប្រគល់ឯកសារនេះ ដោយសារនៅឆ្នាំ១៩៩០ លោកបានសម្ភាសន៍ជាមួយលោក ខៀវ កាញ៉ារិទ្ធ ។ ពេលនោះលោក ខៀវ កាញ៉ារិទ្ធ បាននិយាយថា លោកមានការអន់ចិត្តដោយសារឯកសារដែលផ្តល់ឲ្យ លោក ឃៀរនិន មានចំនួនច្រើន ប៉ុន្តែលោកបានយកទៅសរសេរបោះពុម្ពផ្សាយតែមួយឯកសារប៉ុណ្ណោះ ។ បន្ទាប់មកលោក ខៀវ កាញ៉ារិទ្ធ ក៏បានប្រគល់ឯកសារផ្សេងទៀត ប្រហែលប្រាំពីរ ឬប្រាំបីជូនមកលោក ។ លោកសាស្ត្រាចារ្យបានបន្ថែមថា ឯកសារដែលផ្តល់ឲ្យលោក និងលោក ឃៀរនិន គឺត្រូវបានរកឃើញនៅក្នុងផ្ទះតែមួយក្នុងពេលជាមួយគ្នា ហើយឯកសារដែលផ្តល់ឲ្យលោក គឺលោកបានយកទៅថតចម្លង និងដាក់ឈ្មោះអ្នកដែលផ្តល់ឲ្យ

ព្រមទាំងមានការអនុញ្ញាតិរបស់លោក ក្នុងការចែករំលែកដល់អ្នកស្រាវជ្រាវជាច្រើនផ្សេងទៀត ។ លោកមេធាវីបានបន្តសំណួរទាក់ទងនឹងទីតាំងរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែសំណួរនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះបង្គាប់មិនឲ្យលោកសាស្ត្រាចារ្យឆ្លើយតប ដោយសារមិនពាក់ព័ន្ធនឹងជំនាញរបស់លោក ។

### ៤.ក.១០) តួនាទី ខៀវ សំផន ក្នុងមន្ទីរ៨៧០

បន្ទាប់មក លោកមេធាវីបានស្នើឲ្យសាស្ត្រាចារ្យ ឆេនដល័រ បញ្ជាក់ពីឈ្មោះ ឌឿន និង យ៉ែម ដែលធ្វើការនៅមន្ទីរ៨៧០ ។ លោកសាស្ត្រាចារ្យបានពន្យល់ថា អ្នកទាំងពីរ គឺជាមនុស្សផ្សេងគ្នា ។ ឌឿន គឺ សឿ វ៉ាសុី តែចំពោះសមមិត្ត យ៉ែម លោកមិនអាចសម្គាល់ថាជានណារទេ ប៉ុន្តែឈ្មោះនេះ ខៀវ សំផន ធ្លាប់បានប្រើ ។ ទាក់ទងនឹងតួនាទីរបស់អ្នកទាំងពីរ លោកបញ្ជាក់ថា អ្នកទាំងនោះគឺបញ្ជូនឯកសារចុះឡើងទៅមន្ទីរ៨៧០ ប៉ុន្តែឯកសារទាំងអស់របស់បក្សមិនមែនសុទ្ធតែត្រូវបញ្ជូនឲ្យមន្ទីរ៨៧០ នោះទេ ។ លោកមេធាវីបានបន្តសួរលោកសាស្ត្រាចារ្យទាក់ទងនឹងប្រភពឯកសារដែលលោកសាស្ត្រាចារ្យបានលើកឡើងនៅក្នុងសវនាការថា ខៀវ សំផន បានបន្តដំណែងពី ឌឿន ដែលមានតួនាទីជាប្រធានមន្ទីរនយោបាយ៨៧០ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា លោកបានអានឯកសារនោះ នៅកន្លែងជាច្រើន ប៉ុន្តែលោកមិនបានចាំពីប្រភពឯកសារទេ ។

### ៤.ក.១១) ការរំឭកអំពីការបាត់ខ្លួនរបស់ ខៀវ សំផន

លោកមេធាវី វ៉េកគែន បានបន្តសួរសំណួរទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់លោកសាស្ត្រាចារ្យអំពី មូលហេតុនៃការភៀសខ្លួនចូលក្នុងព្រៃរបស់ ខៀវ សំផន ដោយលោកមេធាវីយោងលើការផ្តល់សក្ខីកម្មរបស់លោកសាស្ត្រាចារ្យក្នុងសវនាការនាពេលកន្លងទៅ ។ លោកសាស្ត្រាចារ្យ ឆេនដល័រ បានយល់ស្របចំពោះការលើកឡើងរបស់មេធាវីដោយ បញ្ជាក់ថាសម្តេច សីហនុ បានចោទ ខៀវ សំផន ថាបានបង្កឲ្យមានការបះបោរនៅសំឡូត ដែលជាអំពើទុរយសបំផុត ។ ចំពោះសំណួរទាក់ទងនឹងសៀវភៅ "សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា" ដែលនិយាយអំពីការស្លាប់របស់ ខៀវ សំផន ថាតើស្ថានភាពនេះជាការជំរុញឲ្យ ប៉ុល ពត ប្ញូន់ យកប្រជាប្រិយភាពរបស់ ខៀវ សំផន ឬយ៉ាងណា? លោកសាស្ត្រាចារ្យអះអាងថា លោកមិនមានភស្តុតាងណាដែលនិយាយពីបញ្ហានេះឡើយ ។ លោកបានបន្ថែមថា នៅក្នុងអំឡុងពេលនោះ ខៀវ សំផន គឺជាបេក្ខជននៅក្នុងមណ្ឌលបោះឆ្នោតមួយ ហើយក៏ជាតំណាងរាស្ត្រម្នាក់ក្នុងចំណោមអ្នកតំណាងរាស្ត្រពីរ ឬបីនាក់ផ្សេងទៀតដែលទៅធ្វើទស្សនៈកិច្ច យកចិត្តទុកដាក់ និងឆ្លើយតបចំពោះការលំបាករបស់ប្រជាជន ។ លោកមិនយល់ស្របថាព័ត៌មានដែលនិយាយពីការស្លាប់របស់ ខៀវ សំផន ធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាឡើយ ហើយលោកក៏មិនគិតថាមានមន្ត្រីជាន់ខ្ពស់របស់បក្សនៅខេត្តកណ្តាលធ្វើការកៀងគរនិស្សិត ១៥,០០០នាក់ចំពោះព័ត៌មាននៃការស្លាប់របស់ ខៀវ សំផន នេះដែរ ។ តាមរយៈប្រវត្តិទំនាក់ទំនងរវាង ប៉ុល ពត និង ខៀវ សំផន មិនមានការបង្ហាញណាមួយឲ្យឃើញថា ប៉ុល ពត មានចេតនាបំផ្លាញប្រជាប្រិយភាពរបស់ ខៀវ សំផន ឡើយ ប៉ុន្តែលោកបានបន្ថែមថា សម្តេច សីហនុ មិនពេញចិត្តចំពោះប្រជាប្រិយភាពនេះទេ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងភាសាដែលសម្តេច សីហនុ ប្រើសំដៅលើ ខៀវ សំផន លោកសាស្ត្រាចារ្យ ឆេនដល័រ បានពន្យល់ថា ខៀវ សំផន មានការតក់ស្លុតខ្លាំងចំពោះភាសាដែលសម្តេច សីហនុ មានបន្ទូលនៅពេលនោះ ដែលភាសានេះធ្វើឲ្យ ខៀវ សំផន យល់ថាខ្លួននឹងត្រូវបានចាប់ដាក់គុកមិនខាន ។ ដូច្នេះហើយ ខៀវ សំផន ក៏សម្រេចចិត្តចាកចេញពីទីក្រុងភ្នំពេញ ។ លោក មេធាវីបានសាកសួរពីសមាជិកភាពរបស់ ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តមុនពេល ខៀវ សំផន ចូលព្រៃនៅឆ្នាំ១៩៦៧ ។ តាមរយៈការរៀបរាប់របស់លោក ឆេនដល័រ បានបង្ហាញថា លោកមិនមានឯកសារ ឬកាតជាសមាជិករបស់ ខៀវ សំផន ឡើយ ដោយសារនៅក្នុងពេលនោះសមាជិកភាពរបស់ ខៀវ សំផន ឬជនដទៃទៀតគឺជាការសម្ងាត់ ។

**គួរកត់សម្គាល់ថា** ការចោទសួររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ចប់នៅព្រឹកថ្ងៃ ទី២៥ ខែកក្កដា ឆ្នាំ២០១២ ។ បន្ទាប់មក នៅរសៀលថ្ងៃដដែលអង្គជំនុំជម្រះបានបន្តសួរសាក្សីមួយរូបផ្សេងទៀត ដែលមានឈ្មោះថា របឹម គុន ជាអតីតកម្មាភិបាលជាន់ខ្ពស់ក្នុងក្រសួងការបរទេសនៃរបប កម្ពុជាប្រជាធិបតេយ្យ ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ស-២១ ៖ មន្ទីរសន្តិបាលស-២១ គឺជាមន្ទីរសន្តិសុខសម្ងាត់របស់នគរបាលដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។

អគ្គសេនាធិការ ៖ ទីបញ្ជាការជាន់ខ្ពស់នៃកងទ័ពបដិវត្តកម្ពុជាដែលដឹកនាំដោយ សុន សេន ស្ថិតនៅទីក្រុងភ្នំពេញ ។

ក-១ ៖ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ ប៉ុល ពត ។

ក-២ ៖ លេខកូដសម្គាល់សម្រាប់ក្រសួងសង្គមកិច្ច ។

ក-៣ ៖ លំនៅដ្ឋានមួយរបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាកន្លែងធ្វើការរបស់ នួន ជា និង ខៀវ សំផន ។


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ dccam@online.com.kh

គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

John D. and Catherine T. MacArthur Foundation and British Embassy-Cambodia ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១ | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

**ឈុនលី** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ឌី សុជាតា**

**សុជាតា** ទទួលបានបរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យទ័ត្ត**

**ជ័យទ័ត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ និងបរិញ្ញាប័ត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ចាន ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។


សង្កេតការណ៍
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម
ខៀវ សំផន ហៅ សមមិត្ត ហែម
នួន ជា
កាំង ហ្គេកអ៊ាវ ហៅឌុច
អៀង ធីរិទ្ធ ហៅសមមិត្ត ភា
សវនាការលើអង្គសេចក្តី ករណី ០០២
ការសួរដេញដោល និងពិនិត្យ ភស្តុតាងក្នុងសំណុំរឿង ០០២
បន្តការសួរដេញដោល និងពិនិត្យ ភស្តុតាងក្នុងសំណុំរឿង ០០២
មាតិកា
ក្រុមសង្កេតការណ៍ :